ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ឆ្នាំ ២០២៤

"ធ្វើសុខដុមនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្នុងទម្រង់ជាប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ សំដៅដល់ការធ្វើបរិវត្តកម្មឌីជីថល
ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព"

រៀបចំដោយ

ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ខែ វិច្ឆិកា ឆ្នាំ ២០២៤

អារម្ភកថា

ក្នុងរយៈពេលជាង ២ ទសវត្សរ៍ចុងក្រោយ, បច្ចេកវិទ្យាឌីជីថលបានក្លាយជាផ្នែកដ៏សំខាន់មិនអាចខ្វះបាន សម្រាប់សកម្មភាពសេដ្ឋកិច្ច និងសង្គម ព្រមទាំងបានផ្តល់នូវកាលានុវត្តភាពថ្មីជាច្រើន តាមរយៈការនាំមកនូវគំរូធុរកិច្ចថ្មីៗ ប្រកបដោយនវានុវត្តន៍ខ្ពស់, ការបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ និងការពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងធុរជន ជាដើម។ ស្របតាមនិន្នាការរបស់ប្រទេសនៅក្នុងតំបន់ និងសកល, កម្ពុជាក៏បានទទួលស្គាល់សារៈសំខាន់នៃបច្ចេកវិទ្យាឌីជីថល និងបានកំពុងខិតខំពង្រឹងខ្លួនក្នុងការចាប់យកឱកាស ដើម្បីរួមចំណែកដល់ការកសាង និងអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ក្នុងដំណើរឆ្ពោះទៅកាន់ការធ្វើបរិវត្តកម្មឌីជីថលនេះ, រាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់នូវឯកសារគតិយុត្តមានជាអាទិ៍ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥, គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ ព្រមទាំងគោលនយោបាយ និងឯកសារយុទ្ធសាស្ត្រពាក់ព័ន្ធជាច្រើនទៀត។

ក្នុងនាមជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការជំរុញការកសាង និងអភិវឌ្ឍគ្រឹះសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន និងកំពុងចាប់យក, ប្រើប្រាស់ និងបង្កើនល្បឿនការធ្វើឌីជីថលភាវូបនីយកម្ម និងការធ្វើទំនើបកម្មនៃប្រព័ន្ធការងាររបស់ខ្លួន។ កិច្ចការនេះត្រូវបានចាត់ទុកជាអាទិភាពមួយ ក្នុងអាទិភាពជាច្រើនទៀត សំដៅបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ក៏ដូចជាការពង្រឹងការផ្តល់សេវាសាធារណៈ និងដើម្បីឆ្លើយតបទៅនឹងគោលនយោបាយដែលបានដាក់ចេញ និងរួមចំណែកជារួមដល់គោលដៅនៃការធ្វើបរិវត្តកម្មឌីជីថលរបស់រាជរដ្ឋាភិបាល។ ជាលទ្ធផល ក្នុងរយៈពេលជាង ១០ ឆ្នាំកន្លងមកនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាអង្គភាពក្រោមឱវាទ បានកសាង និងអភិវឌ្ឍគម្រោង និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើន ដែលត្រូវបានចាត់ទុកថាជាហេដ្ឋារចនាសម្ព័ន្ធសំខាន់ (Critical Infrastructure) របស់ប្រទេស។ ប៉ុន្តែ ក្រៅតែពីបានហុចផលយ៉ាងច្រើនដល់ការងារប្រចាំថ្ងៃ, ការរីកធំធាត់នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់នេះ ក៏បានបង្កើតជាបញ្ហាប្រឈមថ្មីក្នុងការគ្រប់គ្រងជាពិសេសក្នុងបរិការណ៍ដែលប្រព័ន្ធទាំងនោះ ចាប់ផ្តើមធ្វើអន្តរប្រតិបត្តិការជាមួយគ្នា។ ការណ៍នេះ ទាមទារនូវការគិតគូរ និងការកសាងក្របខ័ណ្ឌនិម្មាបនកម្មរួមមួយ ដែលជាផែនទីបង្ហាញផ្លូវក្នុងដំណើរនៃការធ្វើបរិវត្តកម្មឌីជីថល។

ក្នុងស្ថានភាពនេះ និងដើម្បីបន្តជំរុញការធ្វើបរិវត្តកម្មឌីជីថលឱ្យបានកាន់តែមានប្រសិទ្ធភាព និងមានភាពប្រទាក់ក្រឡាគ្នាច្បាស់លាស់, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់ចេញនូវក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងគោលបំណង "**ធ្វើសុខដុមនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងទម្រង់ជាប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ សំដៅដល់ការធ្វើបរិវត្តកម្មឌីជីថល ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព**" និងបានដាក់ចេញនូវគោលដៅ "**កំណត់មុខងាររបស់អង្គភាពលើការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, រៀបចំអភិបាលកិច្ចទិន្នន័យ, រៀបចំយន្តការអន្តរប្រតិបត្តិការ, កំណត់សេចក្តីណែនាំជាស្តង់ដាសម្រាប់អភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងជំរុញការប្រើប្រាស់បច្ចេកវិទ្យា និងធនធានរួម**"។ ក្របខ័ណ្ឌនេះ អនុវត្តឈរលើគោលការណ៍ចំនួន ៣ រួមមានគោលការណ៍បញ្ចូលទិន្នន័យតែមួយលើក, គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ និង

គោលការណ៍ផ្តួចផ្តើម និងពង្រីកដើម្បីប្រសិទ្ធភាព ដែលបានដាក់ចេញក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ។ បន្ថែមលើនេះ, ក្របខ័ណ្ឌនេះមានគោលការណ៍ចំនួន ៦ ទៀត រួមមានភាពជាម្ចាស់, អន្តរប្រតិបត្តិការ, ស្តង់ដាអភិវឌ្ឍ, ទិន្នន័យបើកចំហ, បច្ចេកវិទ្យា និងធនធានរួម និងគុណភាពនិងប្រសិទ្ធភាព។ គោលការណ៍ទាំងនេះ ត្រូវអនុវត្តដោយឈរលើអភិក្រមចំនួន ៣ រួមមាន មនុស្ស, ដំណើរការ និងបច្ចេកវិទ្យា។

ជារួម ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អាចចាត់ទុកថាជាឯកសារក្របខ័ណ្ឌដ៏មានសារៈសំខាន់សម្រាប់ជាមូលដ្ឋានក្នុងការត្រៀម និងអភិវឌ្ឍខ្លួន ដើម្បីឆ្ពោះទៅការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាសម្រាប់រាជរដ្ឋាភិបាលផងដែរ។ ដើម្បីឱ្យការអនុវត្តក្របខ័ណ្ឌនេះសម្រេចបាននូវភាពជោគជ័យ, អង្គភាពពាក់ព័ន្ធទាំងអស់ត្រូវចូលរួមអនុវត្តឱ្យបានពេញលេញប្រកបដោយស្មារតីបុរេសកម្ម, អន្តរសកម្ម, ម្ចាស់ការ និងសហការទទួលខុសត្រូវខ្ពស់ ព្រមទាំងប្រតិបត្តិតាមឱ្យបានខ្ជាប់ខ្ជួននូវគុណតម្លៃស្ថាប័ន និងបំពេញកិច្ចការ ស្របតាមអភិក្រមរដ្ឋាភិបាលទាំងមូល និងជវាភាពនៃប្រព័ន្ធតួអង្គតែមួយ។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមអរគុណចំពោះអង្គភាពទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម និងបានផ្តល់កិច្ចសហការជាមួយនឹងក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មានតាំងពីដើមរហូតដល់ចប់។ ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិត **តង់ ម៉ារី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានប្រចាំការនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងសមាជិក និងសមាជិកានៃក្រុមការងារបច្ចេកទេសទាំងអស់ ដែលបានខិតខំប្រឹងប្រែងរៀបចំឯកសារនេះរហូតសម្រេចបានជាស្តាពរ។

ថ្ងៃទី ខែ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២៤

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន
ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៧៧៤...សហវ.ប្រកាស

ប្រកាស
ស្តីពី
ការដាក់ឱ្យអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៨/១៣៣៣ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១១៩០ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២២១ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើត គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិង ការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិង ការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យស្ថិតក្រោម ការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២០២ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបំពាក់មុខងារ បន្ថែមឱ្យមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាអង្គភាពបរិវត្តកម្មឌីជីថលនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈ- កម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតមជ្ឈមណ្ឌល បណ្តុះធុរកិច្ចថ្មី "តេជោ" ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៧១ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"
- បានឃើញអនុក្រឹត្យលេខ ១៦៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការប្រែក្លាយ ពីទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាលទៅជាភ្នាក់ងារជាតិបញ្ជាក់ចំណាយ
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១.-

ត្រូវបានដាក់ឱ្យអនុវត្ត "**ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**" ដើម្បីធ្វើសុខដុមនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សំដៅជំរុញការធ្វើបរិវត្តកម្មឌីជីថល ប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

ប្រការ២.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអង្គភាពឬស្ថាប័នក្រោមអាណាព្យាបាលនិងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រការ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៤.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងប្រធានគ្រប់អង្គភាពឬស្ថាប័នក្រោមអាណាព្យាបាលនិងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់អង្គភាពឬស្ថាប័នក្រោមអាណាព្យាបាល និងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

មាតិកា

អារម្ភកថា i

ប្រកាសស្តីពីការដាក់ឱ្យអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ iii

បញ្ជីពាក្យកាត់ viii

ខ្លឹមសារសង្ខេប xi

១. សេចក្តីផ្តើម ១

១.១. បរិការណ៍ និងទស្សនាទាននៃការរៀបចំនិម្មាបនកម្ម ១

១.២. វិសាលភាពនៃក្របខ័ណ្ឌនិម្មាបនកម្ម ៣

២. ស្ថានភាពប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៤

២.១. ទស្សនាទានពាក់ព័ន្ធនឹងប្រព័ន្ធអេកូឡូស៊ីឌីជីថល ៤

២.១.១. ប្រព័ន្ធអេកូឡូស៊ីឌីជីថល ៤

២.១.២. និម្មាបនកម្មសហគ្រាស ៦

២.២. ការសិក្សាពីបច្ចុប្បន្នភាពនៃប្រព័ន្ធអេកូឡូស៊ីឌីជីថល ៧

២.៣. បញ្ហាប្រឈមនៃប្រព័ន្ធអេកូឡូស៊ីឌីជីថល ១៤

២.៤. សនិទានភាពនៃការរៀបចំក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ១៦

២.៥. បច្ច័យវិជ្ជមាន ១៧

៣. ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ១៨

៣.១. គោលបំណង និងគោលដៅ ១៨

៣.២. គោលការណ៍ និងអភិក្រម ១៨

៣.៣. និម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០

៣.៣.១. ស្រទាប់មុខងារធុរកិច្ច ២២

៣.៣.២. ស្រទាប់ទិន្នន័យ ២៤

៣.៣.៣. ស្រទាប់ប្រព័ន្ធ ឬកម្មវិធី ៣១

៣.៣.៤. ស្រទាប់បច្ចេកវិទ្យា ៣២

៤. យន្តការអនុវត្ត យន្តការស្ថាប័ន និងយន្តការគាំទ្រថវិកា ៣៦

៥. សន្និដ្ឋាន ៤០

ឧបសម្ព័ន្ធ ១. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងតួនាទីនៃអន្តរភាពក្នុងក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ៤៣

ឧបសម្ព័ន្ធ ២. បញ្ជីទិន្នន័យរបស់អន្តរាគមសម្រាប់ការផ្លាស់ប្តូរ ៤៦
ឧបសម្ព័ន្ធ ៣. គោលការណ៍សម្រាប់ការអភិវឌ្ឍប្រព័ន្ធ ៧៤
ឧបសម្ព័ន្ធ ៤. បច្ចេកវិទ្យាជាក់ដំណើរការរួម ៨១
ឧបសម្ព័ន្ធ ៥. ផែនការអនុវត្តលើការប្រតិបត្តិ, គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធ
បច្ចេកវិទ្យាព័ត៌មាន ៨៧
ឧបសម្ព័ន្ធ ៦. សន្ទានុក្រម ៩១
បរិសិដ្ឋ ១. ការពិនិត្យលើស្ថានភាពបច្ចុប្បន្នផ្អែកតាមនិម្មាបនកម្មសហគ្រាស ៩៥
បរិសិដ្ឋ ២. លទ្ធផលពីក្របខ័ណ្ឌ COBIT ២០១៩ ..... ១០៥
បរិសិដ្ឋ ៣. ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ១០៧
បរិសិដ្ឋ ៤. ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបច្ចេកវិទ្យា
ព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១១៤
បរិសិដ្ឋ ៥. សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាបច្ចេកវិទ្យា
ព័ត៌មាន និងសមាសភាពក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សា
បច្ចេកវិទ្យា ព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១២០
បរិសិដ្ឋ ៦. សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារនៃក្រសួងសេដ្ឋកិច្ច
និងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យ និងផ្តល់យោបល់លើសំណើ
គម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ១២៥
បរិសិដ្ឋ ៧. បញ្ជីឈ្មោះក្រុមការងាររៀបចំក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យា
ព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១៣០

បញ្ជីពាក្យកាត់

ACAR	និយ័តករគណនេយ្យ និងសវនកម្ម (Accounting and Auditing Regulator)
AI	បញ្ញាសិប្បនិម្មិត (Artificial Intelligence)
API	សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interface)
ASYCUDA	ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (Automated System for Customs Data)
CamDX	ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange)
CamDigiKey	ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា (Cambodia Digital Key)
CFRSMC	គណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា (Cambodia Food Reserve System Management Commission)
CGMC	គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា (Commercial Gambling Management Commission of Cambodia)
COBIT	Control Objectives for Information and Related Technologies
DEBC	គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (Digital Economy and Business Committee)
DMFAS	ប្រព័ន្ធគ្រប់គ្រងបំណុល និងវិភាគហិរញ្ញវត្ថុ (Debt Management and Financial Analysis System)
DPI	ហេដ្ឋារចនាសម្ព័ន្ធឌីជីថលសាធារណៈ (Digital Public Infrastructure)
EFI	វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Economics and Finance Institute)
EFPC	គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Economic and Financial Policy Committee)
FMIS	ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System)
GDB	អគ្គនាយកដ្ឋានថវិកា (General Department of Budget)
GDCE	អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (General Department of Customs and Excise)
GDDE	អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល (General Department of Digital Economy)
GDIA	អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (General Department of Internal Audit)
GDICDM	អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (General Department of International Cooperation and Debt Management)
GDR	អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (General Department of Resettlement)
GDNT	អគ្គនាយកដ្ឋានរតនាគារជាតិ (General Department of National Treasury)
GDP	អគ្គនាយកដ្ឋានគោលនយោបាយ (General Department of Policy)

GDPFMIT	អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (General Department of Public Financial Management Information Technology)
GDPP	អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ (General Department of Public Procurement)
GDPPP	អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន (General Department of Public Private Partnership)
GDSNAF	អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ (General Department of Sub-National Administration Finance)
GDSNR	អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (General Department of State Property and Non-Tax Revenue)
GDT	អគ្គនាយកដ្ឋានពន្ធដារ (General Department of Taxation)
GID	អគ្គាធិការដ្ឋាន (General Inspectorate Department)
GS	អគ្គលេខាធិការដ្ឋាន (General Secretariat)
GSC	គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Steering Committee of the Public Financial Management Reform)
GS-FSA	អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (General Secretariat – Non-Bank Financial Service Authority)
IRC	និយ័តករធានារ៉ាប់រងកម្ពុជា (Insurance Regulator of Cambodia)
LC-MEF	ក្រុមប្រឹក្សានីតិកម្ម (Legal Council – Ministry of Economy and Finance)
NCPEC	គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា (National Committee of Productive Economy of Cambodia)
NPCA	ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ (National Payment Certification Agency)
NRMIS	ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-tax Revenue Management Information System)
NSPC	ក្រុមប្រឹក្សាជាតិគាំពារសង្គម (National Social Protection Council)
OBR	ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Online Business Registration)
RPR	និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ (Real Estate Business and Pawnshop Regulator)
SARMIS	ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (State Asset Register Management Information System)
SERC	និយ័តករមូលបត្រកម្ពុជា (Securities and Exchange Regulator of Cambodia)
SNEC	ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (Supreme National Economic Council)
SOC	មជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខ (Security Operation Center)

SSR	និយ័តករសន្តិសុខសង្គម (Social Security Regulator)
TR	និយ័តករបរធនបាលកិច្ច (Trust Regulator)
TSC	មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (Techo Startup Center)

ខ្លឹមសារសង្ខេប

ក្នុងរយៈពេលប្រមាណជិត ៣ ទសវត្សរ៍មកនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំពេញមុខងារជាសេនាធិការជូនរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញការកសាង និងអភិវឌ្ឍគ្រឹះសេដ្ឋកិច្ចជាតិស្របទៅតាមបរិការណ៍ប្រទេស និងតំបន់ ព្រមទាំងបានដឹកនាំរៀបចំ និងអនុវត្តនូវគោលនយោបាយពង្រឹងស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើងជីវភាពប្រជាជន។ ក្នុងទិដ្ឋភាពរួម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរួមចំណែកក្នុងការប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលពឹងផ្អែកលើជំនួយបរទេសទាំងស្រុងសម្រាប់ការអភិវឌ្ឍ មកជាប្រទេសដែលអាចកៀរគរ, គ្រប់គ្រង និងវិភាជធនធានរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាព សម្រាប់ការអភិវឌ្ឍទៅតាមទិសដៅយុទ្ធសាស្ត្រ ប្រកបដោយឯករាជ្យ និងអធិបតេយ្យ។ ក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានខិតខំក្នុងការជំរុញការស្តារគ្រឹះសេដ្ឋកិច្ចជាតិ ស្របទៅតាមបរិការណ៍ប្រទេស, តំបន់ និងសកល ព្រមទាំងបានចូលរួមក្នុងការដឹកនាំរៀបចំ, អនុវត្ត និងចូលរួមអនុវត្តគោលនយោបាយពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បន្ថែមពីនេះ សម្រាប់វិស័យហិរញ្ញវត្ថុសាធារណៈ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានកសាង និងពង្រឹងនូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ជាបន្តបន្ទាប់ ដែលឆ្លើយតបនឹងបរិការណ៍ប្រទេស និងកំពុងធ្វើទំនើបកម្មជាបណ្តើរៗ ឆ្ពោះទៅរកឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ស្របតាមនិន្នាការសកល និងចក្ខុវិស័យនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញកន្លងមក, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន និងកំពុងធ្វើទំនើបកម្មការងាររបស់ខ្លួន តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ឬឌីជីថល សម្រាប់គាំទ្រ, ជំរុញ និងពន្លឿនដល់ការអនុវត្តកម្មវិធីគោលនយោបាយរបស់ក្រសួងខ្លួនឯងផ្ទាល់ផង ព្រមទាំងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជាផង ដើម្បីធានាឱ្យបាននូវគណនេយ្យភាព, តម្លាភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ សមិទ្ធផលជាច្រើនបានលេចឡើងតាមរយៈកិច្ចខិតខំប្រឹងប្រែងឥតស្រាកស្រាន្ត និងយកចិត្តទុកដាក់ ដែលរួមមានការបង្កើតនូវគំនិតផ្តួចផ្តើមក្នុងការរៀបចំ និងដាក់ឱ្យដំណើរការនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួន ក្នុងការធ្វើបរិវត្តកម្មសេវាសាធារណៈ ដែលមានវិសាលភាពធំទូលំទូលាយគ្របដណ្តប់នៅទូទាំងប្រទេស។ ទន្ទឹមនឹងសមិទ្ធផល ព្រមទាំងវឌ្ឍនភាពយ៉ាងល្អប្រសើរនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានកន្លងមក, បទពិសោធនៃការប្រើប្រាស់ និងគ្រប់គ្រងក៏បានជួបនូវបញ្ហាប្រឈមថ្មី ដែលចាំបាច់ត្រូវយកមកសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់ និងដាក់ចេញនូវការតម្រង់ទិស ឬវិធានការដោះស្រាយឱ្យមានប្រសិទ្ធភាព។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ចេញនូវក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងគោលបំណង "ធ្វើសុខដុមនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងទម្រង់ជាប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ សំដៅដល់ការធ្វើបរិវត្តកម្មឌីជីថល ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព" និងបានដាក់ចេញនូវគោលដៅ "កំណត់មុខងាររបស់អង្គភាពលើការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, រៀបចំក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ, រៀបចំក្របខ័ណ្ឌអន្តរប្រតិបត្តិការ, កំណត់

https://t.me/economyfinance

សេចក្តីណែនាំជាស្តង់ដាសម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងជំរុញការប្រើប្រាស់បច្ចេកវិទ្យា និងធនធានរួម"។ ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅដែលបានដាក់ចេញនេះ, ក្របខ័ណ្ឌនេះបានកំណត់នូវអភិក្រមសំខាន់ចំនួន ៣ គឺ មនុស្ស, ដំណើរការ និងបច្ចេកវិទ្យា។ ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប្រើប្រាស់គោលគំនិតនៃការរៀបចំក្នុងទម្រង់ជាប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការជាគោល ហើយសម្របតាមនិម្មាបនកម្មសហគ្រាសដោយបែងចែកជា ៤ ស្រទាប់សំខាន់ៗ រួមមាន (១)-ស្រទាប់មុខងារធុរកិច្ច, (២)-ស្រទាប់ទិន្នន័យ, (៣)-ស្រទាប់ប្រព័ន្ធ ឬកម្មវិធី និង (៤)-ស្រទាប់បច្ចេកវិទ្យា។ គោលការណ៍, សេចក្តីណែនាំ និងស្តង់ដាសំខាន់ៗ បានដាក់ចេញតាមស្រទាប់នីមួយៗ ហើយអង្គភាពទាំងអស់ត្រូវអនុលោមតាម។

ជាយន្តការអនុវត្ត អង្គភាពទាំងអស់ ដែលចង់ស្នើអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មី ឬកែលម្អប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចាស់ ត្រូវរៀបចំការស្នើសុំ និងដាក់មកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការពិនិត្យ និងសម្រេចក្នុងទិដ្ឋភាពបច្ចេកទេស ស្របតាមការកំណត់ក្នុងក្របខ័ណ្ឌនិម្មាបនកម្មនេះ។ ជាងនេះទៀត លេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មានក៏មានតួនាទីដឹកនាំ និងតាមដានជាប្រចាំ លើការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ។ ក្រុមការងារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យ និងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ជាអ្នកពិនិត្យលើទិដ្ឋភាពថវិកា នៃគម្រោងស្នើសុំ។ នៅពេលដែលគម្រោងស្នើសុំអភិវឌ្ឍប្រព័ន្ធនោះ បានរៀបចំរួចរាល់ និងត្រឹមត្រូវទាំងទិដ្ឋភាពបច្ចេកទេស និងទិដ្ឋភាពថវិកា, អង្គភាពអនុវត្តគម្រោងអាចដាក់ស្នើគម្រោងនោះទៅកាន់អង្គភាពផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តគម្រោង ដើម្បីទទួលបានថវិកាសម្រាប់រៀបចំ។ អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ត្រូវចូលរួមអនុវត្តក្របខ័ណ្ឌនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅសម្រេចបាននូវគោល-បំណងដែលបានដាក់ចេញ។

ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានចាត់ទុកថាជា "**ឯកសារស់**" ដែលអាចនឹងត្រូវកែសម្រួលជាយថាហេតុ ដើម្បីធានានូវសង្គតិភាព និងភាពសមស្របទៅតាមការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ក៏ដូចជាការវិវឌ្ឍជាក់ស្តែងនៃស្ថានការណ៍សេដ្ឋកិច្ច និងសង្គម។

១. សេចក្តីផ្តើម

១.១. បរិការណ៍ និងទស្សនាទានៃការរៀបចំនិម្មាបនកម្ម

ក្នុងបរិការណ៍បដិវត្តន៍ឧស្សាហកម្ម ៤.០, ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាពិសេស បច្ចេកវិទ្យាឌីជីថល បាន និងកំពុងលេចរូបរាងយ៉ាងច្បាស់ និងមានការវិវឌ្ឍយ៉ាងឆាប់រហ័ស ព្រមទាំងបាន នាំមកនូវទស្សនាទានថ្មីៗ ដូចជា សេដ្ឋកិច្ចឌីជីថល, សង្គមឌីជីថល និងរដ្ឋាភិបាលឌីជីថល ជាដើម។ បច្ចេកវិទ្យាឌីជីថលត្រូវបានចាត់ទុកថាជាកាតាលីករថ្មីដ៏មានសារៈសំខាន់ ក្នុងការជំរុញកំណើនផលិតភាព សេដ្ឋកិច្ច និងសង្គម ព្រមទាំងប្រសិទ្ធភាពនៃការងាររដ្ឋបាល និងការផ្តល់សេវាផ្សេងៗ ។ ដោយមើលឃើញ នូវនិន្នាការទាំងនេះ, រាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ សំដៅកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលដ៏រស់រវើក និងបន្ទាប់ មកក៏បានដាក់ចេញនូវគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ សំដៅកសាង និង ប្រែក្លាយរដ្ឋាភិបាលទៅជារដ្ឋាភិបាលឌីជីថល។ ទន្ទឹមនេះ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ បាន បន្ថែម "បច្ចេកវិទ្យា" ជាអាទិភាពគន្លឹះក្នុងចំណោមអាទិភាពទាំង ៥ ហើយបានបន្ថែមបញ្ចកោណទី ៥ "ការ អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល" ដែលមានមុំចំនួន ៥ នៅក្នុងនោះ។ កិច្ចខិតខំប្រឹងប្រែងតាមរយៈការ ដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រទាំងនេះ គឺដើម្បីជានាបាននូវដំណើរច្បាស់លាស់ ក្នុង គោលដៅឆ្ពោះទៅកាន់ការធ្វើបវិត្តកម្មឌីជីថល ដែលប្រទេសកម្ពុជាត្រូវសម្រេចឱ្យខានតែបាន។

ក្នុងរយៈពេលប្រមាណជិត ៣ ទសវត្សរ៍មកនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំពេញ មុខងារជាសេនាធិការជូនរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញការកសាង និងអភិវឌ្ឍគ្រឹះសេដ្ឋកិច្ចជាតិស្របទៅតាមបរិការណ៍ប្រទេស និងតំបន់ ព្រមទាំងបានដឹកនាំរៀបចំ និងអនុវត្តនូវគោលនយោបាយពង្រឹង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើងជីវភាពប្រជាជន។ ដើម្បីសម្រេចនូវបេសកកម្មរបស់ខ្លួន, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន និងកំពុងប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល សម្រាប់គាំទ្រ, ជំរុញ និងពន្លឿនដល់ការអនុវត្តកម្មវិធីគោលនយោបាយ របស់ក្រសួងខ្លួនឯងផ្ទាល់ ព្រមទាំងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management – PFM) របស់រាជរដ្ឋាភិបាលកម្ពុជា ដែលធានាឱ្យបាននូវគណនេយ្យភាព, តម្លាភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ សមិទ្ធផលជាច្រើនបានលេចឡើងតាមរយៈកិច្ចខិតខំប្រឹងប្រែងឥតស្រាក-ស្រាន្ត និងយកចិត្តទុកដាក់ ដែលរួមមានការបង្កើតនូវគំនិតផ្តួចផ្តើមក្នុងការរៀបចំ និងដាក់ឱ្យដំណើរការ នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួន ក្នុងការធ្វើបវិត្តកម្ម និងស្វ័យប្រវត្តិកម្មការងារ និងការផ្តល់សេវា សាធារណៈ ដែលមានវិសាលភាពធំទូលំទូលាយគ្របដណ្តប់ទូទាំងប្រទេស។ អង្គភាពក្រោមឱវាទក្រសួង បានងាកមកចាប់ផ្តើមអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ ខ្លួន សំដៅសម្រេចបាននូវបេសកម្មរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់។ ជាមួយនឹងលទ្ធផលដែលសម្រេច បានជាច្រើនកន្លងមក, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅតែបន្តធ្វើកិច្ចការយ៉ាងសកម្ម ប្រកបដោយស្មារតី យកចិត្តទុកដាក់ និងភាពប្រុងប្រយ័ត្នខ្ពស់បំផុត សំដៅជានាសម្រេចបាននូវគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើងជីវភាពប្រជាជន។

កន្លងមក ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឆ្លង កាត់ដំណាក់កាលសំខាន់ៗ មួយចំនួន ដោយរាប់ចាប់តាំងពី (១)-ការធ្វើការតាមបែបប្រពៃណី ដែលការងារ

ស្នូលអនុវត្តដោយមិនប្រើបច្ចេកវិទ្យាព័ត៌មានទាល់តែសោះ, (២)-ការធ្វើការតាមបែបឌីជីតូបនីយកម្ម (Digitization) ដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់តែផ្ទុកទិន្នន័យដើម្បីងាយស្រួលស្វែងរក ខណៈដែលការងារស្នូលនៅតែអនុវត្តដោយមិនប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង (៣)-ការធ្វើការតាមបែបឌីជីថលូបនីយកម្ម ដែលការអនុវត្តការងារស្នូលមួយចំនួនធំពឹងផ្អែកលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ គិតត្រឹមពេលនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់-កាលទី ៣ ដោយបានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់បំពេញការងារស្នូល ជាពិសេសលើទិដ្ឋភាពការងារសំខាន់ៗ មួយចំនួន។ ក្នុងទិដ្ឋភាពជារួម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាមិនទាន់ឈានដល់ដំណាក់កាល នៃការធ្វើការតាមបែបបរិវត្តកម្មឌីជីថលទាំងស្រុងនៅឡើយទេ ឬអាចនិយាយបានថាមិនទាន់ឈានដល់ការក្លាយខ្លួនជារដ្ឋាភិបាលឌីជីថលពេញលេញនៅឡើយ។ ប៉ុន្តែការខិតខំ និងសមិទ្ធផលកន្លងមក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា បានជំរុញឱ្យកម្ពុជាស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការធ្វើបរិវត្តកម្មឌីជីថល ព្រមទាំងបានផ្តល់នូវមូលដ្ឋានគ្រឹះយ៉ាងសំខាន់ និងបច្ចុយដ៏ប្រសើរក្នុងដំណើរឈានទៅសម្រេចបានការធ្វើបរិវត្តកម្មឌីជីថលពេញលេញនៅថ្ងៃខាងមុខ។

ទន្ទឹមនឹងសមិទ្ធផលដែលមានកន្លងមក, ការប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏កំពុងតែជួបប្រទះនូវបញ្ហាស្មុគស្មាញ និងកត្តាប្រឈមមួយចំនួនផងដែរទាំងនៅក្នុងទិដ្ឋភាពនៃការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ទិដ្ឋភាពនៃការគ្រប់គ្រងទិន្នន័យ ក៏ដូចជាទិដ្ឋភាពនៃការវិនិយោគលើការអភិវឌ្ឍ និងថែទាំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាដើម។ ជាទិដ្ឋភាពរួមនៃបញ្ហាស្មុគស្មាញ និងចាក់ស្រេះនេះ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលកំពុងអនុវត្តបច្ចុប្បន្នហាក់នៅបែក-ខ្ញែកពីគ្នា ដោយមិនមានការភ្ជាប់ និងចែករំលែកទិន្នន័យឱ្យគ្នាទៅវិញទៅមក ព្រមទាំងមិនទាន់មានស្តង់ដារួមសម្រាប់ការអភិវឌ្ឍ, ប្រតិបត្តិ និងតាមដាននៅឡើយ។ បើពិនិត្យឱ្យកាន់តែជាក់លាក់ បញ្ហាប្រឈមដែលកំពុងជួបប្រទះមានដូចជា៖ (១)-ធនធានមនុស្សនៅមានកម្រិត ទាំងចំនួន និងជំនាញបច្ចេកទេស, (២)-ការវិនិយោគ និងការគាំទ្រថវិកាលើការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅមានកម្រិត, (៣)-ទិន្នន័យនៅមានភាពរាយប៉ាយ និងមិនមានស្តង់ដា ហើយការចែករំលែកទិន្នន័យទៅវិញទៅមកនៅមានកម្រិតនៅឡើយ, (៤)-កង្វះខាតនូវគោលការណ៍ស្តង់ដារួមសម្រាប់ការអភិវឌ្ឍប្រព័ន្ធ, (៥)-ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងមជ្ឈមណ្ឌលទិន្នន័យ នៅមានទាន់មានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់ និង (៦)-ការផ្លាស់ប្តូរវប្បធម៌ការងារនៅមានភាពយឺតយ៉ាវ ជាដើម។

ផ្អែកតាមបរិការណ៍ និងស្ថានភាពខាងលើ ការរៀបចំក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គឺមានភាពចាំបាច់ និងសារៈសំខាន់ខ្លាំង ដើម្បីធ្វើសុខដុមនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលកំពុងតែប្រតិបត្តិទាំងអស់ និងជានាដល់ការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះស្របតាមគោលការណ៍ និងស្តង់ដាច្បាស់លាស់ សំដៅបម្រើដល់ការអនុវត្តមុខងាររបស់អង្គភាពក្រោមឱវាទឱ្យមានប្រសិទ្ធភាពការងារ។ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងការវិវឌ្ឍនៃបច្ចេកវិទ្យា, ការចាត់ទុកប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រព័ន្ធអេកូឡូស៊ីឌីជីថលមួយ អនុញ្ញាតឱ្យក្របខ័ណ្ឌដែលរៀបចំឡើងសមស្របជាមួយនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ។ ខណៈពេលដែលកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូង នៃការធ្វើបរិវត្តកម្មឌីជីថលនៅឡើយ, ការគិតគូរៀបចំ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ ត្រូវចាប់ផ្តើមធ្វើឡើងចេញពីមូលដ្ឋានធំល្មម, រៀបចំដោយសន្សឹមៗ និងធ្វើដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ សំដៅបង្កើនប្រសិទ្ធភាព និងផលិតភាព ខណៈដែលត្រូវកាត់បន្ថយហានិភ័យ និងបច្ច័យអសកម្មផ្សេងៗ ឱ្យនៅតិចតួចបំផុត។ ការរៀបចំក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏នឹងក្លាយជាម៉ូដែល និងជាមូលដ្ឋានដ៏មានសារៈសំខាន់សម្រាប់ការឈានទៅអនុវត្តអភិក្រម "**រដ្ឋាភិបាលទាំងមូល** - Whole-of-Government Approach"។

១.២. ទិសាលភាពនៃក្របខ័ណ្ឌនិម្មាបនកម្ម

"**ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" មានវិសាលភាពគ្របដណ្តប់ដល់គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងអង្គភាព ឬស្ថាប័នក្រោមអាណាព្យាបាល និងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អង្គភាព ឬស្ថាប័នស្ថិតក្រោមអាណាព្យាបាលក្រសួង ឬក្រោមឱវាទរដ្ឋមន្ត្រី សំដៅដល់អង្គភាពអន្តរក្រសួង, ស្ថាប័នដែលមានលក្ខណៈអចិន្ត្រៃយ៍ ឬអង្គភាពផ្សេងទៀតដែលស្ថិតនៅក្រៅវចនាសម្ព័ន្ធរដ្ឋបាលរបស់ក្រសួង ប៉ុន្តែមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន, មានអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានស្ថិតនៅក្រសួង, ឬមានកញ្ចប់ថវិកាស្ថិតនៅក្នុងក្របខ័ណ្ឌថវិកាកម្មវិធីរបស់ក្រសួង។ ក្របខ័ណ្ឌនេះ ផ្តោតលើមុខងារពាក់ព័ន្ធទៅនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់ដែលកំពុងប្រតិបត្តិ, កំពុងអភិវឌ្ឍ និងគ្រោងនឹងអភិវឌ្ឍនៅថ្ងៃខាងមុខ ដោយត្រូវអនុលោមតាមគោលការណ៍នៅក្នុងក្របខ័ណ្ឌនេះ។

២. ស្ថានភាពប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ការពិនិត្យលើស្ថានភាពបច្ចុប្បន្នអំពីប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្ហាញឱ្យឃើញច្បាស់ពីបញ្ហាប្រឈម និងឱកាស ដែលជារួមនឹងផ្តល់នូវមូលដ្ឋានច្បាស់លាស់សម្រាប់ការពិនិត្យ និងសម្រេចចិត្តលើយន្តការដែលត្រូវដាក់ចេញសម្រាប់ក្របខ័ណ្ឌនិម្មាបនកម្មនេះ។


២.១. ទស្សនាទានពាក់ព័ន្ធនឹងប្រព័ន្ធអេកូឡូស៊ីឌីជីថល

ប្រព័ន្ធអេកូឡូស៊ីឌីជីថលនៅក្នុងឯកសារនិម្មាបនកម្មនេះ សំដៅលើអន្តរសកម្មរវាងអង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, កម្មវិធី, ទិន្នន័យ និងបច្ចេកវិទ្យា ដើម្បីបម្រើដល់ផលប្រយោជន៍អង្គភាព ក៏ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាំងមូល។

២.១.១. ប្រព័ន្ធអេកូឡូស៊ីឌីជីថល

ប្រព័ន្ធអេកូឡូស៊ីឌីជីថល សំដៅលើបណ្តាញស្មុគស្មាញ (Complex Network) នៃអន្តរសកម្មរវាងមនុស្ស ឬស្ថាប័ន, ធុរកិច្ច, ប្រព័ន្ធ ឬកម្មវិធី, ទិន្នន័យ និងបច្ចេកវិទ្យា និងការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីប្រព័ន្ធនេះ។ ជាទូទៅ គំរូនៃការរៀបចំប្រព័ន្ធនេះអាចបែងចែកជា ៣ ប្រភេទ ធំៗ ដែលរួមមាន (១)-ប្រព័ន្ធរួមធំតែមួយ (Traditional Monolithic System), (២)-ប្រព័ន្ធបែបម៉ូឌុល (Modular Monolith System) និង (៣)-ប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ (Decentralized Digital Ecosystem) (រូបភាពទី ១)។ គំរូទាំង ៣ នេះ មានលក្ខណៈពិសេស និងត្រូវបានប្រើប្រាស់តាមបរិការណ៍របស់ស្ថាប័នរៀងៗ ខ្លួន។

រូបភាពទី ១៖ ការប្រៀបធៀបប្រភេទនៃប្រព័ន្ធអេកូឡូស៊ីឌីជីថល



១)- ប្រព័ន្ធរួមធំតែមួយ៖ ជាប្រព័ន្ធរួមមួយ ដែលគ្រប់ការកសាង, ប្រតិបត្តិ, ថែទាំ និងអភិវឌ្ឍ ត្រូវធ្វើឡើងក្នុងប្រព័ន្ធរួមនេះ ដោយមិនមានការបែងចែកទៅតាមម៉ូឌុលឡើយ។ ប្រព័ន្ធប្រភេទនេះ ងាយស្រួលអភិវឌ្ឍ និងដាក់ឱ្យដំណើរការ នៅពេលដែលរចនាសម្ព័ន្ធ និងមុខងាររបស់ស្ថាប័ននៅមានចំនួនតិចតួច។ បន្ថែមពីនេះ ការប្រើប្រាស់ប្រព័ន្ធប្រភេទនេះ ផ្តល់ភាពងាយស្រួលក្នុងការសម្របសម្រួល និងគ្រប់គ្រង ដោយសារមិនតម្រូវឱ្យមានយន្តការធ្វើការឆ្លងអង្គភាពច្រើន។ យ៉ាងណាមិញ ប្រព័ន្ធប្រភេទនេះមានបញ្ហាមួយចំនួន ដូចជា ភាពលំបាកក្នុងការថែទាំ, កែសម្រួល និងបន្ថែមមុខងារច្រើន នៅពេលដែលប្រព័ន្ធត្រូវពង្រីកវិសាលភាព ព្រមទាំងការប្រឈមហានិភ័យខ្ពស់នៃការដួលមួយដួលទាំងអស់ ជាងគំរូប្រព័ន្ធដទៃទៀតក្នុងពេលប្រតិបត្តិការ។

២)- ប្រព័ន្ធបែបម៉ូឌុល៖ ជាប្រព័ន្ធមួយដែលវិឌ្ឍចេញពីប្រព័ន្ធរួមធំតែមួយ ដើម្បីដោះស្រាយចំណុចខ្វះខាតមួយចំនួនរបស់ប្រព័ន្ធរួមធំតែមួយ ជាពិសេសភាពលំបាកក្នុងការកែសម្រួល និងបន្ថែមមុខងារច្រើន នៅពេលដែលប្រព័ន្ធត្រូវពង្រីកវិសាលភាព។ ប្រព័ន្ធបែបម៉ូឌុលអាចដោះស្រាយភាពលំបាកក្នុងការកែសម្រួលប្រព័ន្ធ តាមរយៈការបង្កើតជាម៉ូឌុលតូចៗ ដែលមានមុខងារឯករាជ្យពីម៉ូឌុលដទៃទៀត។ ការណ៍នេះ នឹងមិនធ្វើឱ្យមានភាពលំបាកក្នុងការកែសម្រួលប្រព័ន្ធ នៅពេលដែលម៉ូឌុលថ្មីណាមួយត្រូវបានបង្កើតឡើង ឬនៅពេលដែលម៉ូឌុលណាមួយត្រូវធ្វើបច្ចុប្បន្នភាព។ យ៉ាងណាមិញ ការប្រើប្រាស់ប្រព័ន្ធប្រភេទនេះ ក៏ផ្តល់នូវបញ្ហាធំៗ ចំនួន ៣ ផងដែរ រួមាន (១)- ភាពឯករាជ្យរបស់ម៉ូឌុលនីមួយៗ នៅមានកម្រិត, (២)- ភាពស្មុគស្មាញនៅក្នុងការពង្រីកវិសាលភាពនៃប្រព័ន្ធ និង (៣)-ភាពស្មុគស្មាញក្នុងការធ្វើតេស្តនៅក្នុងប្រព័ន្ធ។

៣)- ប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ៖ ផ្ទុយពីប្រព័ន្ធទាំង ២ ខាងលើ ប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ ត្រូវបានរៀបចំឡើងដោយអនុញ្ញាតឱ្យប្រព័ន្ធបច្ចេកវិទ្យារបស់អង្គភាពនីមួយៗ អាចដំណើរការបានដោយឯករាជ្យ និងមានអន្តរប្រតិបត្តិការជាមួយគ្នាទៅវិញទៅមកជាប្រព័ន្ធអេកូឡូស៊ីតែមួយ។ ជាទូទៅ ប្រព័ន្ធប្រភេទនេះត្រូវបានប្រើប្រាស់នៅក្នុងស្ថាប័នដែលមានរចនាសម្ព័ន្ធធំ មានអង្គភាពក្រោមចំណុះច្រើន។ ប្រព័ន្ធប្រភេទនេះផ្តល់អត្ថប្រយោជន៍ ក៏ដូចជាដោះស្រាយនូវបញ្ហាដែលអាចកើតឡើងនៅពេលប្រើប្រាស់ប្រព័ន្ធរួមធំតែមួយ និងប្រព័ន្ធបែបម៉ូឌុល។ អត្ថប្រយោជន៍ទាំងនោះ មានដូចជា បង្កើនភាពងាយស្រួលដល់ការគ្រប់គ្រង និងកែសម្រួល ឬបន្ថែមមុខងារផ្សេងៗ របស់ប្រព័ន្ធនៅតាមអង្គភាពនីមួយៗ, កំណត់ពីសិទ្ធលើការប្រើប្រាស់ និងគ្រប់គ្រងទិន្នន័យបានជាក់លាក់, និងកាត់បន្ថយការប្រឈមនូវហានិភ័យនៃការដួលមួយដួលទាំងអស់ ដោយសារភាពដាច់ដោយឡែកពីគ្នាពីប្រព័ន្ធមួយទៅប្រព័ន្ធមួយ។ យ៉ាងណាមិញ ប្រព័ន្ធប្រភេទនេះ ក៏មានបញ្ហាមួយចំនួន ដែលរួមមានដូចជា ការលំបាកក្នុងការសម្រប-សម្រួលលើយន្តការការងាររវាងអង្គភាពនីមួយៗ ក៏ដូចជាការធ្វើសន្ទានកម្ម និងធ្វើអន្តរប្រតិបត្តិការរវាងប្រព័ន្ធ និងប្រព័ន្ធ។ ការណ៍នេះ ទាមទារឱ្យមានការរៀបចំក្របខ័ណ្ឌអន្តរប្រតិបត្តិការ ក៏ដូចជាយន្តការការងារក្នុងការដឹកនាំ និងសម្របសម្រួលច្បាស់លាស់។

ត្បិតថាប្រព័ន្ធបែបអេកូឡូស៊ីមានបច្ចុប្បន្នអវិជ្ជមានមួយចំនួន, ប្រព័ន្ធប្រភេទនេះកំពុងក្លាយជាជម្រើសពេញនិយមសម្រាប់ស្ថាប័នដែលមានប្រព័ន្ធធំៗ ច្រើន ជាពិសេសចំពោះស្ថាប័នដែលមានរចនាសម្ព័ន្ធធំ មានអង្គភាពចំណុះ និងមានមុខងារច្រើន។ ប្រទេសមួយចំនួន បាន និងកំពុងប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការនេះ សម្រាប់ការគ្រប់គ្រងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យារបស់រាជរដ្ឋាភិបាលខ្លួន

ដែលរួមមានដូចជា សហរដ្ឋអាមេរិក, សិង្ហបុរី, កូរ៉េខាងត្បូង, កាណាដា, អូស្ត្រាលី និងចក្រភពអង់គ្លេស ជាដើម។ ក្រុមហ៊ុនអន្តរជាតិធំៗ ជាច្រើន ដូចជា Amazon, Netflix និង Spotify ក៏បាន និងកំពុងប្រើប្រាស់ប្រព័ន្ធប្រភេទនេះផងដែរ។ សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្នុងចំណោមប្រភេទទាំង ៣, ប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ មានភាពសមស្របសម្រាប់ការប្រើប្រាស់ ដោយផ្អែកលើស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់ប្រព័ន្ធ, រចនាសម្ព័ន្ធស្ថាប័ន ព្រមទាំងចក្ខុវិស័យវែងឆ្ងាយក្នុងការរួមចំណែកដល់ការធ្វើបវិត្តកម្មឌីជីថល។

២.១.២. និម្មាបនកម្មសហគ្រាស


និម្មាបនកម្មសហគ្រាស (Enterprise Architecture) ជាក្របខ័ណ្ឌទស្សនាទាន ក៏ដូចជាផែនទីមគ្គទេសក៍សម្រាប់រៀបចំកែសម្រួលមុខងារ និងយន្តការប្រតិបត្តិការរបស់តួអង្គពាក់ព័ន្ធទាំងអស់របស់ស្ថាប័ន ក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលមានភាពធំសំពីងសំពោង និងមានអន្តរសកម្មច្រើន ដើម្បីអាចសម្រេចគោលបំណងរបស់ស្ថាប័នដោយប្រសិទ្ធភាព។ សហគ្រាសនៅក្នុងនិម្មាបនកម្មសហគ្រាស សំដៅដល់បណ្តុំរបស់អង្គភាពនៅក្នុងស្ថាប័ន ទាំងនៅក្នុងវិស័យឯកជន និងវិស័យសាធារណៈ ដែលមានគោលដៅរួមក្នុងការបម្រើដល់ប្រយោជន៍ស្ថាប័ន។ ការអនុវត្តតាមនិម្មាបនកម្មសហគ្រាសនឹងធានាថា គ្រប់តួអង្គពាក់ព័ន្ធទាំងនោះ នឹងធ្វើការរៀបចំ, អភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន ស្របតាមគោលការណ៍ និងស្តង់ដាដែលបានកំណត់ ព្រមទាំងធានាថាប្រព័ន្ធនីមួយៗ អាចធ្វើអន្តរប្រតិបត្តិការជាមួយគ្នាបានដោយរហូត។ បន្ថែមពីនេះ និម្មាបនកម្មសហគ្រាស ក៏កំណត់ពីទំនាក់ទំនងច្បាស់លាស់រវាងបណ្តាញតភ្ជាប់, ហាដវែរ ដែលមានម៉ាស៊ីនមេ និងឧបករណ៍បច្ចេកវិទ្យាព័ត៌មានដទៃទៀត, កម្មវិធី និងទិន្នន័យ ដើម្បីបង្កើនប្រសិទ្ធភាពនៃមុខងាររបស់ស្ថាប័ន និងកាត់បន្ថយថ្លៃចំណាយផ្សេងៗ ដែលមិនចាំបាច់។

គួរគូសរំលេចផងដែរថា និម្មាបនកម្មសហគ្រាស មិនមែនជាប្រធានបទ ឬពាក្យថ្មីដែលទើបត្រូវបានបង្កើតនោះទេ។ និម្មាបនកម្មសហគ្រាសនេះ ត្រូវបានប្រើប្រាស់អស់រយៈពេលច្រើនជាង ៥០ ឆ្នាំ និងបានឆ្លងកាត់ ៣ ដំណាក់កាលរួចមកហើយ តាមការវិវឌ្ឍនៃបច្ចេកវិទ្យា។ និម្មាបនកម្មសហគ្រាស ត្រូវបានយកទៅប្រើប្រាស់កាលពីដំបូងនៅក្នុងក្រុមហ៊ុនធំៗ ដូចជា ក្រុមហ៊ុន IBM, ក្រុមហ៊ុន Coca Cola និងក្រុមហ៊ុនជីកប្រេង ជាដើម។ បន្ទាប់មក រដ្ឋាភិបាលនៃប្រទេសមួយចំនួនដូចជា សហរដ្ឋអាមេរិក, សិង្ហបុរី, កូរ៉េខាងត្បូង, កាណាដា, អូស្ត្រាលី, ចក្រភពអង់គ្លេស ជាដើម បានចាប់ផ្តើមប្រើប្រាស់និម្មាបនកម្មសហគ្រាស ក្នុងការគ្រប់គ្រង និងរៀបចំប្រព័ន្ធបច្ចេកវិទ្យារបស់ខ្លួន ដើម្បីធានាដល់ប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងការសម្រេចនូវបេសកកម្ម ក៏ដូចជាគោលដៅរបស់ខ្លួន។

នៅក្នុងការវិវឌ្ឍចុងក្រោយ និម្មាបនកម្មសហគ្រាស ត្រូវបានចែកចេញជា ៤ ស្រទាប់ គឺ (១)-**ស្រទាប់មុខងារធុរកិច្ច** (Business Layer) ដែលកំណត់ពីគោលបំណង និងគោលដៅរបស់ស្ថាប័ន (២)-**ស្រទាប់ទិន្នន័យ** (Data Layer) ដែលកំណត់ពីការរៀបចំក្របខ័ណ្ឌអភិបាលកិច្চទិន្នន័យ ដើម្បីគ្រប់គ្រង, ចែករំលែក និងធ្វើសន្ធានកម្មទិន្នន័យគ្រប់ប្រព័ន្ធពាក់ព័ន្ធ, (៣)-**ស្រទាប់ប្រព័ន្ធ និងកម្មវិធី** (Application Layer) ដែលកំណត់ពីការអភិវឌ្ឍ, ការដាក់ដំណើរការ និងការគ្រប់គ្រងប្រព័ន្ធ និងកម្មវិធី ដើម្បីធានាឲ្យបានការប្រើប្រាស់មុខងាររួម និងអន្តរប្រតិបត្តិការជាមួយគ្នា និង (៤)-**ស្រទាប់បច្ចេកវិទ្យា** (Technology Layer) ដែលកំណត់ពីហេដ្ឋារចនាសម្ព័ន្ធ, បណ្តាញ, មជ្ឈមណ្ឌលទិន្នន័យ

(Data Center) និងប្រតិបត្តិការសន្តិសុខឌីជីថល។ ស្រទាប់ទាំង ៤ នេះជាស្រទាប់គោល ខណៈដែលស្ថាប័នដែលបានយកនិម្មាបនកម្មនេះទៅប្រើប្រាស់អាចធ្វើការកែសម្រួល ឬបន្ថែមសមាសភាគសំខាន់ៗ បន្ថែមទៀតចូលទៅតាមស្រទាប់នីមួយៗ អាស្រ័យតាមស្ថានភាពជាក់ស្តែង។ ការណ៍នេះ បានបង្ហាញឱ្យឃើញនូវភាពបត់បែននៃនិម្មាបនកម្មសហគ្រាស សម្រាប់ស្ថាប័នប្រើប្រាស់ឱ្យស្របតាមស្ថានភាព និងបរិការណ៍ខ្លួន។ រូបភាពទី ២ ខាងក្រោមបង្ហាញពីស្រទាប់ទាំង ៤ នៃនិម្មាបនកម្មសហគ្រាស។

រូបភាពទី ២៖ ទំនើបកម្មចុងក្រោយនៃនិម្មាបនកម្មសហគ្រាស




បើប្រៀបធៀបជាមួយទីក្រុង, និម្មាបនកម្មសហគ្រាសប្រៀបបានទៅនឹងផែនការមេសម្រាប់អភិវឌ្ឍទីក្រុងមួយទាំងមូល ដែលតម្រូវឱ្យមានការរៀបចំនិម្មាបនកម្មជាក់លាក់សម្រាប់ការកសាងរចនាសម្ព័ន្ធផ្សេងៗ ដែលរួមមានដូចជា ផ្លូវ, ប្រព័ន្ធលូ, ប្រព័ន្ធទឹក, បណ្តាញអគ្គីសនី និងប្លង់ (Layout) សម្រាប់ទីក្រុងទាំងមូល ព្រមទាំងប្រភេទនៃមុខងារ និងសេវានៃតំបន់នីមួយៗ នៅក្នុងទីក្រុង។ ជាទូទៅ ទីក្រុងអាចត្រូវបែងចែកជា ៤ ផ្នែកធំៗ ដែលរួមមាន ១)-តំបន់, ២)-សមត្ថភាពមនុស្ស និងសម្ភារប្រើប្រាស់, ៣)-អគារ (Physical Building) និង ៤)-រចនាសម្ព័ន្ធ ដូចជា បណ្តាញផ្លូវ, ប្រព័ន្ធលូ, ប្រព័ន្ធទឹក និងបណ្តាញអគ្គីសនី ជាដើម។

២.២. ការសិក្សាពីបច្ចុប្បន្នភាពនៃប្រព័ន្ធអេកូឡូស៊ីឌីជីថល

ក្នុងដើមឆ្នាំ ២០២៤ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងប្រព័ន្ធអេកូឡូស៊ីនេះ មានចំនួនសរុបប្រមាណជា ២០០ ប្រព័ន្ធ ដែលបាន និងកំពុងរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញការធ្វើបរិវត្តកម្ម និងស្វ័យប្រវត្តិកម្មការងារឱ្យបានជាអតិបរមា។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់នេះ ក៏អាចធ្វើការបែងចែកទៅតាមមុខងារធំៗ ទាំង ៦ ដែលមានដូចជា (១)-ការគ្រប់គ្រងចំណូល, (២)-ការអនុវត្តចំណូល-ចំណាយ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យនៃថវិការដ្ឋ, (៣)-ការវិនិយោគសាធារណៈ, (៤)-ឧស្សាហកម្មហិរញ្ញវត្ថុ, (៥)-រដ្ឋបាល, ធនធានមនុស្ស, សារពើភណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ និងសេវាសាធារណៈ និង (៦)-ម៉ាក្រូសេដ្ឋកិច្ច, សវនកម្ម និងអធិការកិច្ច។ រូបភាពទី ៣ ខាងក្រោមបង្ហាញពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបម្រើមុខងារស្នូលតាមអង្គភាព ដោយបែងចែកតាមមុខងារនៃប្រព័ន្ធទាំងនោះ។

រូបភាពទី ៣៖ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបែងចែកតាមមុខងារ



ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់ ក៏អាចធ្វើការបែងចែកទៅជា ២ ក្រុម ដែលរួមមាន សំណុំនៃប្រព័ន្ធបច្ចេកវិទ្យាបម្រើដល់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងសំណុំនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀត ដែលការផ្គុំគ្នានៃសំណុំទាំងពីរត្រូវបានកំណត់ថាជា "**ប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃការគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**"។

ក. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management Reform Program – PFMRP) ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ដោយ ពោលគឺចាប់តាំងពីឆ្នាំ ២០០៤ រហូតមកទល់ពេលនេះ ដោយបែងចែកជា ៤ ដំណាក់កាល។ ដំណាក់កាលទី ១ បានចាប់ផ្តើមនៅឆ្នាំ ២០០៤ ដោយផ្តោតលើ "ការកសាងភាពជឿទុកចិត្តនៃថវិកា" ដែលបានអនុវត្តរហូតដល់ឆ្នាំ ២០០៨ ដោយសម្រេចបាននូវលទ្ធផលគន្លឹះជាមូលដ្ឋាន សម្រាប់ដំណើរទៅកាន់ដំណាក់កាលបន្តបន្ទាប់។ ដំណាក់-កាលទី ២ បានចាប់ផ្តើមនៅឆ្នាំ ២០០៩ ដោយផ្តោតលើ "ការកសាងគណនេយ្យភាពហិរញ្ញវត្ថុ" ដោយដំបូងបានកំណត់យកផែនការសកម្មភាពរយៈពេល ៥ ឆ្នាំ និងបានបន្ថែមរយៈពេល ២ ឆ្នាំបន្ថែមទៀតសម្រាប់អនុវត្ត។ បន្ទាប់ពីបានវាយតម្លៃលើការអនុវត្តរយៈពេល ៧ ឆ្នាំ ក្នុងដំណាក់ទី ២ រួចមក, រាជរដ្ឋា-ភិបាលសម្រេចចាប់ផ្តើមអនុវត្តដំណាក់កាលទី ៣ ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២២ ដោយផ្តោតលើ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"។ ផ្អែកលើសមិទ្ធផលក្នុងរយៈពេលជិត ២០ ឆ្នាំ នៃការអនុវត្តទាំង ៣ ដំណាក់កាល, រាជរដ្ឋាភិបាលមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការអនុវត្តដំណាក់កាលទី ៤ ដោយផ្តោតលើ "គណនេយ្យភាពសមិទ្ធកម្ម" ដែលបានប្រកាសដាក់ឱ្យអនុវត្តកាលពីខែ មីនា ឆ្នាំ ២០២៣ កន្លងទៅនេះ។ ក្នុងការអនុវត្តកម្មវិធីនេះ បច្ចេកវិទ្យាត្រូវបានចាត់ទុកថាជាឧបករណ៍គន្លឹះសម្រាប់ជំរុញដល់ការធ្វើស្ងួយប្រវត្តិកម្មការងារ និងបង្កើនប្រសិទ្ធភាពការងារ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើនត្រូវបានអភិវឌ្ឍ និងប្រើប្រាស់នៅតាមអង្គភាព បម្រើដល់ការងារស្នូល និងប្រតិបត្តិការរបស់អង្គភាពទាំងនោះ។

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System – FMIS) គឺជាប្រព័ន្ធស្ងួយប្រវត្តិកម្ម និងសមាហរណកម្ម នូវដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាលកម្ពុជា ដែលរួមមាន ការរៀបចំនិងអនុវត្តថវិកា, ប្រតិបត្តិការហិរញ្ញវត្ថុ, ការរៀបចំរបាយការណ៍, ការធ្វើអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្ម ជាដើម។ FMIS គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដ៏សំខាន់មួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការជួយបង្កើតនូវតម្លាភាព និងគណនេយ្យភាពហិរញ្ញវត្ថុនៅគ្រប់ដំណាក់កាលវដ្តនៃថវិកា រួមមាន (១)-ដំណាក់កាលរៀបចំថវិកា (ការរៀបចំផែនការចំណូល-ចំណាយថវិកា) (២)-ដំណាក់កាលអនុវត្តថវិកា (ការស្នើសុំធានាចំណាយថវិកា, ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ, ការទូទាត់ថវិកា, ការអនុវត្តចំណូលថវិកា) និង (៣)-ដំណាក់កាលតាមដាន និងវាយតម្លៃការអនុវត្តថវិកា (តាមរយៈរបាយការណ៍នៃការអនុវត្តថវិកាតាមចំណាត់ថ្នាក់ទាំង៧ គឺ ចំណាត់ថ្នាក់សេដ្ឋកិច្ច, ចំណាត់ថ្នាក់រដ្ឋបាល, ចំណាត់ថ្នាក់កម្មវិធី, ចំណាត់ថ្នាក់មូលនិធិ, ចំណាត់ថ្នាក់គម្រោង, ចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់ភូមិសាស្ត្រ និងរបាយការណ៍សមិទ្ធកម្ម) ព្រមទាំងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យនៃថវិការដ្ឋ។ ក្រៅពីនេះ FMIS ត្រូវបានប្រើប្រាស់សម្រាប់ជំនួយដល់ការរៀបចំម៉ាក្រូសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌថវិការយៈពេលមធ្យម (Medium-Term Budget Framework – MTBF), ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (Medium-Term Fiscal

Framework – MTFF) និងការព្យាករណ៍ស្ថានភាពថវិកា ។ ក្នុងពេលបច្ចុប្បន្ននេះ FMIS ក៏ត្រូវបាន ប្រើប្រាស់ក្នុងការធ្វើអធិការកិច្ច និងសវនកម្មដោយអាជ្ញាធរសវនកម្មជាតិ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអគ្គាធិការដ្ឋាន ជាដើម។


យោងតាមមាត្រាទី ១៣ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលបានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣, ការគ្រប់គ្រង, រៀបចំ, អនុវត្ត, តាមដាន, និងត្រួតពិនិត្យលើការអនុវត្តចំណូល និងចំណាយថវិការដ្ឋ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យនៃថវិការដ្ឋ ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវប្រើប្រាស់ និងឆ្លុះបញ្ចាំងក្នុង FMIS តែមួយគត់។ បច្ចុប្បន្ន FMIS មានមុខងារដូចជា មុខងាររៀបចំផែនការថវិកា, មុខងារវិភាជន៍ថវិកា, មុខងារទិញ, មុខងារលទ្ធកម្មពេញលេញ, មុខងារគណនីត្រូវទារ, មុខងារគណនីត្រូវសង, មុខងារគ្រប់គ្រងសាច់ប្រាក់, មុខងារសៀវភៅធំ និងមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងគ្រប់គ្រងសន្និធិ ជាដើម។

ទោះជាយ៉ាងនេះក្តី មកទល់ពេលនេះ ក្នុងចំណោមមុខងារដែលបានរៀបរាប់ខាងលើនេះ, FMIS នៅមិនទាន់បានអភិវឌ្ឍមុខងារទាំងនោះឱ្យបានពេញលេញនៅឡើយទេ។ ក្នុងនោះ មុខងារគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានអភិវឌ្ឍដាច់ដោយឡែក និងគ្រប់គ្រងដោយអគ្គនាយកដ្ឋានទ្រព្យ-សម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ដែលប្រព័ន្ធនោះឈ្មោះថា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (State Asset Register Management Information System – SARMIS)។ សម្រាប់មុខងារគ្រប់គ្រងសន្និធិ ក៏នៅមិនទាន់បានអភិវឌ្ឍនៅឡើយទេ។ ស្របតាមលក្ខខណ្ឌបច្ចេកទេស ដើម្បីអាចធ្វើសន្ទានកម្ម FMIS ជាមួយនឹងប្រព័ន្ធ SARMIS បាន, FMIS ចាំបាច់ត្រូវបើកដំណើរការនូវមុខងារគ្រប់គ្រងទ្រព្យសម្បត្តិ (Asset Management Module) ដែលនឹងក្លាយជាម៉ូឌុលថ្មីមួយនៅក្នុង FMIS ។ ប៉ុន្តែ ការបើកដំណើរការនូវមុខងារថ្មីនេះ សម្រាប់តែប្រើប្រាស់លើមុខងារមួយចំនួនប៉ុណ្ណោះ ខណៈដែលមុខងារដែលមាននៅក្នុងប្រព័ន្ធ SARMIS គឺជាមុខងារសម្រាប់ក្រសួងស្ថាប័នប្រើប្រាស់ក្នុងការចុះបញ្ជី និងគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

ក្រៅពី FMIS, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀត ជាប្រព័ន្ធរណប និងដើរតួយ៉ាងសំខាន់ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដូចគ្នា ដែលក្នុងនោះរួមមាន ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ, ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (Automated System for Customs Data – ASYCUDA) របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-tax Revenue Management Information System – NRMIS), ប្រព័ន្ធគ្រប់គ្រងបំណុល និងវិភាគហិរញ្ញវត្ថុ (Debt Management and Financial Analysis System – DMFAS) របស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលជាដើម។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់មានតួនាទីសំខាន់រៀងៗ ខ្លួន និងបំពេញមុខងាររបស់ខ្លួនដើម្បីធានាបាននូវប្រព័ន្ធអេកូឡូស៊ីមួយដែលមានភាពរស់រវើក។ FMIS ក៏បាន និងកំពុងធ្វើសន្ទានកម្មជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធផ្សេងទៀតដូចជា ការធ្វើសន្ទានកម្មរបាយការណ៍ធនាគារជាមួយធនាគារជាតិ និងធនាគារពាណិជ្ជ, ការធ្វើសន្ទានកម្មជាមួយប្រព័ន្ធ DMFAS, ប្រព័ន្ធ ASYCUDA, ប្រព័ន្ធ NRMIS, ប្រព័ន្ធគ្រប់គ្រងប្រាក់បៀវត្សមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ និងប្រព័ន្ធពាក់ព័ន្ធមួយចំនួនទៀត។

បណ្តុំនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមាននៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងអស់នេះត្រូវបានផ្តល់នូវឈ្មោះផ្សេងៗ គ្នា។ ជាក់ស្តែង ឯកសាររបស់ធនាគារពិភពលោក បានហៅបណ្តុំនៃប្រព័ន្ធទាំងនោះថា "ការរួមបញ្ចូលគ្នានៃប្រព័ន្ធ FMIS (Integrated FMIS)"។ ចំណែកក្នុងរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានចុះមកសិក្សាវាយតម្លៃពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានហៅបណ្តុំនៃប្រព័ន្ធទាំងនោះថា "ប្រព័ន្ធអេកូឡូស៊ីឌីជីថល នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM Digital Ecosystem)"។ ផ្អែកតាមការកំណត់ទាំងនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** បានណែនាំ និងកំណត់នូវពាក្យសម្រាប់ហៅបណ្តុំនេះថា "**ការរួមបញ្ចូលគ្នានៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Integrated PFM Information System – I-PFMIS)**"។ រូបភាពទី ៤ ខាងក្រោមបង្ហាញពីទិដ្ឋភាពនៃការរួមបញ្ចូលគ្នានៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

រូបភាពទី ៤៖ ការរួមបញ្ចូលគ្នានៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



GL: General Ledger (មុខងារសៀវភៅធំ)
BA: Budget Allocation (មុខងារវិភាជន៍ថវិកា)
BP: Budget Planning (មុខងាររៀបចំផែនការថវិកា)
PO: Purchasing Order (មុខងារទិញ)
AR: Account Receivable (មុខងារគណនីត្រូវទារ)
AP: Account Payable (មុខងារគណនីត្រូវសង)

CM: Cash Management (មុខងារគ្រប់គ្រងសាច់ប្រាក់)
e-GP: Electronic Government Procurement (មុខងាររៀបចំលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក)
AM: Asset Management (មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ)
IM: Inventory Management (មុខងារគ្រប់គ្រងសារពើភ័ណ្ឌ)

ខ. សំណុំនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀត

ក្រៅពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមាន FMIS និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀតដូចបានរៀបរាប់ខាងលើ, អគ្គនាយកដ្ឋាន និងអង្គភាពមួយចំនួនដែលស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏មានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់បម្រើដល់មុខងារស្នូលរបស់ខ្លួនផងដែរ។ ការងារក្នុងការវិនិយោគសាធារណៈ អាចបែងចែកទៅជាសំណុំនៃប្រព័ន្ធបច្ចេកវិទ្យាមួយផងដែរ ដែលមានអង្គភាពមួយចំនួនពាក់ព័ន្ធនៅក្នុងនោះ ដូចជា អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាដើម។ អង្គភាពទាំងនេះ ប្រើប្រាស់ប្រភពថវិកាផ្សេងគ្នាសម្រាប់ការវិនិយោគ ហើយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗ គ្នា ដើម្បីជួយសម្រួលដល់ការបំពេញមុខងាររបស់ខ្លួន។

នៅក្នុងសំណុំមួយទៀត ទាក់ទងទៅនឹងទិដ្ឋភាពការងារសំខាន់ដូចជា ការគ្រប់គ្រងទិន្នន័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច, ការធ្វើសវនកម្ម និងការធ្វើអធិការកិច្ច ក៏មានប្រព័ន្ធបច្ចេកវិទ្យាមួយចំនួនបម្រើដល់ការងារទាំងនោះដែរ។ អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល បាន និងកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អង្គភាពដែលមានតួនាទីលើការងារអធិការកិច្ច និងសវនកម្ម ក៏មានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់បំពេញការងារស្នូលរបស់ខ្លួនផងដែរ ឧទាហរណ៍ដូចជា អគ្គាធិការដ្ឋានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការងារអធិការកិច្ចហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រើប្រាស់ប្រព័ន្ធ SAAT ជាដើម។

សម្រាប់ការងារនៅក្នុងវិស័យឧស្សាហកម្មហិរញ្ញវត្ថុ, បច្ចុប្បន្នមានទិដ្ឋភាពសំខាន់ៗ ចំនួន ២ រួមមានទិដ្ឋភាពការងារក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងទិដ្ឋភាពការងារក្នុងវិស័យល្បែងពាណិជ្ជកម្ម។ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវបានបង្កើតឡើងដោយធ្វើសមាហរណកម្មយន្តការនៃការគ្រប់គ្រង និងការត្រួតពិនិត្យលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងគោលបំណងពង្រឹង និង ជានាប្រសិទ្ធភាពនៃការគ្រប់គ្រង, ការត្រួតពិនិត្យ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍ និងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលមាននិយ័តករក្រោមឱវាទចំនួន ៦ និងអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាសេនាធិការ។ ក្នុងនោះ និយ័តករទាំង ៦ រួមទាំងអគ្គលេខាធិការដ្ឋាន មានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនកំពុងតែប្រតិបត្តិតាមវិស័យរបស់ខ្លួន ដែលរួមមានដូចជា ប្រព័ន្ធគ្រប់គ្រងទិន្នន័យ, ប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យ និងប្រព័ន្ធបច្ចេកវិទ្យានិយ័តកម្ម ជាដើម។


សម្រាប់ការផ្តល់សេវាសាធារណៈ, អគ្គនាយកដ្ឋាន និងអង្គភាពដែលមានតួនាទី និងការកិច្ចលើការងារនេះ បាន និងកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាមួយចំនួនដូចជា ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX), ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា (CamDigiKey), ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់លិខិតអនុញ្ញាត និងផ្តល់អាជ្ញាបណ្ណ មួយចំនួនទៀតផងដែរ។ អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ក៏មានមុខងារ និងប្រព័ន្ធមួយចំនួនដែលបម្រើដល់ការងារផ្តល់សេវាសាធារណៈ តាមរយៈការផ្តល់លិខិតអនុញ្ញាត និងផ្តល់អាជ្ញាបណ្ណផងដែរ។

ប្រព័ន្ធបច្ចេកវិទ្យាមួយចំនួន មានលក្ខណៈជាប្រព័ន្ធដែលបម្រើមុខងាររួម លើទិដ្ឋភាពការងារមួយចំនួនដូចជា ការងាររដ្ឋបាល, ការគ្រប់គ្រងបុគ្គលិក និងមន្ត្រី, ការគ្រប់គ្រងបញ្ជីសារពើភណ្ឌ, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការបណ្តុះបណ្តាល, ការតាមដាន និងវាយតម្លៃ ជាដើម។ បន្ថែមពីលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបានរៀបរាប់ខាងលើ នៅមានប្រព័ន្ធបច្ចេកវិទ្យាមួយចំនួនទៀត ដូចជា ថ្នាលធុរកិច្ចថ្មីកម្ពុជា, ថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស, ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ, ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក ជាដើម។

គ. ប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទាំងសំណុំនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសំណុំនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀត អាចហៅបានថាជា "**ប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**"។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះត្រូវបានអភិវឌ្ឍ និងប្រតិបត្តិដាច់ដោយឡែកពីគ្នា ហើយមួយចំនួនមានលទ្ធភាពក្នុងការធ្វើអន្តរប្រតិបត្តិការជាមួយគ្នាទៅវិញទៅមក ខណៈមួយចំនួនទៀត នៅមិនទាន់អាចធ្វើបាននៅឡើយ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់មានតួនាទី និងមុខងារសំខាន់រៀងៗ ខ្លួន និងបានរួមចំណែកយ៉ាងសំខាន់ តាមរយៈការបង្កើនប្រសិទ្ធភាពដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាគោលបំណងគោលនយោបាយធំទាំង ២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រូបភាពទី ៥ ខាងក្រោមបង្ហាញពីប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រូបភាពទី ៥៖ ប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



២.៣. បញ្ហាប្រឈមនៃប្រព័ន្ធអេកូឡូស៊ីឌីជីថល

ដូចបង្ហាញក្នុងរូបភាពទី ៥ ខាងលើ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗ នៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបែងចែកជា ២ ក្រុមធំៗ ដែលស្របទៅតាមគោលបំណងនៃគោលនយោបាយទាំង ២ ។ ក្នុងន័យនេះ បើធ្វើការប្រៀបធៀបប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅនឹងប្រព័ន្ធព្រះអាទិត្យ, ប្រព័ន្ធនេះមានភពច្រើន ហើយភពនីមួយៗ មានតួនាទីរៀងខ្លួន និងរណបគ្នាទៅវិញទៅមក ដើម្បីរក្សាស្ថិរភាពប្រព័ន្ធព្រះអាទិត្យទាំងមូល។ ផ្អែកតាមការពិនិត្យលើស្ថានភាពប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ដំណើរនៃការធ្វើបរិវត្តកម្មឌីជីថល បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជា៖

១)- ធនធានមនុស្សនៅមានកម្រិត ទាំងចំនួន និងជំនាញបច្ចេកទេស ដើម្បីគាំទ្រដល់ការងារអភិវឌ្ឍ, ប្រតិបត្តិ និងថែទាំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ តម្រូវការនៃការប្រើប្រាស់ធនធានមនុស្ស ពីអង្គភាពមួយទៅអង្គភាពមួយមានភាពខុសៗ គ្នា អាស្រ័យទៅតាមលក្ខខណ្ឌ និងតម្រូវការមួយចំនួនដូចជា តម្រូវការសម្រាប់ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដោយខ្លួនឯង, តម្រូវការសម្រាប់ការអភិវឌ្ឍប្រព័ន្ធដោយខ្លួនឯង, តម្រូវការនៃការប្រតិបត្តិការប្រព័ន្ធ ជាដើម ព្រមទាំងទិសដៅនៃការធ្វើការដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា

ព័ត៌មាន។ ក្នុងន័យនេះ កង្វះនូវគោលការណ៍ ឬការណែនាំច្បាស់លាស់លើការជ្រើសរើស និងប្រើប្រាស់ធនធានមនុស្ស នាំឱ្យរាំងស្ទះដល់ដំណើរការការងារដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

២)- ការវិនិយោគ និងការគាំទ្រថវិកាលើការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅមានកម្រិត និងមិនទាន់មានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់នៅឡើយ។ ប្រព័ន្ធមួយចំនួន ដែលបម្រើលើមុខងារដូចគ្នា ឬប្រហាក់ប្រហែលគ្នា ត្រូវបានអភិវឌ្ឍជាន់គ្នា ដែលបណ្តាលឱ្យខ្ជះខ្ជាយធនធានក្នុងការវិនិយោគ ខណៈដែលប្រព័ន្ធទាំងនោះអាចប្រើប្រាស់ជាប្រព័ន្ធដែលបម្រើមុខងាររួមបាន។ ការគាំទ្រថវិកា ក៏ហាក់នៅមានទំនោរ និងតម្រង់ទៅតែលើអង្គភាព ឬប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនច្រើនលើសលប់ ខណៈអង្គភាព ឬប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនទៀតនៅតែខ្វះខាតការគាំទ្រច្រើន ដើម្បីអាចបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

៣)- ទិន្នន័យនៅមានភាពរាយប៉ាយ និងមិនមានស្តង់ដា ហើយការចែករំលែកទិន្នន័យទៅវិញទៅមកនៅមានកម្រិតនៅឡើយ រវាងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការចែករំលែកទិន្នន័យភាគច្រើននៅតែមិនទាន់អាចធ្វើបានដោយស្វ័យប្រវត្តិរវាងប្រព័ន្ធ និងប្រព័ន្ធបាន ដោយសារតែកង្វះនូវក្របខ័ណ្ឌអន្តរប្រតិបត្តិការ។ កង្វះនូវក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ក៏ជាបច្ច័យអវិជ្ជមានដល់ការប្រើប្រាស់ និងចែករំលែកទិន្នន័យ សម្រាប់ប្រើប្រាស់ជារួមផងដែរ។

៤)- កង្វះខាតនូវគោលការណ៍ស្តង់ដារួមសម្រាប់ការអភិវឌ្ឍប្រព័ន្ធ បណ្តាលឱ្យជួបប្រទះនូវផលវិបាក ក្នុងការថែទាំ និងពង្រីកវិសាលភាពប្រព័ន្ធនោះ។ ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានភាគច្រើនធ្វើទៅតាមតម្រូវការ និងធនធានដែលមាន ដោយមិនទាន់បានកំណត់នូវគោលការណ៍ស្តង់ដានៃការអភិវឌ្ឍឱ្យបានច្បាស់លាស់។ កង្វះខាតនូវគោលការណ៍ស្តង់ដារួម បានធ្វើឱ្យប្រព័ន្ធទាំងនោះអាចនឹងជួបនូវបញ្ហាប្រឈមមួយចំនួននៅពេលដែលចង់ធ្វើការភ្ជាប់គ្នារវាងប្រព័ន្ធ និងប្រព័ន្ធ។ ជាងនេះទៀត ប្រសិទ្ធភាពនៃការធានានូវសន្តិសុខសាយប័រក៏ជាបញ្ហាប្រឈមផងដែរ នៅពេលដែលការអភិវឌ្ឍប្រព័ន្ធនីមួយៗ មិនទាន់បានអនុលោមទៅតាមគោលការណ៍សុវត្ថិភាពបានត្រឹមត្រូវ។

៥)- ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងមជ្ឈមណ្ឌលទិន្នន័យ នៅមិនទាន់មានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់នៅឡើយ។ បច្ចុប្បន្ន អង្គភាពចំនួន ៤ ដែលមានលទ្ធភាពប្រតិបត្តិ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដោយខ្លួនឯង។ ទោះជាយ៉ាងនេះក្តី អគ្គនាយកដ្ឋានមួយចំនួនក៏នៅបន្តប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនដែលមាន ដោយមិនទាន់បានផ្លាស់ប្តូរមកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួមនៅឡើយ ដោយសារតែកង្វះខាតធនធានក្នុងការផ្លាស់ប្តូរ។ មួយវិញទៀត ការផ្តល់សេវាពីអគ្គលេខាធិការដ្ឋានក៏នៅមានកម្រិត ដោយសារតែចំនួនធនធាននៅខ្វះខាត និងមានចំនួនបុគ្គលិកតិច។

៦)- ការផ្លាស់ប្តូរវប្បធម៌ការងារនៅមានភាពយឺតយ៉ាវ ដោយសារការមិនបានត្រៀមខ្លួនក្នុងការចាប់យក និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការបំពេញការងារ របស់អង្គភាពមួយចំនួន។ ការណ៍នេះធ្វើឱ្យអង្គភាពដែលមានភាពយឺតយ៉ាវទាំងនោះ ហាក់មិនបានរួមចំណែកពេញលេញ នៅក្នុងដំណើរនៃការធ្វើបវិត្តកម្មឌីជីថល និងរាំងស្ទះដល់ដំណើរការការងារមួយចំនួន ដែលមានភាពប្រទាក់ក្រឡាគ្នា។

២.៤. សនិទានភាពនៃការរៀបចំក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងរួមចំណែកដល់ការធ្វើបរិវត្តកម្មឌីជីថលរបស់រាជរដ្ឋាភិបាល, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាំបាច់ត្រូវរៀបចំនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនឱ្យបានច្បាស់លាស់ និងសមស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ក៏ដូចជាបរិការណ៍របស់ខ្លួន។ និម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប្រៀបបានទៅនឹងប្លង់មេ និងគ្រឹះ សម្រាប់ការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងស្ថាប័នមួយ ហើយភាពចាំបាច់នៃការរៀបចំនិម្មាបនកម្មនេះ គឺផ្អែកលើហេតុផលសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

១)- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន មានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំនួន ២០០ ប្រព័ន្ធ រួមជាមួយនឹងចំនួនអង្គភាពច្រើន និងរចនាសម្ព័ន្ធសំពីងសំពោង ព្រមទាំងត្រូវធ្វើអន្តរប្រតិបត្តិការជាមួយគ្នាទៅវិញទៅមក លើដំណើរការការងារ។

២)- ឧត្តមានុវត្តន៍ និងបទពិសោធអន្តរជាតិ ព្រមទាំងការសិក្សារបស់មូលនិធិរូបិយវត្ថុអន្តរជាតិក្នុងឆ្នាំ ២០២៤ នៅកម្ពុជាបានបង្ហាញថា ការប្រើប្រាស់និម្មាបនកម្មក្នុងទម្រង់ជាប្រព័ន្ធអេកូឡូស៊ីបែបវិមជ្ឈការ គឺស្របទៅនឹងស្ថានភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន ដែលមានអង្គភាពក្រោមឱវាទ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានច្រើន។

៣)- រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធ ដូចជាក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥, គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨, យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ព្រមទាំងគោលនយោបាយ និងឯកសារយុទ្ធសាស្ត្រពាក់ព័ន្ធជាច្រើនទៀត។ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា បានកំណត់នូវគោលការណ៍ក្នុងការអនុវត្តរដ្ឋាភិបាលឌីជីថល ចំនួន ៣ សំខាន់ៗ រួមមាន (១)-គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក (The Only-Once Principle), (២)-គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ (Interoperability as an Ecosystem) និង (៣)-គោលការណ៍ផ្តួចផ្តើម និងពង្រីកដើម្បីប្រសិទ្ធភាព (Land and Expand for Efficiency) ។

៤)- ជានិន្នាការសកល ថ្នាលសំខាន់ធំៗ ចំនួន ៣ ត្រូវបានកំណត់ថាជាហេដ្ឋារចនាសម្ព័ន្ធឌីជីថលសាធារណៈ (Digital Public Infrastructure – DPI) ដែលក្នុងនោះរួមមាន ថ្នាលផ្លាស់ប្តូរទិន្នន័យ, ថ្នាលកំណត់អត្តសញ្ញាណឌីជីថល និងថ្នាលទូទាត់សងប្រាក់ឌីជីថល។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាមានថ្នាលសំខាន់ៗ ស្របតាមហេដ្ឋារចនាសម្ព័ន្ធឌីជីថលសាធារណៈ ដែលមានដូចជា ថ្នាល CamDX, ថ្នាល CamDigiKey, ប្រព័ន្ធទូទាត់សងប្រាក់បាគង និងថ្នាល verifiy.gov.kh ជាដើម។ ថ្នាលទាំងនេះ បានដើរតួនាទីជាថ្នាលគ្រឹះឌីជីថល ក្នុងការជួយសម្រួល ពន្លឿន និងទំនើបកម្មដំណើរការនៃការធ្វើការ និងការផ្តល់សេវារបស់ស្ថាប័នរដ្ឋ ព្រមទាំងអាចជួយបង្កើនប្រសិទ្ធភាពការងារប្រតិបត្តិការអាជីវកម្មរបស់វិស័យឯកជនផងដែរ។

២.៥. បច្ចុយវិជ្ជមាន

ស្របតាមបរិការណ៍បច្ចុប្បន្ននៃស្ថានភាពប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, បទពិសោធ និងឧត្តមានុវត្តន៍អន្តរជាតិ ព្រមទាំងអនុសាសន៍របស់ដៃគូអភិវឌ្ឍន៍, វត្តមាននៃថ្នាលឌីជីថលគ្រឹះ និងការចង្អុលបង្ហាញពីក្របខ័ណ្ឌគោលនយោបាយ, ការរៀបចំក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំឡើងក្នុងទម្រង់ជា **"និម្មាបនកម្មប្រព័ន្ធអេកូ-ឡូស៊ីឌីជីថលបែបវិមជ្ឈការ"**។ ការជ្រើសរើសយកនិម្មាបនកម្មប្រភេទនេះមកប្រើប្រាស់ នឹងផ្តល់បច្ច័យវិជ្ជមានមួយចំនួនដូចជា កំណត់ភាពជាម្ចាស់នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទិន្នន័យបានច្បាស់លាស់, បង្កើនការប្រើប្រាស់ទិន្នន័យឱ្យអស់ពីលទ្ធភាព, ផ្តល់សុវត្ថិភាពខ្ពស់ដល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, អនុញ្ញាតឱ្យប្រើប្រាស់ធនធានរួម និងប្រើធនធានបានត្រឹមត្រូវ ព្រមទាំងបង្កើនប្រសិទ្ធភាពការងារ និងនានុវត្តន៍។

ភាពជោគជ័យនៃការប្រើប្រាស់និម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ គឺទាមទារជាចាំបាច់នូវការកំណត់នូវមុខងាររបស់អង្គភាព, កំណត់ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ និងក្របខ័ណ្ឌអន្តរ-ប្រតិបត្តិការ, កំណត់នូវបច្ចេកវិទ្យាដែលអាចប្រើប្រាស់រួមក្នុងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកំណត់នូវការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ក្នុងន័យនេះ ការជ្រើសរើសយកនិម្មាបនកម្មសហគ្រាសមកប្រើប្រាស់ នឹងអនុញ្ញាតឱ្យការអភិវឌ្ឍ, ប្រតិបត្តិ, គ្រប់គ្រង និងថែទាំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានម៉ូដែលរួម និងច្បាស់លាស់មួយ។ និម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់នូវធាតុមួយចំនួន ស្របតាមនិម្មាបនកម្មសហគ្រាសដែលការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអាចផ្អែកលើដំណោះស្រាយដែលមានស្រាប់ ឬដំណោះស្រាយរួម។ ជាងនេះទៀត និម្មាបនកម្មនេះអនុញ្ញាតឱ្យមានការគ្រប់គ្រង និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានប្រកបដោយប្រសិទ្ធភាព។ ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ និងក្របខ័ណ្ឌអន្តរប្រតិបត្តិការក៏ជាចំណុចសំខាន់មិនអាចខ្វះបាន ដើម្បីអាចដោះស្រាយនូវបញ្ហាចាក់ស្រេះនៃការគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យ ក៏ដូចជាដើម្បីពង្រឹងនូវវប្បធម៌ការងារដោយប្រើប្រាស់ទិន្នន័យឱ្យបានច្រើន។

៣. ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

៣.១. គោលបំណង និងគោលដៅ

ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានគោលបំណង **"ធ្វើសុខដុមនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងទម្រង់ជាប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ សំដៅដល់ការធ្វើបរិវត្តកម្មឌីជីថល ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព"**។

ទន្ទឹមនេះ ក្របខ័ណ្ឌនេះមានគោលដៅ **"កំណត់មុខងាររបស់អង្គភាពលើការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, រៀបចំក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ, រៀបចំក្របខ័ណ្ឌអន្តរប្រតិបត្តិការ, កំណត់សេចក្តីណែនាំជាស្តង់ដាសម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងជំរុញការប្រើប្រាស់បច្ចេកវិទ្យា និងធនធានរួម"**។

៣.២. គោលការណ៍ និងអតិក្រម

ការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងទម្រង់ជាប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ អនុញ្ញាតឱ្យប្រព័ន្ធនីមួយៗ ដំណើរការបានដោយដោយឯករាជ្យ និងមានអន្តរប្រតិបត្តិការជាមួយគ្នាទៅវិញទៅមក ដើម្បីធានាបាននូវការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងស័ក្តសិទ្ធភាពខ្ពស់។ ក្របខ័ណ្ឌនេះ អនុញ្ញាតឱ្យមានការប្រើប្រាស់នូវហេដ្ឋារចនាសម្ព័ន្ធ ឬប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួមមួយចំនួនរបស់ក្រសួងដែលបានកសាង និងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្នឱ្យអស់លទ្ធភាព និងចៀសវាងនូវការវិនិយោគលើការអភិវឌ្ឍន្ថែម ឬស្ទួនគ្នាណាដែលមិនចាំបាច់។ ក្នុងន័យនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួន ដែលមានមុខងាររួម និងប្រើប្រាស់ដោយអង្គភាពជាច្រើនផ្សេងទៀត នៅតែបន្តប្រតិបត្តិ ហើយមិនអនុញ្ញាតឱ្យមានការបង្កើតប្រព័ន្ធដែលបម្រើមុខងារដូចគ្នានេះ នៅអង្គភាពផ្សេងទៀតឡើយ។

ដើម្បីឱ្យស្របជាមួយនឹងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥, ក្របខ័ណ្ឌនេះក៏នឹងអនុវត្តតាមគោលការណ៍សំខាន់ៗ រួមមាន គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក, គោលការណ៍អន្តរ-ប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ និងគោលការណ៍ផ្តួចផ្តើម និងពង្រីក ដើម្បីប្រសិទ្ធភាព។ បន្ថែមពីលើគោលការណ៍ទាំង ៣ នេះ, ក្របខ័ណ្ឌនេះ បានបន្ថែមនូវគោលការណ៍រួមសំខាន់ៗ ចំនួន ៦ ទៀតសម្រាប់ការអនុវត្ត រួមមាន (១)-ភាពជាម្ចាស់, (២)-អន្តរប្រតិបត្តិការ, (៣)-ស្តង់ដាអភិវឌ្ឍ, (៤)-ទិន្នន័យបើកចំហ, (៥)-បច្ចេកវិទ្យា និងធនធានរួម និង(៦)-គុណភាព និងប្រសិទ្ធភាព។

អនុលោមទៅតាមគោលការណ៍ខាងលើ, ការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវគោរពតាមអតិក្រមចំនួន ៣ ដូចខាងក្រោម៖


១)- មនុស្ស (People)៖ កំណត់នូវគោលការណ៍ក្នុងការកសាង និងប្រើប្រាស់ធនធានមនុស្សស្របតាមតម្រូវការឱ្យមានប្រសិទ្ធភាពខ្ពស់។ បុគ្គលិក និងមន្ត្រីត្រូវមានសមត្ថភាពក្នុងការប្រើប្រាស់, អភិវឌ្ឍ និងថែទាំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ស្របតាមមុខងារនៃការអនុវត្តរបស់ស្ថាប័នខ្លួន។ លើសពីនេះ បុគ្គលិក និងមន្ត្រីត្រូវមានផ្នត់គំនិតក្នុងការចាប់យក និងសម្របលើការប្រើប្រាស់បច្ចេកវិទ្យា ជាពិសេសរបៀបធ្វើការងារជាប្រព័ន្ធ តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ អតិក្រមមនុស្សក៏សំដៅលើអង្គភាពដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតួអង្គពាក់ព័ន្ធដទៃទៀតនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃ

វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងមុខងារនៃតួអង្គពាក់ព័ន្ធ នៅក្នុងប្រព័ន្ធអេកូឡូស៊ី។ អភិក្រមនេះ ត្រូវបានកំណត់ និងដាក់ចេញជាគោលការណ៍ ឬវិធាននៅក្នុងស្រទាប់ទី ១ គឺស្រទាប់មុខងារធុរកិច្ច។

២)- ដំណើរការ (Process)៖ កំណត់នូវចនាសម្ព័ន្ធនៃការអភិវឌ្ឍ, ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យបានច្បាស់លាស់ សំដៅបម្រើដល់ការផ្លាស់ប្តូររបៀបរបបធ្វើការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងរបៀបដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអាចធ្វើការជាមួយគ្នាទៅវិញទៅមកបាន។ថែមពីលើនេះ អភិក្រមដំណើរការ ក៏សំដៅដល់ការកំណត់ពីក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ និងក្របខ័ណ្ឌអន្តរប្រតិបត្តិការដើម្បីធានាដល់ការផ្លាស់ប្តូរ, ប្រើប្រាស់ និងរក្សាសុវត្ថិភាពទិន្នន័យ។ អភិក្រមនេះ ត្រូវបានកំណត់ និងដាក់ចេញជាគោលការណ៍ ឬវិធាននៅក្នុងស្រទាប់ទី ២ គឺស្រទាប់ទិន្នន័យ។

៣)- បច្ចេកវិទ្យា (Technology)៖ កំណត់នូវឧបករណ៍ស្តង់ដា, ថ្នាលឌីជីថលគ្រឹះ និងមធ្យោបាយក្នុងការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធ ដើម្បីធានានូវការពង្រីកវិសាលភាពប្រព័ន្ធ, អន្តរប្រតិបត្តិការរវាងប្រព័ន្ធ និងប្រព័ន្ធ និងស្តង់ដាសុវត្ថិភាពសម្រាប់ប្រព័ន្ធ។ ការកសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចាំបាច់ត្រូវគោរពតាមគោលការណ៍ និងស្តង់ដាដែលបានកំណត់នៅក្នុងក្របខ័ណ្ឌនេះ ព្រមទាំងត្រូវមានមុខងារស្នូលស្របទៅតាមមុខងាររបស់ស្ថាប័នខ្លួន។ លើសពីនេះ ការប្រើប្រាស់ និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវឈរលើមូលដ្ឋាននៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ រួមទាំងបណ្តាញ, មជ្ឈមណ្ឌលទិន្នន័យ, បច្ចេកវិទ្យា និងថ្នាលឌីជីថលគ្រឹះ។ អភិក្រមនេះ ត្រូវបានកំណត់ និងដាក់ចេញជាគោលការណ៍ ឬវិធាននៅក្នុងស្រទាប់ទី ៣ គឺស្រទាប់កម្មវិធី និងស្រទាប់ទី ៤ គឺស្រទាប់បច្ចេកវិទ្យា។

រូបភាពទី ៦៖ គោលការណ៍ និងអភិក្រមក្នុងការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មបច្ចេកវិទ្យាព័ត៌មាន



៣.៣. និម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ការរៀបចំក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន បានប្រើប្រាស់វិធីសាស្ត្រ និងឧបករណ៍មួយចំនួនរួមមាន ការអង្កេត, សម្ភាសន៍ផ្ទាល់, រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងការពិនិត្យលើឯកសារពាក់ព័ន្ធផ្សេងៗ ជាដើម។ ការអង្កេត និងសម្ភាសន៍ផ្ទាល់ដោយការប្រើប្រាស់ក្របខ័ណ្ឌ Control Objectives for Information and Related Technologies (COBIT) ២០១៩ គឺដើម្បីសិក្សាស្វែងយល់ស៊ីជម្រៅពីស្ថានភាពបុគ្គលិកផ្នែកបច្ចេកវិទ្យាព័ត៌មាន, តួនាទី និងការកិច្ចរបស់អង្គភាព, ស្ថានភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងស្ថានភាពមន្ត្រី បុគ្គលិកសម្រាប់ការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាដើម។ បន្ថែមពីនេះ សិក្ខាសាលាពិគ្រោះយោបល់ស្តីពីអភិបាលកិច្ចទិន្នន័យក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំឡើង ដើម្បីស្វែងយល់កាន់តែស៊ីជម្រៅពីទិន្នន័យដែលមាននៅតាមអង្គភាពនីមួយៗ, ក៏ដូចជាពីការគ្រប់គ្រងទិន្នន័យ និងដើម្បីកំណត់ពីការផ្លាស់ប្តូរទិន្នន័យទាំងនោះ។ សិក្ខាសាលានេះបានជួយសម្រួចដល់ការរៀបចំក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ និងក្របខ័ណ្ឌអន្តរប្រតិបត្តិការ ដែលបានក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងស្រទាប់ទិន្នន័យនៃក្របខ័ណ្ឌនិម្មាបនកម្មនេះ។ បន្ថែមពីលើការអង្កេត និងសម្ភាសន៍ផ្ទាល់ ព្រមទាំងសិក្ខាសាលា, អនុក្រឹត្យស្តីពីការបង្កើតអគ្គនាយកដ្ឋាន និងអង្គភាព ព្រមទាំងប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃអង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួង ត្រូវបានប្រមូល និងយកមកពិនិត្យ ដើម្បីស្វែងយល់ពីមុខងារ និងការកិច្ចដែលអគ្គនាយកដ្ឋាន និងអង្គភាពទាំងនោះត្រូវបំពេញ។

លទ្ធផលដែលបានពីការប្រើប្រាស់ក្របខ័ណ្ឌ COBIT ២០១៩ បានផ្តល់សេចក្តីសន្និដ្ឋានសំខាន់ចំនួន ៣ រួមមាន (១)-ការរៀបចំនូវនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលតម្រូវឱ្យមានអន្តរសេកម្មរវាងអង្គភាពទាំងអស់ទៅតាមភាពចាំបាច់ និងត្រូវធានាឱ្យបានថាអង្គភាពមានសិទ្ធិសម្រេច និងគ្រប់គ្រងប្រព័ន្ធផ្ទៃក្នុង ក៏ដូចជាទិន្នន័យរបស់ខ្លួន និយាយជារួម អង្គភាពទាំងនោះនៅតែរក្សាបាននូវអធិបតេយ្យភាពសិទ្ធិ, អំណាច និងតួនាទីរបស់ខ្លួន ទន្ទឹមនឹងការចូលរួមយ៉ាងសកម្មបន្ថែមទៀត នៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (២)-ការចែករំលែកទិន្នន័យប្រកបដោយតម្លាភាពរវាងអង្គភាពដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទិន្នន័យដែលមានស្រាប់ និង (៣)-ការប្រើប្រាស់ធនធាន និងដោះស្រាយបញ្ហានៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានប្រកបដោយប្រសិទ្ធភាព តាមរយៈការប្រើប្រាស់នូវធនធានដែលមានស្រាប់រួមគ្នា និងកំណត់នូវតួនាទី និងទំនួលខុសត្រូវច្បាស់លាស់។ លទ្ធផលដែលបានពីការប្រើប្រាស់ក្របខ័ណ្ឌ COBIT ២០១៩ បង្ហាញលម្អិតនូវក្នុងឧបសម្ព័ន្ធទី ២ ។

ស្របតាមលទ្ធផលដែលបានពីក្របខ័ណ្ឌ COBIT ២០១៩, ការរៀបចំសិក្ខាសាលា និងការពិនិត្យលើឯកសារពាក់ព័ន្ធផ្សេងៗ, ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំស្របតាមនិម្មាបនកម្មសហគ្រាសដែលមាន ៤ ស្រទាប់ ដូចរូបភាពទី ៧ ខាងក្រោម។ គោលការណ៍នៅក្នុងក្របខ័ណ្ឌនិម្មាបនកម្មនេះ ក៏រៀបចំឡើងស្របទៅតាមស្រទាប់ទាំង ៤ នេះផងដែរ។


១)- ស្រទាប់មុខងារធុរកិច្ច៖ កំណត់ពីគោលបំណង និងគោលដៅរបស់ស្ថាប័ន, មុខងារ និងធនធានមនុស្ស ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់, អភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

២)- ស្រទាប់ទិន្នន័យ៖ កំណត់ពីការរៀបចំក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ដើម្បីគ្រប់គ្រង និងចែករំលែកទិន្នន័យឱ្យបានទូលំទូលាយ និងមានគោលការណ៍ច្បាស់លាស់ ព្រមទាំងកំណត់ពីក្របខ័ណ្ឌអន្តរប្រតិបត្តិការ ក្នុងការធ្វើសន្ទានកម្មទិន្នន័យគ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធ។

៣)- ស្រទាប់ប្រព័ន្ធ ឬកម្មវិធី៖ កំណត់ពីការអភិវឌ្ឍ, ដាក់ដំណើរការ និងគ្រប់គ្រងតាមដានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធី ដើម្បីធានាបាននូវការប្រើប្រាស់មុខងាររួម និងអន្តរប្រតិបត្តិការជាមួយគ្នា ព្រមទាំងធានាបាននូវសុវត្ថិភាពសម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផងដែរ។

៤)- ស្រទាប់បច្ចេកវិទ្យា៖ កំណត់ពីហេដ្ឋារចនាសម្ព័ន្ធ, ឧបករណ៍បច្ចេកវិទ្យា និងបច្ចេកវិទ្យារួមដែលប្រើប្រាស់ក្នុងដំណើរការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងថ្នាលឌីជីថលគ្រឹះដែលត្រូវបានប្រើប្រាស់ ដើម្បីឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបានរៀបចំ មានស្តង់ដាខ្ពស់ និងអាចប្រើប្រាស់ធនធានរួមឱ្យបានដាអតិបរិមា។

រូបភាពទី ៧៖ ក្របខ័ណ្ឌនិម្មាបនកម្មបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




៣.៣.១. ស្រទាប់មុខងារធុរកិច្ច

ស្រទាប់មុខងារធុរកិច្ច សំដៅដល់ការកំណត់ពីគោលបំណង និងគោលដៅ ដែលបញ្ជាក់យ៉ាងច្បាស់ពីមុខងាររបស់អង្គភាពនីមួយៗ, កំណត់ពីបំណែងចែកនៃមុខងារទៅតាមស្ថានភាពនៃអង្គភាព ព្រមទាំងកំណត់ពីគោលការណ៍នៃការប្រើប្រាស់ធនធានមនុស្សស្របតាមតម្រូវការ និងធនធាន។ ក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ គោលការណ៍ដែលបានដាក់ចេញតាមផ្នែកនីមួយៗ នៅក្នុងស្រទាប់នេះរួមមាន៖

(ក) **មុខងាររបស់អង្គភាព៖** ដោយផ្តោតតែលើទិដ្ឋភាពនៃការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, អង្គភាពទាំងអស់ត្រូវអនុលោមតាមគោលការណ៍សំខាន់ៗ ដែលបានកំណត់នៅក្នុងផ្នែកនេះ នៃស្រទាប់មុខងារធុរកិច្ច។

១)- គោរពតាមការបែងចែកអង្គភាពទាំងអស់នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបែងចែកជា ៣ ក្រុមតាមកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដែលរួមមាន (១)-ក្រុមដំណើរការពេញលេញ, (២)-ក្រុមអភិវឌ្ឍ និង (៣)-ក្រុមប្រតិបត្តិ ដែលក្រុមនីមួយៗ មានសិទ្ធទៅលើការរៀបចំអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដូចបានបង្ហាញក្នុងរូបភាពទី ៨ និងខ្លឹមសារខាងក្រោម៖

រូបភាពទី ៨៖ ការចែកកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន



- **ក្រុមទី ១ - ក្រុមដំណើរការពេញលេញ៖** មានលទ្ធភាពក្នុងការគ្រប់គ្រង និងប្រតិបត្តិហេដ្ឋារចនាសម្ព័ន្ធ និងមជ្ឈមណ្ឌលទិន្នន័យ និងអាចអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបានដោយខ្លួនឯង។
- **ក្រុមទី ២ - ក្រុមអភិវឌ្ឍ៖** មានលទ្ធភាពក្នុងការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយខ្លួនឯង ដោយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធដែលគ្រប់គ្រងដោយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន ឬអគ្គនាយកដ្ឋានណាមួយនៅក្នុងក្រុមទី ១ ខាងលើ។

- **ក្រុមទី ៣ - ក្រុមប្រតិបត្តិ៖** មានលទ្ធភាពក្នុងការប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីបម្រើមុខងាររបស់ខ្លួន ដែលប្រព័ន្ធទាំងនោះត្រូវបានអភិវឌ្ឍដោយអង្គភាពផ្សេង ឬជួលក្រុមហ៊ុនផ្តល់សេវាបច្ចេកវិទ្យាក្នុងការអភិវឌ្ឍ។

២)- ពង្រឹង និងរៀបចំឱ្យបានរៀបរយនូវរចនាសម្ព័ន្ធរបស់ខ្លួនដែលមានស្រាប់ក្នុងពេលបច្ចុប្បន្នស្របតាមការវិភាគមុខងារនេះ និងឆ្លើយតបទៅនឹងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

៣)- ពិនិត្យលទ្ធភាពកែសម្រួលរចនាសម្ព័ន្ធអង្គភាព និងក្រុមការងារបច្ចេកវិទ្យាព័ត៌មាន ស្របតាមការវិភាគមុខងារនេះ។

(ខ) ការប្រើប្រាស់ធនធាន៖ ការជ្រើសរើស និងប្រើប្រាស់ធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មាន ឬមន្ត្រីបច្ចេកទេសត្រូវគោរពទៅតាមតម្រូវការនៅក្នុងក្រុមនីមួយៗ ។ ការស្នើសុំជ្រើសរើសធនធានមនុស្សក៏អាចប្រែប្រួលក្នុងករណីដែលអគ្គនាយកដ្ឋាន ឬអង្គភាពត្រូវបានបន្ថែមមុខងារថ្មី។ ទន្ទឹមនេះ ដាយន្តការនៃការធ្វើបវិត្តកម្មឌីជីថល, មន្ត្រី និងបុគ្គលិកដែលជាអ្នកប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវទទួលបានការបណ្តុះបណ្តាលពីការប្រើប្រាស់បច្ចេកវិទ្យា។

១)- រៀបចំយន្តការក្នុងការជ្រើសរើស និងប្រើប្រាស់ធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មានដោយត្រូវគោរពទៅតាមបំណែងចែកកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានជា ៣ ក្រុមខាងលើ រួមមាន៖

- **ក្រុមទី ១ - ក្រុមដំណើរការពេញលេញ៖** មានលទ្ធភាពក្នុងការជ្រើសរើសបុគ្គលិកជំនាញបច្ចេកវិទ្យាព័ត៌មានគ្រប់ផ្នែក។
- **ក្រុមទី ២ - ក្រុមអភិវឌ្ឍ៖** មានលទ្ធភាពក្នុងការជ្រើសរើសបុគ្គលិកជំនាញផ្នែកអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធី។
- **ក្រុមទី ៣ - ក្រុមប្រតិបត្តិ៖** មានលទ្ធភាពក្នុងការជ្រើសរើសបុគ្គលិកផ្នែកគាំទ្រ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

២)- រៀបចំយន្តការធ្វើការឆ្លងអង្គភាព ដោយឈរលើគោលការណ៍កិច្ចសហការ និងប្រសិទ្ធភាពការងារ ដើម្បីធានាបាននូវការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគាំទ្រគ្នាទៅវិញទៅមកបានពេញលេញ។

៣)- កសាងយន្តការលើកទឹកចិត្តដោយផ្អែកលើសមិទ្ធផល (Performance-Based Incentives) ក្នុងរូបភាពជាការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ, ការផ្តល់មេដាយ និងការផ្តល់ឱកាសអភិវឌ្ឍសមត្ថភាពជាដើម។

៤)- រៀបចំនូវការបណ្តុះបណ្តាលដល់មន្ត្រី និងបុគ្គលិក ដោយផ្តោតលើចំណេះដឹង និងជំនាញពាក់ព័ន្ធ និងចាំបាច់ ស្របតាមការវិវឌ្ឍនៃបច្ចេកវិទ្យាថ្មីៗ និងការកំណត់នៅក្នុងក្របខ័ណ្ឌនិម្មាបនកម្មនេះ។


៥)- រៀបចំផែនការអំពីតម្រូវការធនធានមនុស្ស ឬមន្ត្រីបច្ចេកទេសផ្នែកបច្ចេកវិទ្យាព័ត៌មាន និងផែនការក្នុងការកសាងធនធានមនុស្សដើម្បីឆ្លើយតបនឹងការវិវឌ្ឍនៃបច្ចេកវិទ្យាថ្មីៗ ។

៣.៣.២. ស្រទាប់ទិន្នន័យ

ស្រទាប់ទិន្នន័យ កំណត់ពីការរៀបចំក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ដើម្បីគ្រប់គ្រង និងចែករំលែកទិន្នន័យឱ្យបានទូលំទូលាយ និងមានគោលការណ៍ច្បាស់លាស់ ព្រមទាំងកំណត់ពីក្របខ័ណ្ឌអន្តរប្រតិបត្តិការ ក្នុងការធ្វើសន្ធានកម្មទិន្នន័យគ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធ។

(ក) ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ៖ សំដៅដល់សំណុំនៃការកំណត់ពីតួនាទី, សិទ្ធអំណាច, ដំណើរការ, ការគ្រប់គ្រង និងការសម្រេចចិត្តរួមគ្នា ដើម្បីធ្វើការប្រមូល, រៀបចំ, រក្សាទុក, ចែករំលែក និងប្រើប្រាស់ទិន្នន័យ ឱ្យបានត្រឹមត្រូវសម្រាប់ស្ថាប័ន។ ប្រព័ន្ធទាំង ២០០ និងមុខងារនៃអង្គភាពទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចបែងចែកជា ៦ ក្រុម រួមមាន (១)-ការគ្រប់គ្រងចំណូល, (២)-ការអនុវត្តចំណូល-ចំណាយ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យនៃថវិការដ្ឋ, (៣)-ការវិនិយោគសាធារណៈ, (៤)-ឧស្សាហកម្មហិរញ្ញវត្ថុ,(៥)-រដ្ឋបាល, ធនធានមនុស្ស, សារពើភណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ និងសេវាសាធារណៈ និង (៦)-ម៉ាក្រូសេដ្ឋកិច្ច, សវនកម្ម និងអធិការកិច្ច។ ការបែងចែកជាក្រុមបែបនេះ អនុញ្ញាតឱ្យមានការកំណត់នូវទំនាក់ទំនងនៃដំណើរការការងាររបស់អង្គភាព និងតួនាទីរបស់អង្គភាពនីមួយៗ បានយ៉ាងច្បាស់លាស់។ រូបភាពទី ៩ ខាងក្រោមនេះ បង្ហាញពីក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបែងចែកតាមមុខងារនៃអង្គភាពទាំងអស់ តាមក្រុមទាំង ៦ នៃប្រព័ន្ធ ព្រមទាំងកំណត់ពីតួនាទី និងទំនាក់ទំនងរបស់អង្គភាពទាំងអស់លើទិន្នន័យ។ ការកំណត់ក្នុងក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យនេះ នឹងអនុញ្ញាតឱ្យអង្គភាពនីមួយៗ ដឹងពីតួនាទីរបស់ខ្លួនបានច្បាស់លាស់ និងត្រូវអនុលោមទៅតាម ដើម្បីធ្វើការចែករំលែកទិន្នន័យឱ្យគ្នាទៅវិញទៅមកមានប្រសិទ្ធភាព។ តារាងលម្អិតបង្ហាញពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងតួនាទីនៃអង្គភាពក្នុងក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ១ ។

រូបភាពទី ៩៖ ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



នៅក្នុងក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យនេះ, តួនាទី និងទំនួលខុសត្រូវលើទិន្នន័យ ត្រូវបានបែងចែកជា ៤ ក្រុម និងដាក់ចេញនូវគោលការណ៍សំខាន់ដូចខាងក្រោម៖

១)- **ប្រធានទិន្នន័យ (Data Owner)**៖ គឺជាអង្គភាពដែលទទួលខុសត្រូវលើខ្លឹមសារ, អត្ថន័យ, និងគុណភាពទិន្នន័យ ព្រមទាំងផ្តល់ការយល់ព្រមលើការចែករំលែកទិន្នន័យទៅដល់បុគ្គលផ្សេងទៀតក្នុងគោលបំណងណាមួយ។ នៅក្នុងក្របខ័ណ្ឌនេះ, ប្រធានទិន្នន័យអាចជា ប្រជាពលរដ្ឋទូទៅ, ធុរជន, ក្រុមហ៊ុន, សហគ្រាស ព្រមទាំងបុគ្គលិក មន្ត្រីនៅតាមក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ។ ទន្ទឹមនេះ អង្គភាពនីមួយៗ ក៏ជាប្រធានទិន្នន័យលើទិន្នន័យមួយចំនួន ដូចជា ចំណាយ, ចំណូល, សមិទ្ធកម្ម, សមិទ្ធផល, ផែនការចំណាយ, ផែនការសកម្មភាព, បុគ្គលិក, បញ្ជីសារពើភណ្ឌជាដើម។ គោលការណ៍សម្រាប់ប្រធានទិន្នន័យនៅក្នុងក្របខ័ណ្ឌនេះ មានដូចខាងក្រោម៖

- ប្រធានទិន្នន័យជាអ្នកទទួលខុសត្រូវលើភាពត្រឹមត្រូវ និងភាពជឿជាក់នៃទិន្នន័យរបស់ខ្លួន។
- ប្រធានទិន្នន័យមានសិទ្ធក្នុងការចូលទៅពិនិត្យ, កែសម្រួល និងប្រើប្រាស់ទិន្នន័យរបស់ខ្លួនតាមតម្រូវការ ដោយមិនតម្រូវឱ្យរៀបចំជាលិខិតស្នើសុំផ្លូវការដាក់ជូនទៅបុគ្គលគ្រប់គ្រងទិន្នន័យ។

- ប្រធានទិន្នន័យមានសិទ្ធក្នុងការផ្តល់ការអនុញ្ញាត (Consent) សម្រាប់ការប្រមូល, កែសម្រួល, លុប ឬចែករំលែកទិន្នន័យ។

២)- បុគ្គលគ្រប់គ្រងទិន្នន័យ (Data Custodian)៖ គឺជាអង្គភាពដែលមានតួនាទីកំណត់គោល-បំណង និងមធ្យោបាយនៃការប្រមូល ការប្រើប្រាស់ ឬការលាតត្រដាងទិន្នន័យ។ ផ្អែកតាមមុខងារ របស់អង្គភាព, អង្គភាពភាគច្រើនមានតួនាទីជាបុគ្គលគ្រប់គ្រងទិន្នន័យ ពោលគឺ អង្គភាពទាំងនោះ មានតួនាទីក្នុងការប្រមូលទិន្នន័យពីអ្នកប្រើប្រាស់ ឬអ្នកទទួលសេវា។ អង្គភាពទាំងនោះភាគច្រើន ជាអង្គភាពដែលមានតួនាទីជាម្ចាស់ ឬអ្នកគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ គោលការណ៍ សម្រាប់បុគ្គលគ្រប់គ្រងទិន្នន័យនៅក្នុងក្របខ័ណ្ឌនេះ មានដូចខាងក្រោម៖

- បុគ្គលគ្រប់គ្រងទិន្នន័យ ត្រូវរៀបចំឱ្យមានជាសេចក្តីណែនាំឱ្យបានច្បាស់លាស់ និងការស្នើសុំការ អនុញ្ញាត (Consent) ពីប្រធានទិន្នន័យ រាល់ការធ្វើប្រតិបត្តិការលើទិន្នន័យ នៅក្នុងប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានរបស់ខ្លួន។
- បុគ្គលគ្រប់គ្រងទិន្នន័យត្រូវចែករំលែកទិន្នន័យ ទៅកាន់បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យទៅតាមការ អនុញ្ញាតរបស់ប្រធានទិន្នន័យ និងគោរពទៅតាមបញ្ជីទិន្នន័យរបស់អង្គភាពសម្រាប់ការផ្លាស់ប្តូរ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី ២ ។
- បុគ្គលគ្រប់គ្រងទិន្នន័យត្រូវរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន ដើម្បីធានាបាននូវអន្តរ-ប្រតិបត្តិការ ក្នុងការផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀត ដោយគោរពតាម គោលការណ៍នៅក្នុងក្របខ័ណ្ឌអន្តរប្រតិបត្តិការ ដែលបានបង្ហាញនូវចំណុច (ខ) ក្របខ័ណ្ឌអន្តរ-ប្រតិបត្តិការ ខាងក្រោម។
- បុគ្គលគ្រប់គ្រងទិន្នន័យត្រូវធានាឱ្យបាននូវសុវត្ថិភាពនៃទិន្នន័យ និងធានាឱ្យបាននូវអនុលោមភាព នៃការប្រើប្រាស់ទិន្នន័យ តាមក្របខ័ណ្ឌអន្តរប្រតិបត្តិការដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី ១ និង បញ្ជីទិន្នន័យរបស់អង្គភាពសម្រាប់ការផ្លាស់ប្តូរក្នុងឧបសម្ព័ន្ធទី ២ ។

៣)- បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ (Data Consumer)៖ ជាអង្គភាពដែលមានតួនាទីធ្វើប្រព្រឹត្តកម្ម (ប្រើប្រាស់) ទិន្នន័យ ដែលបានមកពីប្រធានទិន្នន័យ។ គោលការណ៍សម្រាប់បុគ្គលធ្វើប្រព្រឹត្តកម្ម ទិន្នន័យ នៅក្នុងក្របខ័ណ្ឌនេះ មានដូចខាងក្រោម៖

- បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ មានទំនួលខុសត្រូវក្នុងការធានានូវសុវត្ថិភាព, ទំនុកចិត្ត និង ក្រមសីលធម៌នៃការប្រើប្រាស់ទិន្នន័យ។


៤)- បុគ្គលអភិបាលកិច្ចទិន្នន័យ ឬបុគ្គលអធិការកិច្ចទិន្នន័យ (Data Steward)៖ ជាអង្គភាពដែល មានតួនាទីតាមដាន, ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ដែលបានព្រមព្រៀង។ គោលការណ៍សម្រាប់បុគ្គលអភិបាលកិច្ចទិន្នន័យ នៅក្នុងក្របខ័ណ្ឌនេះ មានដូចខាងក្រោម៖

- បុគ្គលអភិបាលកិច្ចទិន្នន័យមានតួនាទីបង្កើតគោលការណ៍ណែនាំ សម្រាប់ការគ្រប់គ្រងទិន្នន័យ ព្រមទាំងការវាយតម្លៃគុណភាព និងសុវត្ថិភាពទិន្នន័យ។
- បុគ្គលអភិបាលកិច្ចទិន្នន័យមានតួនាទីតាមដាន, ត្រួតពិនិត្យ និងជំរុញការអនុវត្តក្របខ័ណ្ឌ អភិបាលកិច្ចទិន្នន័យដែលបានព្រមព្រៀង។

ដើម្បីបង្ហាញពីដំណើរការនៃការអនុវត្តក្របខ័ណ្ឌអន្តរប្រតិបត្តិការ នៅក្នុងក្របខ័ណ្ឌនិម្មាបនកម្ម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ទិន្នន័យក្នុងគម្រោងវិនិយោគសាធារណៈនឹងលើកយកមកបង្ហាញជាឧទាហរណ៍។ ក្នុងដំណើរការអនុវត្តគម្រោងវិនិយោកសាធារណៈ, ទិន្នន័យអំពីព័ត៌មានគម្រោង និងវដ្តនៃគម្រោងទាំង ៨ ដំណាក់កាល ជាទិន្នន័យសំខាន់ ហើយក្រសួង ស្ថាប័នជាម្ចាស់គម្រោង ជាប្រធានទិន្នន័យ។ បុគ្គលគ្រប់គ្រងទិន្នន័យ អាចជាអង្គភាពមួយចំនួនដូចជា អគ្គនាយកដ្ឋានថវិកា ក្នុងករណីប្រើប្រាស់ថវិកាជាតិ, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ក្នុងករណីប្រើប្រាស់ថវិកាកម្ចី, អគ្គនាយក-ដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងករណីប្រើប្រាស់ថវិកាថ្នាក់ក្រោមជាតិ និងអគ្គនាយកដ្ឋានភាព ជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងករណីប្រើប្រាស់ថវិកាដៃគូ ជាដើម។ ចំពោះបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ គឺមានអគ្គនាយកដ្ឋានគោលនយោបាយ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការគម្រោងវិនិយោគសាធារណៈ។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន គឺមានតួនាទីជាបុគ្គលអភិបាលកិច្ចទិន្នន័យ។

(ខ) ក្របខ័ណ្ឌអន្តរប្រតិបត្តិការ: សំដៅដល់យន្តការដែលអនុញ្ញាតឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ពីរ ឬច្រើនជាងនេះ អាចមានលទ្ធភាពក្នុងការធ្វើអន្តរកម្មជាមួយគ្នាបាន ក្នុងគោលបំណងចែករំលែក ទិន្នន័យជាមួយគ្នា ឬប្រើប្រាស់ទិន្នន័យពីគ្នាទៅវិញទៅមក។ កង្វះនៃការធ្វើអន្តរប្រតិបត្តិការ គឺជាឧបសគ្គ ចម្បងនៅក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ស្ថាប័នធំៗ ដែលមានអង្គភាពចំណុះ និង មានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានច្រើន។ នៅក្នុងក្របខ័ណ្ឌអន្តរប្រតិបត្តិការ ចាំបាច់ត្រូវបង្កើតនូវសំណុំនៃ ស្តង់ដា, គោលការណ៍ និងនីតិវិធីដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់ត្រូវអនុលោមតាម ដើម្បី អនុញ្ញាតឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗ អាចទាក់ទងគ្នា, ផ្លាស់ប្តូរទិន្នន័យជាមួយគ្នា និងប្រើប្រាស់ មុខងារគ្នាទៅវិញទៅមកបាន។ ជាឧត្តមានុវត្តន៍អន្តរជាតិ សំណុំនៃស្តង់ដា, គោលការណ៍ និងនីតិវិធីទាំង នោះមានធាតុសំខាន់ៗ ចំនួន ៤ រួមមាន (១)-គោលការណ៍នៃការរៀបចំសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interface – API), (២)-កត្តាជំរុញ, (៣)-លក្ខណៈបច្ចេកទេស និង (៤)-ហេដ្ឋារចនា-សម្ព័ន្ធគាំទ្រ។ ***អង្គភាពទាំងអស់ត្រូវពិនិត្យ និងរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនឱ្យស្របទៅតាមស្តង់ដា, គោលការណ៍ និងនីតិវិធីទាំងនោះ ដូចដែលបានបង្ហាញក្នុងរូបភាពទី ១០ និងខ្លឹមសារខាងក្រោម។*** ធាតុសំខាន់ៗ នៅក្នុងសំណុំនេះ មាន ៤ រួមមាន៖

រូបភាពទី ១០៖ ក្របខ័ណ្ឌអន្តរប្រតិបត្តិការ



១)- គោលការណ៍នៃការរៀបចំ API៖ ជាលក្ខណៈបច្ចេកទេស ការរៀបចំ API ឱ្យមានស្តង់ដា និងធានាបាននូវការផ្លាស់ប្តូរជាមួយគ្នាបាន ចាំបាច់ត្រូវមានធាតុសំខាន់មួយចំនួន។ ចំណុចទាំងនោះមានដូចជា៖

- **ភាពស្វយ័ត៖** ចៀសវាងការពឹងផ្អែកលើអ្នកផ្តល់សេវាកម្ម ឬបច្ចេកវិទ្យាណាមួយ ដែលនាំឱ្យពិបាកក្នុងការបត់បែនតាមការវិវឌ្ឍ និងនិន្នាការ។
- **សុវត្ថិភាព៖** រៀបចំសំណុំនៃវិធីសាស្ត្រស្របទៅតាមស្តង់ដា និងនីតិវិធីច្បាស់លាស់ ដើម្បីបង្ការ និងធានាឱ្យបាននូវសុវត្ថិភាព។
- **ភាពធ្វើសន្ធានកម្ម៖** រៀបចំ API ឱ្យមានលក្ខណៈស្តង់ដា, មានឯកសារ និងងាយស្រួលប្រើប្រាស់ ដើម្បីកាត់បន្ថយភាពស្មុគស្មាញដល់អ្នកប្រើប្រាស់។
- **ភាពមិនងាយផ្លាស់ប្តូរ៖** រៀបចំ API ឱ្យមានស្ថិរភាពរយៈពេលវែង តាមរយៈការបន្ថែមកំណែសម្រាប់ API នីមួយៗ ដោយធានាថាមានការផ្លាស់ប្តូរតិចតួច នឹងមិនប៉ះពាល់ដល់អ្វីដែលបានរៀបចំនោះទេ។
- **ភាពត្រូវគ្នាក្នុងចំណោម API ជំនាន់ខុសគ្នា៖** ធានាថាកំណែថ្មីនៃ API នៅតែអាចដំណើរការជាមួយព័ត៌មានស្នើសុំ (Request) និងឆ្លើយតប (Response) ដែលផ្អែកលើកំណែចាស់ដោយមិនចាំបាច់ធ្វើការផ្លាស់ប្តូរកូដច្រើន។
- **ភាពធ្មុំជាមួយ API ផ្សេងទៀត៖** ធានាថា API អាចធ្វើសន្ធានកម្មបានល្អជាមួយនឹង API ផ្សេងទៀត។
- **ភាពស្វែងរកឃើញ៖** ធានាថា API អាចត្រូវបានប្រើប្រាស់ឡើងវិញ និងត្រូវបានបង្ហាញតាមរបៀបមួយដែលងាយស្រួលរកឃើញ និងប្រើប្រាស់សម្រាប់គោលបំណងផ្សេងៗ នាពេលអនាគត។

- **ភាពមានឯកសារបច្ចេកទេសគ្រប់គ្រាន់៖** រៀបចំឯកសារ និងការណែនាំឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ អំពីរបៀបដែល API ដំណើរការ និងព័ត៌មានលម្អិតរបស់ API ។

២)- **កត្តាជំរុញ៖** កត្តាជំរុញសំខាន់ៗ ត្រូវកំណត់ឱ្យបានច្បាស់លាស់ ដើម្បីធានាបានការអនុវត្តក្របខ័ណ្ឌអន្តរប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពខ្ពស់។

- **អភិបាលកិច្ចទិន្នន័យ៖** ដូចបានរៀបរាប់លម្អិតនៅផ្នែក (ក) ខាងលើ។
- **ការយល់ព្រម៖** រៀបចំយន្តការផ្តល់ការយល់ព្រមពីប្រធានទិន្នន័យ នូវរាល់អន្តរសកម្មលើទិន្នន័យ ដូចជា ការរក្សាទុក, ការដំណើរការ និងការចូលប្រើទិន្នន័យ។
- **ការការពារទិន្នន័យ៖** ធានាថាទិន្នន័យត្រូវបានការពារយ៉ាងល្អ នៅក្នុងក្របខ័ណ្ឌអន្តរប្រតិបត្តិការដែលជាចំណុចសំខាន់សម្រាប់រក្សាទំនុកចិត្ត និងភាពត្រឹមត្រូវនៃប្រព័ន្ធ។ ចំណុចសំខាន់ៗ ទាក់ទងនឹងការការពារទិន្នន័យមានដូចជា៖
  - **សុវត្ថិភាពតាមការរៀបចំ** (Secured by Design)៖ កំណត់អំពីការការពារទិន្នន័យ តាំងពីដំណាក់កាលដំបូងនៃការរៀបចំ API ។
  - **ការធ្វើកូដនីយកម្មទិន្នន័យ** (Data Encryption)៖ បំប្លែងទិន្នន័យទៅជាទម្រង់ណាមួយដែលគេមិនអាចមើលយល់បាន មុនពេលទិន្នន័យត្រូវបានផ្ទេរ និងរក្សាទុក។
  - **ការបង្កើតតម្លៃហាស** (Hashing)៖ បំប្លែងទិន្នន័យទៅជាទិន្នន័យមួយទៀតក្នុងទម្រង់ជាអក្សរ និងលេខ (String) ដែលមិនអាចឱ្យគេបំប្លែងត្រឡប់ទៅទិន្នន័យដើមបាន ហើយមានទំហំកំណត់ជាក់លាក់មួយ។ តម្លៃហាសនេះ អាចប្រើប្រាស់ធ្វើជាអត្តសញ្ញាណ (Data Fingerprint) នៃទិន្នន័យដើមនោះបាន។
  - Tokenization៖ ការពារព័ត៌មានដែលមានភាពរសើបខ្ពស់ ដោយបំប្លែងព័ត៌មានទៅជាផ្នែកតូចៗ សម្រាប់ឱ្យប្រព័ន្ធ ឬម៉ាស៊ីនអាចអានព័ត៌មានទាំងនេះមកវិញ។
  - **ការបិទបាំង** (Mask)៖ បិទបាំងព័ត៌មានមួយចំនួននៅពេលចែករំលែក ពិសេសព័ត៌មានដែលមានភាពរសើបខ្ពស់។
  - **ហត្ថលេខាឌីជីថល** (Digital Signature)៖ ផ្តល់នូវការបញ្ជាក់អត្តសញ្ញាណច្បាស់លាស់ និងសុចរិតភាព នៃទិន្នន័យដើម។
  - **ទិន្នន័យត្រូវបានការពារដោយច្បាប់ ឬបទប្បញ្ញត្តិ** (Protected by Law)៖ កំណត់ ឬអនុលោមតាមបទប្បញ្ញត្តិដែលមានស្រាប់ ដើម្បីធានានូវការការពារទិន្នន័យ និងការការពារឯកជនភាព។
- **ចល័តភាពនៃទិន្នន័យ៖** ធានាឱ្យបាននូវសមត្ថភាពក្នុងការផ្ទេរទិន្នន័យ ពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀត តាមការកំណត់ និងតម្រូវការចាំបាច់។ ដើម្បីធានានូវចល័តភាពនៃទិន្នន័យបាន ចាំបាច់ត្រូវរៀបចំឱ្យមានធាតុសំខាន់ៗ មួយចំនួន ដូចជា៖
  - **ការចម្លងទិន្នន័យ** (Data Replication)៖ ទិន្នន័យអាចចម្លងទុក និងរក្សាទុកនៅទីតាំងផ្សេងគ្នា។
  - **ការផ្លាស់ប្តូរទីតាំងទិន្នន័យ** (Data Relocation)៖ ទិន្នន័យអាចផ្លាស់ប្តូរទីតាំងរូបវន្តនៃការរក្សាទុក ពីទីតាំងមួយ ទៅទីតាំងមួយទៀត។

- **ការផ្ទេរទិន្នន័យ (Data Migration)៖** ទិន្នន័យអាចផ្លាស់ប្តូរពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀត នៅពេលមានតម្រូវការផ្លាស់ប្តូរ ឬដំឡើងកំណែនៃប្រព័ន្ធ។
- **ការបម្រុងទុកទិន្នន័យ (Data Backup)៖** ទិន្នន័យត្រូវបានបម្រុងទុកជាប្រចាំ (ប្រចាំថ្ងៃ, សប្តាហ៍, ខែ ឬឆ្នាំ ជាដើម) អាស្រ័យតាមប្រភេទទិន្នន័យ ដើម្បីការពារការបាត់បង់ ឬដើម្បីអាចស្តារទិន្នន័យបានក្នុងករណីមានគ្រោះមហន្តរាយ ឬការខូចខាត ជាដើម។

៣)- **លក្ខណៈបច្ចេកទេស៖** ការរៀបចំ API ផ្តោតលើលក្ខណៈបច្ចេកទេសសំខាន់ៗ មួយចំនួន ដូចខាង-ក្រោម៖

- **ទម្រង់ទិន្នន័យផ្លាស់ប្តូរតាម API៖** ប្រព័ន្ធនីមួយៗ ត្រូវកំណត់ស្តង់ដានៃទម្រង់ទិន្នន័យឱ្យបានជាក់លាក់ ដើម្បីអនុញ្ញាតឱ្យអាចធ្វើការផ្លាស់ប្តូរតាម API បាន។ ទម្រង់ទិន្នន័យដែលពេញនិយមក្នុងការប្រើប្រាស់សម្រាប់ការផ្លាស់ប្តូរមានដូចជា ទម្រង់ JSON, XML, Text, CSV ឬក្នុងទម្រង់ជា File Upload ជាដើម។
- **ការគ្រប់គ្រង API៖** បង្កើត, គ្រប់គ្រង និងតាមដានការប្រើប្រាស់ API ដើម្បីធានាបាននូវប្រសិទ្ធភាព, សុវត្ថិភាព និងភាពជោគជ័យ ដោយគោរពតាមចំណុចសំខាន់ៗ ខាងក្រោម៖
  - **API Gateway៖** ទទួល API Request ពីខាងក្រៅ ដោយ API Request ដែលទទួលបាន គឺត្រូវបានកំណត់ដោយគោលការណ៍ណាមួយ និងត្រូវបែងចែក API Request ទាំងនោះទៅកាន់ Service ណាមួយផ្អែកតាមការស្នើរបស់ API។
  - **API Catalogue៖** រៀបចំឱ្យមានកាតាឡុក API ដើម្បីផ្តល់ព័ត៌មានលម្អិតអំពី API ។
  - **API Discovery Service៖** រៀបចំឱ្យមានយន្តការគាំទ្រដល់ការស្វែងរក API ដោយស្វ័យប្រវត្តិ។
  - **API Meta Information៖** ផ្តល់ព័ត៌មានសង្ខេបអំពី API ដែលជួយឱ្យអ្នកអភិវឌ្ឍ, អ្នកគ្រប់គ្រង និងអ្នកប្រើប្រាស់ API យល់ដឹងកាន់តែច្បាស់អំពីលក្ខណៈ, មុខងារ និងរបៀបប្រើប្រាស់ API នោះ។
- **សន្តិសុខលើ API៖** ការរៀបចំ API ត្រូវមានគោលការណ៍នៃការគ្រប់គ្រង និងការការពារសន្តិសុខជាប្រចាំ ដើម្បីធានាបាននូវស្ថិរភាព ដោយគោរពតាមចំណុចសំខាន់ៗ ខាងក្រោម៖
  - រៀបចំឱ្យមានយន្តការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ ឬប្រព័ន្ធ មុននឹងអនុញ្ញាតឱ្យធ្វើការស្នើសុំប្រើប្រាស់ API ដើម្បីធានាបានថារាល់ការចូលទៅប្រើប្រាស់ API គឺមានការអនុញ្ញាតត្រឹមត្រូវ។
  - កំណត់អំពីហានិភ័យដែលអាចកើតឡើង និងមានវិធានការការពារហានិភ័យទាំងនោះ។
  - កំណត់អំពីការផ្លាស់ប្តូរ API តាមរយៈថ្នាល CamDX ដោយសារតែក្នុងនោះមានមុខងារនៃការធ្វើកូដនីយកម្ម, ការចុះហត្ថលេខាឌីជីថល និងការបោះត្រាពេលវេលា ជាដើម។

៤)- **ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ៖** CamDigiKey ជាថ្នាលកំណត់អត្តសញ្ញាណឌីជីថលអ្នកប្រើប្រាស់ដែលអាចឱ្យប្រព័ន្ធផ្សេងៗ ធ្វើសមាហរណកម្ម ហើយអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ធ្វើយថាភូតកម្មផ្ទៀងផ្ទាត់អត្តសញ្ញាណចូលប្រើប្រាស់បានងាយស្រួល និងឆាប់រហ័ស។ ចំពោះការផ្លាស់ប្តូរទិន្នន័យតាមរយៈ API ត្រូវធ្វើឡើងតាមថ្នាល CamDX ដែលប្រើប្រាស់យន្តការសុវត្ថិភាពក្នុងពេលផ្លាស់ប្តូរទិន្នន័យ រួមមាន ការធ្វើកូដនីយកម្ម, ការចុះហត្ថលេខាឌីជីថល, ការបោះត្រាពេលវេលា

ជាដើម។ ថ្នាលឌីជីថលគ្រឹះទាំងនេះ ជាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដែលមានស្រាប់ និងមានថ្នាលបច្ចេកវិទ្យាសម្រាប់គាំទ្ររួចហើយ។

៣.៣.៣. ស្រទាប់ប្រព័ន្ធ ឬកម្មវិធី

ស្រទាប់ប្រព័ន្ធ ឬកម្មវិធី (Application Layer) កំណត់ពីការអភិវឌ្ឍ, ដាក់ដំណើរការ និងគ្រប់គ្រង និងថែទាំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធី ដើម្បីធានាឱ្យបានការប្រើប្រាស់មុខងាររួម និងអន្តរ-ប្រតិបត្តិការជាមួយគ្នា។ គ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបម្រើមុខងារស្នូល និងមុខងាររួមចាំបាច់ត្រូវរៀបចំបញ្ជីនៃមុខងារតម្រូវការ និងមុខងារមិនតម្រូវការនៃប្រព័ន្ធ ហើយមុខងារមិនតម្រូវការនៃប្រព័ន្ធត្រូវគោរពតាមគោលការណ៍ស្តង់ដាដែលបានកំណត់ក្នុងស្រទាប់នេះ។ គោលការណ៍ទាំងនោះ បែងចែកជាផ្នែកធំៗ រួមមាន ការរៀបចំផែនការ និងគ្រប់គ្រងគម្រោង, ការគ្រប់គ្រងគុណភាពនៃកូដ, ការរក្សាសុវត្ថិភាព, ការដំណើរការ, ការពង្រីកវិសាលភាព, ការកំណត់ស្តង់ដាចំណុចប្រទាក់អ្នកប្រើប្រាស់ និងបទពិសោធអ្នកប្រើប្រាស់ (User Interface/User Experience – UI/UX), ការកំណត់ស្តង់ដា API និងការដាក់ឱ្យប្រើប្រាស់ និងថែទាំ ជាដើម។ ក្នុងនោះ តាមផ្នែកនីមួយៗ កំណត់ពីគោលការណ៍សំខាន់ៗ ដែលត្រូវអនុលោម,ស្តង់ដាដែលត្រូវប្រើប្រាស់ ព្រមទាំងឧបករណ៍ដែលពេញនិយមយកមកប្រើប្រាស់ ដោយផ្អែកលើឧត្តមានុវត្តន៍ ជាដើម (ពិនិត្យលម្អិតនៅឧបសម្ព័ន្ធទី ៣)។ សម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបម្រើមុខងារប្រតិបត្តិការ មិនតម្រូវឱ្យចាំបាច់ត្រូវគោរពតាមមុខងារមិនតម្រូវការនោះទេ លុះត្រាតែប្រព័ន្ធនោះក្លាយទៅជាប្រព័ន្ធដែលប្រើប្រាស់រួម។ ***អង្គភាពទាំងអស់ត្រូវពិនិត្យ និងរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនឱ្យស្របទៅតាមស្តង់ដា និងគោលការណ៍ដូចខាងក្រោម។***

ក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ គោលការណ៍ដែលបានដាក់ចេញតាមផ្នែកនីមួយៗ នៅក្នុងស្រទាប់នេះរួមមាន៖

១)- **ការរៀបចំផែនការ និងគ្រប់គ្រងគម្រោង៖** រៀបចំឯកសារផែនការ និងការគ្រប់គ្រងគម្រោងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធីឱ្យបានច្បាស់លាស់ ដែលជួយធានាដល់ការអនុវត្តឱ្យមានប្រសិទ្ធភាព ដោយប្រើប្រាស់ស្តង់ដាណាមួយ ឬច្រើន និងជម្រើសនៃឧបករណ៍ពេញនិយមប្រើប្រាស់ ដូចដែលបានណែនាំលម្អិតនៅក្នុងឧបសម្ព័ន្ធទី ៣ ។

២)- **ការគ្រប់គ្រងគុណភាពនៃកូដ៖** ធានាឱ្យបាននូវគុណភាពនៃកូដរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមបញ្ចូលទាំងការសរសេរកូដឱ្យមានលក្ខណៈស្តង់ដារួម, ងាយស្រួលយល់, ងាយស្រួលថែទាំ ព្រមទាំងមានប្រសិទ្ធភាព និងអាចប្រើប្រាស់ឡើងវិញបាន។ បន្ថែមពីនេះ ការរក្សាសុវត្ថិភាព, ការពង្រីកវិសាលភាព, ការធ្វើតេស្ត និងការរៀបចំឯកសារណែនាំត្រឹមត្រូវ (Documentation) ក៏ត្រូវមានការគិតគូរផងដែរ ដោយប្រើប្រាស់ស្តង់ដាណាមួយ ឬច្រើន និងជម្រើសនៃឧបករណ៍ពេញនិយមប្រើប្រាស់ ដូចដែលបានណែនាំលម្អិតនៅក្នុងឧបសម្ព័ន្ធទី ៣ ។

៣)- **ការរក្សាសុវត្ថិភាព៖** ធានាឱ្យបាននូវសុវត្ថិភាពសម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធីពីការគំរាមកំហែងផ្សេងៗ ដោយប្រើប្រាស់ស្តង់ដាណាមួយ ឬច្រើន និងជម្រើសនៃឧបករណ៍ពេញនិយមប្រើប្រាស់ ដូចដែលបានណែនាំលម្អិតនៅក្នុងឧបសម្ព័ន្ធទី ៣ ។

៤)- **ការធ្វើតេស្ត៖** បង្កើនប្រសិទ្ធភាពនៃការធ្វើតេស្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធី ដើម្បីផ្តល់នូវបទពិសោធដល់អ្នកប្រើប្រាស់ដោយរហូត និងធានាឱ្យបាននូវស្ថិរភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ដោយប្រើប្រាស់ស្តង់ដាណាមួយ ឬច្រើន និងជម្រើសនៃឧបករណ៍ពេញនិយមប្រើប្រាស់ ដូចបង្ហាញក្នុងឧបសម្ព័ន្ធទី ៣ ។

៥)- **ការពង្រីកវិសាលភាព៖** រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធី ដើម្បីអាចពង្រីកវិសាលភាពស្របតាមតម្រូវការនាពេលអនាគត ដោយប្រើប្រាស់ស្តង់ដាណាមួយ ឬច្រើន និងជម្រើសនៃឧបករណ៍ពេញនិយមប្រើប្រាស់ ដូចដែលបានណែនាំលម្អិតនៅក្នុងឧបសម្ព័ន្ធទី ៣ ។

៦)- **ការកំណត់ស្តង់ដា UI/UX៖** ធានាឱ្យបាននូវភាពងាយស្រួលប្រើប្រាស់ (User-Friendly), អាចចូលទៅប្រើប្រាស់បាន និងមានភាពទាក់ទាញ សម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធី ដោយប្រើប្រាស់ស្តង់ដាណាមួយ ឬច្រើន និងជម្រើសនៃឧបករណ៍ពេញនិយមប្រើប្រាស់ ដូចដែលបានណែនាំលម្អិតនៅក្នុងឧបសម្ព័ន្ធទី ៣ ។

៧)- **ការកំណត់ស្តង់ដា API៖** រៀបចំ, អភិវឌ្ឍ និងរក្សានូវ API ស្របតាមឧត្តមានុវត្តន៍ ដើម្បីធានាបាននូវភាពជឿជាក់, ភាពអាចពង្រីកបាន និងភាពងាយស្រួលក្នុងការប្រើប្រាស់ ដូចដែលបានណែនាំលម្អិតនៅក្នុងផ្នែកក្របខ័ណ្ឌអន្តរប្រតិបត្តិការនៃស្រទាប់ទិន្នន័យខាងលើ និងឧបសម្ព័ន្ធទី ៣ ។

៨)- **ការដាក់ឱ្យប្រើប្រាស់ (Deployment) និងថែទាំ៖** ធានាឱ្យបាននូវការដាក់ឱ្យប្រើប្រាស់ប្រកបដោយភាពរហូន និងការថែទាំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធីប្រកបដោយប្រសិទ្ធភាព តាមរយៈការបែងចែកបរិស្ថានអភិវឌ្ឍ (Development Environments) ជា ៣ ផ្នែកធំៗ រួមមាន បរិស្ថានអភិវឌ្ឍកម្មវិធី, បរិស្ថានតេស្តកម្មវិធី និងបរិស្ថានប្រើប្រាស់ ដោយប្រើប្រាស់ស្តង់ដាណាមួយ ឬច្រើន និងជម្រើសនៃឧបករណ៍ពេញនិយមប្រើប្រាស់ ដូចដែលបានណែនាំលម្អិតនៅក្នុងឧបសម្ព័ន្ធទី ៣ ។

៩)- **ការប្រើប្រាស់ហត្ថលេខាឌីជីថល៖** ប្រើប្រាស់ហត្ថលេខាឌីជីថលដែលជាមុខងារមានស្រាប់នៅក្នុងថ្នាល CamDX និងថ្នាល CamDigiKey សម្រាប់គ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានណាដែលមាននូវប្រតិបត្តិការអេឡិចត្រូនិក ហើយមានចរិតលក្ខណៈត្រូវការផ្ទៀងផ្ទាត់ និងការបញ្ជាក់អត្តសញ្ញាណ។

៣.៣.៤. ស្រទាប់បច្ចេកវិទ្យា

កំណត់ពីហេដ្ឋារចនាសម្ព័ន្ធ, ឧបករណ៍បច្ចេកវិទ្យា និងបច្ចេកវិទ្យារួមដែលប្រើប្រាស់ក្នុងដំណើរការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងថ្នាលឌីជីថលគ្រឹះដែលត្រូវបានប្រើប្រាស់ ដើម្បីឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបានរៀបចំ មានស្តង់ដាខ្ពស់ និងអាចប្រើប្រាស់ធនធានរួមឱ្យបានជាអតិបរិមា។ ស្រទាប់នេះបែងចែកជា ៣ ផ្នែករួមមាន ហេដ្ឋារចនាសម្ព័ន្ធឌីជីថលសាធារណៈ, ផ្នែកបច្ចេកវិទ្យាដាក់ដំណើរការរួម និងផ្នែកហេដ្ឋារចនាសម្ព័ន្ធ។ ***អង្គភាពទាំងអស់ត្រូវប្រើប្រាស់ថ្នាលឌីជីថលគ្រឹះ, បច្ចេកវិទ្យា និងគោលការណ៍ដូចដែលបានកំណត់ខាងក្រោម។***

ក្នុងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ គោលការណ៍ដែលបានដាក់ចេញតាមផ្នែកនីមួយៗ នៅក្នុងស្រទាប់នេះរួមមាន៖

(ក) **ផ្នែកថ្នាលឌីជីថលគ្រឹះ ឬនិន្នាការពិភពលោកហៅថាហេដ្ឋារចនាសម្ព័ន្ធឌីជីថលសាធារណៈ៖** សំដៅដល់ការកំណត់ថ្នាលឌីជីថលគ្រឹះសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះសំខាន់សម្រាប់ការធ្វើបរិវត្តកម្មឌីជីថល ហើយក្នុងនោះមានថ្នាលឌីជីថលគ្រឹះយ៉ាងហោចណាស់ ៣ ដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗ ត្រូវតែប្រើប្រាស់ ដែលក្នុងនោះរួមមាន (១)-ថ្នាលផ្លាស់ប្តូរទិន្នន័យ, (២)-ថ្នាលកំណត់អត្ត-

សញ្ញាណឌីជីថល និង (៣)-ថ្នាលទូទាត់សងប្រាក់។ ការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះទាំង ៣ នេះ ជានិន្នាការសកល ដែលកំណត់ពីតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍបច្ចេកវិទ្យារដ្ឋាភិបាល។ ដោយឡែកសម្រាប់ករណីប្រទេសកម្ពុជា ថ្នាលឌីជីថលគ្រឹះទី ៤ គឺជាថ្នាលផ្ទៀងផ្ទាត់ឯកសារ។ ក្នុងន័យនេះ អង្គភាពដែលស្ថិតនៅក្រោមឱវាទ និងអាណាព្យាបាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវប្រើប្រាស់ថ្នាលឌីជីថលគ្រឹះទាំង ៤ ដូចដែលបានរៀបរាប់ខាងក្រោមនេះ ជាចាំបាច់។

១)- ប្រើប្រាស់ថ្នាល CamDX ក្នុងការផ្លាស់ប្តូរទិន្នន័យ សម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់ដែលមានមុខងារផ្លាស់ប្តូរទិន្នន័យ។

២)- ប្រើប្រាស់ថ្នាល CamDigiKey ក្នុងការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ សម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់ដែលមានមុខងារកំណត់អត្តសញ្ញាណឌីជីថល។

៣)- ប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់របស់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ ដែលស្ថិតក្នុងក្របខ័ណ្ឌ ឬជាសមាជិកនៃប្រព័ន្ធបាគង (Bakong) សម្រាប់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ចំពោះគ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់ដែលមានមុខងារទូទាត់សងប្រាក់។

៤)- ប្រើប្រាស់ថ្នាល verify.gov.kh ក្នុងការបញ្ជាក់នីត្យានុកូលកម្មតាមឌីជីថល សម្រាប់ប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានទាំងអស់ដែលមានមុខងារផ្ទៀងផ្ទាត់ឯកសារ។

៥)- ពិនិត្យ និងស្រាវជ្រាវអំពីថ្នាលឌីជីថលគ្រឹះផ្សេងទៀត ដែលនឹងលេចឡើងនៅពេលខាងមុខ ដើម្បីធ្វើការកំណត់ និងដាក់ចូលបន្ថែមទៀតតាមស្ថានភាព និងតម្រូវការដាក់ស្តែង។

(ខ) **ផ្នែកបច្ចេកវិទ្យាជាក់ជំណើរការរួម (MEF Tech Stack)៖** សំដៅដល់ការកំណត់ការប្រើប្រាស់បច្ចេកវិទ្យាដែលមានស្រាប់មួយចំនួន សម្រាប់សម្រួលដល់ការអភិវឌ្ឍ និងដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលត្រូវអភិវឌ្ឍនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នៅក្នុងផ្នែកនេះ កំណត់ពីបញ្ជីនៃបច្ចេកវិទ្យាដែលមានស្រាប់ ទៅតាមវដ្តនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយគិតចាប់ពីការអភិវឌ្ឍ, ការធ្វើតេស្ត, ការដាក់ដំណើរការ, ការតាមដានប្រតិបត្តិការរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការតាមដានសុវត្ថិភាពរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបម្រុងទុកទិន្នន័យ។ បច្ចេកវិទ្យារួមគ្នានេះ បែងចែកជា ៣ ផ្នែករួមមាន (១)-បច្ចេកវិទ្យារួមសម្រាប់ការអភិវឌ្ឍ (Development Tech Stack), (២)-បច្ចេកវិទ្យារួមសម្រាប់ប្រតិបត្តិ និងតាមដាន (Operation/Monitoring Tech Stack) និង (៣)-ស្តង់ដាសុវត្ថិភាពរួម (Security)។ ការប្រើប្រាស់បច្ចេកវិទ្យាដែលមានស្រាប់រួមគ្នាដូច្នេះ គឺក្នុងគោលបំណងឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់មានទំនើបកម្ម និងប្រព័ន្ធសន្តិសុខឌីជីថលប្រហែលគ្នា ហើយក្រុមអ្នកអភិវឌ្ឍកម្មវិធីពីអគ្គនាយកដ្ឋានផ្សេងគ្នា អាចធ្វើការជាមួយគ្នាបាន ព្រមទាំងងាយស្រួលក្នុងការបណ្តុះបណ្តាល និងគាំទ្រផងដែរ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីដែលបម្រើមុខងារស្នូល និងមុខងាររួមចាំបាច់ត្រូវគោរពតាមគោលការណ៍ដែលបានកំណត់ក្នុងស្រទាប់នេះ ហើយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចាស់ត្រូវកែសម្រួលបន្តិចម្តងៗ ដើម្បីឱ្យស្របតាមគោលការណ៍នេះ។

១)- អភិវឌ្ឍគ្រប់ប្រព័ន្ធទាំងអស់ ដោយជ្រើសរើសនូវឧបករណ៍ស្របតាមភាពពាក់ព័ន្ធ តាមផ្នែកសំខាន់ៗ ដែលមានដូចជា ប្រព័ន្ធប្រតិបត្តិការ, ភាសាកម្មវិធី, មូលដ្ឋានទិន្នន័យ, ម៉ាស៊ីនមេ, ប្រព័ន្ធផ្លាស់ប្តូរព័ត៌មាន (Webservice) ដូចដែលបានណែនាំលម្អិតនៅក្នុងឧបសម្ព័ន្ធទី ៤ ។

២)- ប្រតិបត្តិការ និងតាមដានប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់ ដោយជ្រើសរើសនូវឧបករណ៍ស្របតាមភាពពាក់ព័ន្ធតាមផ្នែកសំខាន់ៗ ដែលមានដូចជា ឧបករណ៍សម្រាប់ការគ្រប់គ្រងគម្រោង, គ្រប់គ្រងកូដ និងគ្រប់គ្រងការចូលទៅកាន់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការធ្វើតេស្ត និងតាមដានពីកំហុសឆ្គង, ការធ្វើរបាយការណ៍ ជាដើម ដូចដែលបានណែនាំលម្អិតនៅក្នុងឧបសម្ព័ន្ធទី ៤ ។

៣)- គោរពតាមស្តង់ដាសុវត្ថិភាព ដោយជ្រើសរើសនូវឧបករណ៍ស្របតាមភាពពាក់ព័ន្ធតាមផ្នែកសំខាន់ៗ ដែលមានដូចជា ផ្នែកបណ្តាញតភ្ជាប់, ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការគ្រប់គ្រងអត្តសញ្ញាណ និងការចូលទៅប្រើប្រាស់, ការគ្រប់គ្រងភាពងាយរងគ្រោះ, ការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសន្តិសុខ និងព្រឹត្តិការណ៍, ការឆ្លើយតបឧប្បត្តិហេតុ និងកោសល្យវិច័យ ជាដើម ដូចដែលបានណែនាំលម្អិតនៅក្នុងឧបសម្ព័ន្ធទី ៤ ។

៤)- ស្រាវជ្រាវ និងពិនិត្យមើលជាប្រចាំលើការវិវឌ្ឍនៃបច្ចេកវិទ្យាថ្មីៗ ដូចជា បញ្ញាសិប្បនិម្មិត, ប្លុកឆេន, បច្ចេកវិទ្យាក្លោដ រួមទាំងបច្ចេកវិទ្យាដែលកំពុងលេចឡើងផ្សេងទៀត ដើម្បីធ្វើបច្ចុប្បន្នភាពបច្ចេកវិទ្យាដែលបានកំណត់ក្នុងផ្នែកបច្ចេកវិទ្យាជាក់ដំណើរការរួម។

(គ) ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖ កំណត់ការប្រើប្រាស់ និងការគ្រប់គ្រងកុំព្យូទ័ររួម, បណ្តាញរួម, ការប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យ និងមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យរួម។ កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យា គួរតែអាចប្រើជាមធ្យោបាយ ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានាក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងលក្ខខណ្ឌសុវត្ថិភាព កុំព្យូទ័រទាំងនេះគឺត្រូវប្រើប្រាស់បម្រើតែមុខងាររបស់ស្ថាប័ន ដោយមិនត្រូវយកទៅប្រើប្រាស់ក្នុងការងារផ្ទាល់ខ្លួន។ ការរៀបចំ និងប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ គឺត្រូវប្រើប្រាស់រួមគ្នាលើកលែងតែអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលធ្លាប់បានគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យផ្ទាល់ខ្លួនដាច់ដោយឡែករួចទៅហើយ។ ចំពោះអគ្គនាយកដ្ឋានដទៃទៀត គឺត្រូវប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យរួម ដែលគ្រប់គ្រងដោយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន។ ការប្រើប្រាស់មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យរួម មានគោលការណ៍រួចទៅហើយ ហើយត្រូវអនុលោមទៅតាមគោលការណ៍នោះ។

១)- លេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន មានតួនាទីគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធរួម ដែលរួមមាន ការគ្រប់គ្រងបណ្តាញតភ្ជាប់, មជ្ឈមណ្ឌលទិន្នន័យ, មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ, ម៉ាស៊ីនមេ ជាដើម បម្រើដល់ប្រតិបត្តិការរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់។

២)- អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដែលកំពុងប្រតិបត្តិហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនដាច់ដោយឡែក នឹងបន្តគ្រប់គ្រង និងប្រតិបត្តិហេដ្ឋារចនាសម្ព័ន្ធនោះ លើកលែងមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ ដែលត្រូវប្រើប្រាស់រួម និងគ្រប់គ្រងដោយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន។

៣)- អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវរៀបចំផែនការ ក្នុងការផ្លាស់ប្តូរទីតាំងមជ្ឈមណ្ឌលទិន្នន័យដែលកំពុងប្រតិបត្តិបច្ចុប្បន្ន ទៅកាន់ទីតាំងរួម ដែលគ្រប់គ្រងដោយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន។

៤)- អគ្គនាយកដ្ឋាន និងអង្គភាពទាំងអស់ដែលមិនមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងផ្ទាល់ខ្លួន នឹងត្រូវប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម ដែលគ្រប់គ្រង និងគាំទ្រដោយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន។

៥)- កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាដែលជាមធ្យោបាយសម្រាប់ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវកំណត់ពីលក្ខខណ្ឌសុវត្ថិភាពឱ្យបានច្បាស់លាស់ និងត្រូវប្រើប្រាស់បម្រើដល់មុខងាររបស់ស្ថាប័ន។

៤. យន្តការអនុវត្ត យន្តការស្ថាប័ន និងយន្តការគាំទ្រថវិកា

យន្តការអនុវត្ត យន្តការស្ថាប័ន ព្រមទាំងយន្តការគាំទ្រថវិកា ចាំបាច់ត្រូវរៀបចំឱ្យបានជាក់លាក់ ដើម្បីធានាបាននូវការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។

(ក) យន្តការអនុវត្ត

នៅពេលអនុវត្ត ប្រសិនបើមានអង្គភាពណាមួយស្នើសុំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ដើម្បីសម្រួលដល់ការងារនៅស្ថាប័នរបស់ខ្លួន ស្របតាមការវិភាគមុខងារ, អង្គភាពនោះអាចរៀបចំអភិវឌ្ឍប្រព័ន្ធនោះតាមការស្នើសុំ។ ដូច្នេះ អង្គភាពនោះត្រូវសរសេរការស្នើគម្រោង ដោយគោរពទៅតាមដំហានទាំង ៦ ដូចបង្ហាញក្នុងរូបភាពទី ១១ ខាងក្រោម។ **ដំហានដំបូង,** អង្គភាពដែលជាម្ចាស់ និងជាអ្នកគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ចាំបាច់ត្រូវកំណត់មុខងារតម្រូវការរបស់ប្រព័ន្ធឱ្យបានច្បាស់លាស់ ដែលមុខងារទាំងនោះត្រូវធានាយ៉ាងណាបម្រើដល់គោលបំណង និងបេសកកម្មស្នូលរបស់ស្ថាប័នខ្លួន។ បន្ទាប់មក **ក្នុងដំហានទី ២,** អង្គភាពនោះចាំបាច់ត្រូវកំណត់នូវទិន្នន័យទាំងឡាយណាដែលអាចចែករំលែកបាន ស្របទៅតាមក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យនៅក្នុងស្រទាប់ទិន្នន័យ។ ទន្ទឹមនេះ អង្គភាពជាអ្នកអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវពិនិត្យរៀបចំប្រព័ន្ធ ដោយគោរពតាមក្របខ័ណ្ឌអន្តរប្រតិបត្តិការ ដើម្បីធានាថា ប្រព័ន្ធដែលអភិវឌ្ឍរួចអាចធ្វើអន្តរប្រតិបត្តិការជាមួយប្រព័ន្ធផ្សេងទៀតបាន។ **ដំហានទី ៣,** អង្គភាពជាអ្នកអភិវឌ្ឍប្រព័ន្ធត្រូវពិនិត្យមើលមុខងារតម្រូវការដែលបានកំណត់ក្នុងដំហានទី ១, ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ និងក្របខ័ណ្ឌអន្តរប្រតិបត្តិការ ក្នុងដំហានទី ២ ព្រមទាំងបន្ថែមនូវមុខងារមិនតម្រូវការដោយគោរពតាមឯកសារណែនាំដែលបានកំណត់នៅក្នុងស្រទាប់កម្មវិធី។ **ដំហានទី ៤,** អង្គភាពអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវពិនិត្យមើលថា ប្រព័ន្ធដែលគ្រោងនឹងអភិវឌ្ឍនោះ ត្រូវការមានមុខងារអ្វីខ្លះដែលជាមុខងារដែលមានស្រាប់នៅក្នុងថ្នាលឌីជីថលគ្រឹះរបស់រាជរដ្ឋាភិបាល ឬហេដ្ឋារចនាសម្ព័ន្ធឌីជីថលសាធារណៈ។ ឧទាហរណ៍ដូចជា ប្រសិនបើតម្រូវឱ្យមានមុខងារកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ ត្រូវប្រើប្រាស់ថ្នាល CamDigiKey, ប្រសិនបើតម្រូវឱ្យមានមុខងារផ្លាស់ប្តូរទិន្នន័យ ត្រូវប្រើប្រាស់ថ្នាល CamDX និងប្រសិនបើតម្រូវឱ្យមានមុខងារទូទាត់សងប្រាក់ ត្រូវប្រើប្រាស់ប្រព័ន្ធបាគង ជាដើម។ **ដំហានទី ៥,** អង្គភាពអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវពិនិត្យ និងជ្រើសរើសនូវបច្ចេកវិទ្យា, កម្មវិធី ឬឧបករណ៍ដែលបានកំណត់នៅក្នុងស្រទាប់បច្ចេកវិទ្យា ដើម្បីធានាថាប្រព័ន្ធដែលអភិវឌ្ឍរួចគោរពតាមស្តង់ដាបច្ចេកវិទ្យាខ្ពស់ និងមានសុវត្ថិភាព។ **ដំហានចុងក្រោយ** អង្គភាពអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវធ្វើការជាមួយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន ដើម្បីឱ្យប្រព័ន្ធនោះត្រូវអាចដាក់ឱ្យដំណើរការនៅលើហេដ្ឋារចនាសម្ព័ន្ធរួមគ្នាបាន។ ក្នុងករណីដែលអង្គភាពខ្លះ គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្ទាល់ខ្លួន ក៏ត្រូវពិនិត្យនិងធ្វើការជាមួយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន ដើម្បីពិនិត្យមើលលើទិដ្ឋភាពមួយចំនួនដែលត្រូវដាក់ដំណើរការរួម ដូចជា ទិដ្ឋភាពមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខ (Security Operation Center) ជាដើម។ ក្នុងន័យនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបានអភិវឌ្ឍរួចនឹងមានមុខងារតម្រូវការពេញលេញតាមការកំណត់, អាចប្រើប្រាស់ធនធានរួម, គោរពតាមស្តង់ដាបច្ចេកវិទ្យាត្រឹមត្រូវ និងមានសមត្ថភាពពេញលេញ ក្នុងការធ្វើអន្តរប្រតិបត្តិការផ្លាស់ប្តូរទិន្នន័យ ព្រមទាំងផ្តល់ភាពងាយស្រួលដល់

ក្រុមការងារនៅមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខ (Security Operation Center) អាចបន្តពិនិត្យសុវត្ថិភាពរបស់ប្រព័ន្ធទៀតផង។

រូបភាពទី ១១៖ ដំហាននៃការរៀបចំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយគោរពតាមក្របខ័ណ្ឌ



យោងតាមដំហានខាងលើនេះ, ទោះជាក្នុងករណីអង្គភាពនោះអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយខ្លួនឯង, ផ្តល់ឱ្យអង្គភាពផ្សេងដែលស្ថិតនៅក្រោមអាណាព្យាបាល ឬឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកអភិវឌ្ឍ ឬក៏ផ្តល់ឱ្យក្រុមហ៊ុនផ្តល់សេវាបច្ចេកវិទ្យាជាអ្នកអភិវឌ្ឍក៏ដោយ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននោះ ចាំបាច់ត្រូវអនុលោមតាមក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ បន្ថែមពីលើនេះ គោលការណ៍នៃការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងទម្រង់ជាប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ, ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មី ត្រូវតែជាប្រព័ន្ធមួយដែលដំណើរការដោយឯករាជ្យ និងមានលទ្ធភាពធ្វើអន្តរប្រតិបត្តិការជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀត។ ដូចនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីនោះមិនត្រូវអភិវឌ្ឍ ដោយដាក់បញ្ចូលជាមួយប្រព័ន្ធដែលមានស្រាប់ ក្នុងទម្រង់ជាប្រព័ន្ធបែបរួមធំ ឬប្រព័ន្ធបែបម៉ូឌុល នោះទេ។

បន្ថែមពីលើជំហានដែលបានរៀបរាប់ខាងលើ មានចំណុចសំខាន់ៗ មួយចំនួនទៀត ដែលអង្គភាពទាំងអស់ត្រូវអនុវត្តតាម ដែលក្នុងនោះរួមមាន៖

១)- ចំពោះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានស្រាប់ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្ម និងទំនើបកម្មជាបណ្តើរៗ តាមបន្ទាត់ពេលវេលាមួយ ដើម្បីធានាថា ប្រព័ន្ធនោះបានអនុលោមតាមគោលការណ៍ និងស្តង់ដាដែលបានកំណត់។

២)- ចំពោះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈចាស់ខ្លាំង (Outdated) ត្រូវស្នើរៀបចំប្រព័ន្ធថ្មីឡើងវិញ ដើម្បីឆ្លើយតបទៅនឹងក្របខ័ណ្ឌនិម្មាបនកម្មនេះ ហើយការស្នើនោះ ត្រូវគោរពទៅតាមនីតិវិធីនៃការស្នើគម្រោងដូចទៅនឹងគម្រោងថ្មីដែរ។

៣)- ចំពោះទិន្នន័យនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចាស់ដែលត្រូវរៀបចំថ្មីឡើងវិញ ត្រូវព្យាយាមរក្សា និងផ្ទេរមកប្រើប្រាស់នៅក្នុងប្រព័ន្ធថ្មីនៅពេលដែលប្រព័ន្ធថ្មីអភិវឌ្ឍរួចរាល់។

៤)- អង្គភាពទាំងអស់ចាំបាច់ត្រូវរៀបចំផែនការក្នុងការធ្វើបច្ចុប្បន្នកម្ម និងទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានស្រាប់ ឬស្នើសុំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីជំនួសឱ្យប្រព័ន្ធចាស់ក្នុងក្របខ័ណ្ឌពេលវេលារយៈពេលខ្លី (១ ឆ្នាំ), រយៈពេលមធ្យម (៣ ឆ្នាំ) និងរយៈពេលវែង (៥ ឆ្នាំ) តាមតម្រូវការ និងអាទិភាពជាក់ស្តែង។


ផ្អែកតាមយន្តការអនុវត្តដូចដែលបានរៀបរាប់ខាងលើ អង្គភាពទាំងអស់ត្រូវដាក់ចេញនូវផែនការអនុវត្តលើការប្រតិបត្តិ, គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមការកំណត់ដូចបានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី ៥។

(ខ) យន្តការស្តាប័ន

បន្ទាប់ពីអង្គភាពអនុវត្តគម្រោង រៀបចំគម្រោងស្នើសុំសម្រាប់ការរៀបចំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួចរាល់, គម្រោងស្នើសុំនោះត្រូវដាក់ជូនលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន ដែលជាអង្គភាពបរិវត្តកម្មឌីជីថលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការពិនិត្យលើទិដ្ឋភាពបច្ចេកទេស ជាពិសេសពាក់ព័ន្ធទៅនឹងការកំណត់មុខងារមិនតម្រូវការនៃប្រព័ន្ធ និងការប្រើប្រាស់ធនធានរួមសម្រាប់ការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធ។ បន្ទាប់ពីបានកំណត់ច្បាស់លាស់លើទិដ្ឋភាពបច្ចេកទេសសម្រាប់ការរៀបចំអភិវឌ្ឍប្រព័ន្ធ, អង្គភាពអនុវត្តគម្រោងត្រូវដាក់ស្នើនូវគម្រោងស្នើសុំនោះទាំងទិដ្ឋភាពបច្ចេកទេស និងថវិកាទៅកាន់ក្រុមការងារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុកពិនិត្យ និងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដើម្បីធ្វើការពិនិត្យលម្អិតលើទិដ្ឋភាពថវិកា។ នៅពេលដែលគម្រោងស្នើសុំអភិវឌ្ឍប្រព័ន្ធនោះ បានរៀបចំរួចរាល់ និងត្រឹមត្រូវទាំងទិដ្ឋភាពបច្ចេកទេស និងទិដ្ឋភាពថវិកា, អង្គភាពអនុវត្តគម្រោងអាចដាក់ស្នើគម្រោងនោះទៅកាន់អង្គភាពផ្តល់ហិរញ្ញប្បទាន សម្រាប់អនុវត្តគម្រោង ដើម្បីទទួលបានថវិកាសម្រាប់រៀបចំ។ អង្គភាពផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តគម្រោងអាចមានច្រើនអាស្រ័យទៅលើក្របខ័ណ្ឌការងារ និងប្រភពថវិកាសម្រាប់អនុវត្ត ដែលរួមមានដូចជា ប្រភពថវិកាសម្រាប់ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ថវិកាជាតិ, ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ, ថវិកាកម្ចី, ថវិកាពីដៃគូ និងប្រភពថវិកាស្របច្បាប់ផ្សេងទៀត ជាដើម។ ឧទាហរណ៍ដូចជា គម្រោងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងក្របខ័ណ្ឌ I-PFMIS អាចស្នើទៅគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីទទួលបានមូលនិធិសម្រាប់អនុវត្តគម្រោង។ គម្រោងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាផ្សេងទៀត អាចស្នើទៅអគ្គនាយកដ្ឋានថវិកា ដើម្បីទទួលបានប្រភពថវិកាជាតិសម្រាប់អនុវត្ត, ស្នើទៅអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ដើម្បីប្រើប្រាស់ថវិកាកម្ចីសម្រាប់អនុវត្ត ឬស្នើទៅអគ្គនាយកដ្ឋានភាពជាដៃគូវាងវដ្ត និងឯកជន ដើម្បីប្រើប្រាស់ថវិកាពីដៃគូសម្រាប់អនុវត្តជាដើម។ នៅពេលប្រព័ន្ធបានអភិវឌ្ឍរួចរាល់ និងមុនការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ, អង្គភាពអនុវត្តគម្រោងដែលជាម្ចាស់ប្រព័ន្ធ ឬអ្នកអភិវឌ្ឍប្រព័ន្ធ ត្រូវធ្វើការជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យា

ព័ត៌មាន ដើម្បីត្រួតពិនិត្យលើអនុលោមភាពនៃប្រព័ន្ធ ស្របតាមក្របខ័ណ្ឌនិម្មាបនកម្មនេះ។ រូបភាពទី ១២ ខាងក្រោម បង្ហាញពីយន្តការស្ថាប័ន និងដំណើរការការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

រូបភាពទី ១២៖ យន្តការស្ថាប័នក្នុងការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន



បន្ថែមពីលើយន្តការអនុវត្ត និងយន្តការស្ថាប័នសម្រាប់ក្របខ័ណ្ឌនេះជារួម ដូចបានរៀបរាប់ខាងលើ, អង្គភាពនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចរៀបចំក្របខ័ណ្ឌអនុវត្ត ឬឯកសារណែនាំលម្អិត សម្រាប់ផ្ទៃក្នុងរបស់ខ្លួន ដោយគោរពទៅតាមគោលការណ៍ដែលបានដាក់ចេញនៅក្របខ័ណ្ឌរួមនេះ។ ឧទាហរណ៍ដូចជា សម្រាប់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលជាអាជ្ញាធរឯករាជ្យ អាចរៀបចំក្របខ័ណ្ឌអនុវត្ត សម្រាប់និយ័តករ និងអង្គភាពក្រោមឱវាទរបស់ខ្លួនដោយគោរពទៅតាមគោលការណ៍នៅក្នុងក្របខ័ណ្ឌរួមនេះ។

៥. សន្និដ្ឋាន

ឈរលើមូលដ្ឋានដ៏ច្បាស់លាស់ ក្នុងការទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាព័ត៌មានសម្រាប់ការបង្កើនប្រសិទ្ធភាពការងារស្នូលតាមអង្គភាពទាំងអស់ និងរួមចំណែកដល់ដំណើរនៃការធ្វើបរិវត្តកម្មឌីជីថលរបស់រាជរដ្ឋាភិបាលកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវ "**ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" ដោយដាក់ចេញនូវគោលបំណងក្នុងការធ្វើសុខដុមនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងទម្រង់ជាប្រព័ន្ធអេកូឡូស៊ីឌីជីថលបែបវិមជ្ឈការ សំដៅដល់ការធ្វើបរិវត្តកម្មឌីជីថល ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ គោលការណ៍ក្នុងការអនុវត្តឯកសារក្របខ័ណ្ឌនេះ នឹងគោរពទៅតាមក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ។ អភិក្រមនៃឯកសារក្របខ័ណ្ឌនេះគឺកំណត់យកសមាសភាគសំខាន់ធំ ៣ រួមមាន មនុស្ស, បច្ចេកវិទ្យា និងដំណើរការ។ និម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានគិតគូរ ប្រកបដោយភាពប្រាកដនិយមខ្ពស់ តាមរយៈការពិនិត្យមើលយ៉ាងល្អិតល្អន់ទៅលើស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ឧត្តមានុវត្តន៍អន្តរជាតិលើការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, អនុសាសន៍ពីដៃគូពាក់ព័ន្ធ ព្រមទាំងការពិគ្រោះយោបល់ជាមួយអង្គភាពក្រោមអាណាព្យាបាល និងឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់។ ប្រការនេះបានផ្តល់នូវមូលដ្ឋានយ៉ាងរឹងមាំ ដល់ការដាក់ចេញនូវនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីអាចឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលកំពុងជួបប្រទះ និងបង្កើនប្រសិទ្ធភាពការងារឱ្យបានកាន់តែខ្ពស់។

ក្របខ័ណ្ឌនេះមានគោលដៅកំណត់មុខងាររបស់អង្គភាពលើការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, រៀបចំក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ, រៀបចំក្របខ័ណ្ឌអន្តរប្រតិបត្តិការ, កំណត់សេចក្តីណែនាំជាស្តង់ដាសម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងជំរុញការប្រើប្រាស់បច្ចេកវិទ្យា និងធនធានរួម។ ដើម្បីឱ្យស្របជាមួយនឹងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥, ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក៏នឹងអនុវត្តគោរពទៅតាមគោលការណ៍សំខាន់ៗ រួមមាន គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក, គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ និងគោលការណ៍ផ្តួចផ្តើម និងពង្រីកដើម្បីប្រសិទ្ធភាព។ បន្ថែមពីលើគោលការណ៍ទាំង ៣ នេះ ក្របខ័ណ្ឌនេះ បានបន្ថែមនូវគោលការណ៍រួមសំខាន់ៗ ចំនួន ៦ ទៀត សម្រាប់ការអនុវត្ត រួមមាន ភាពជាម្ចាស់, អន្តរប្រតិបត្តិការ, ស្តង់ដាអភិវឌ្ឍ, ទិន្នន័យបើកចំហ, បច្ចេកវិទ្យា និងធនធានរួម និងគុណភាព និងប្រសិទ្ធភាព។

និម្មាបនកម្មសហគ្រាស បានយកមកប្រើប្រាស់ និងបានកែសម្រួលតាមបរិការណ៍ជាក់ស្តែង ដែលក្នុងនោះបានបែងចែកជា ៤ ស្រទាប់ធំៗ រួមមាន (១)-ស្រទាប់មុខងារធុរកិច្ច កំណត់ពីគោលបំណង និងគោលដៅរបស់ស្ថាប័ន, មុខងារ និងធនធានមនុស្ស, (២)-ស្រទាប់ទិន្នន័យ កំណត់ពីការរៀបចំក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ ដើម្បីគ្រប់គ្រង និងចែករំលែក ព្រមទាំងក្របខ័ណ្ឌអន្តរប្រតិបត្តិការ ក្នុងការធ្វើសន្ធានកម្មទិន្នន័យគ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធ, (៣)-ស្រទាប់ប្រព័ន្ធ ឬកម្មវិធី កំណត់ពីការអភិវឌ្ឍ, ការដាក់ដំណើរការ និងការគ្រប់គ្រងតាមដានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធី ដើម្បីធានាបានការប្រើប្រាស់មុខងាររួម និងអន្តរប្រតិបត្តិការជាមួយគ្នា ព្រមទាំងធានាបាននូវសុវត្ថិភាពសម្រាប់ប្រព័ន្ធបច្ចេកវិទ្យា

ព័ត៌មានផងដែរ និង (៤)-ស្រទាប់បច្ចេកវិទ្យា កំណត់ពីហេដ្ឋារចនាសម្ព័ន្ធ, ឧបករណ៍បច្ចេកវិទ្យា និងបច្ចេកវិទ្យាដែលប្រើប្រាស់ក្នុងការដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងថ្នាលឌីជីថលគ្រឹះដែលត្រូវប្រើប្រាស់ ដើម្បីឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបានរៀបចំមានស្តង់ដា និងប្រើប្រាស់ធនធានរួម។ តាមស្រទាប់នីមួយៗ បានដាក់ចេញនូវគោលការណ៍ និងស្តង់ដារួម សម្រាប់អង្គភាពទាំងអស់អនុវត្តតាម ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅដែលបានដាក់ចេញ។

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទីដឹកនាំ, សម្របសម្រួល និងតាមដានជាប្រចាំ លើការអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ។ អង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ត្រូវចូលរួមអនុវត្តក្របខ័ណ្ឌនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅសម្រេចបាននូវគោលបំណងដែលបានដាក់ចេញ។ ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាជា "**ឯកសាររស់**" ដែលអាចនឹងត្រូវកែសម្រួលជាយថាហេតុ ដើម្បីធានានូវសង្គតិភាព និងភាពសមស្របទៅតាមការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ក៏ដូចជាការវិវឌ្ឍជាក់ស្តែងនៃស្ថានការណ៍សេដ្ឋកិច្ច និងសង្គម។

ឧបសម្ព័ន្ធ ១. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងតួនាទីនៃអង្គភាពក្នុងក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ

ល.រ.	បំណែងចែកមុខងារ	ប្រព័ន្ធ	ប្រធានទិន្នន័យ	បុគ្គលគ្រប់គ្រងទិន្នន័យ	បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ
១	ការគ្រប់គ្រងចំណូល	**ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ**	**វិស័យឯកជន, ក្រសួង ស្ថាប័ន**	**GDT**	
២		ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ	វិស័យឯកជន	GDT	GDNT
៣		ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ	វិស័យឯកជន	GDT	GDNT
៤		ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក	វិស័យឯកជន	GDT	GDNT
៥		ប្រព័ន្ធគ្រប់គ្រងបង់ប្រាក់ពន្ធតាមអនឡាញ	វិស័យឯកជន	GDT	GDNT
៦		ប្រព័ន្ធគ្រប់គ្រងការស្នើសុំការលើកទឹកចិត្ត	វិស័យឯកជន	GDT	GDNT
៧		**ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធគយ**	**វិស័យឯកជន**	**GDCE**	
៨		ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា)	វិស័យឯកជន	GDCE	GDNT
៩		ប្រព័ន្ធអាស៊ីហាប់ (ASYHUB)	វិស័យឯកជន	GDCE	GDNT
១០		ប្រព័ន្ធអេឡិចត្រូនិកគយ (e-Customs)	វិស័យឯកជន	GDCE	GDNT
១១		ប្រព័ន្ធបញ្ជរតែមួយអាស៊ាន (ASW)	វិស័យឯកជន	GDCE	GDNT
១២		ប្រព័ន្ធបញ្ជរតែមួយជាតិ (CNSW)	វិស័យឯកជន	GDCE	GDNT

១៣		ប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ACTS)	វិស័យឯកជន	GDCE	GDNT
១៤		ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស (GTAS)	វិស័យឯកជន	GDCE	GDNT
១៥		NRMIS	វិស័យឯកជន, ក្រសួង ស្ថាប័ន	GDSNR	ក្រសួង ស្ថាប័ន, GDNT
១៦	ការអនុវត្តចំណូល-ចំណាយ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យនៃថវិការដ្ឋ	FMIS	ក្រសួង ស្ថាប័ន, GDB, GDNT, GDPP, GDPFMIT	GDB, GDNT, GDPP, GDPFMIT	GDNT, GDP
១៧		ប្រព័ន្ធលទ្ធកម្មសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក (e-GP)	ក្រសួង ស្ថាប័ន	GDPP	GDNT
១៨	ការវិនិយោគសាធារណៈ	PPDMS	ក្រសួង ស្ថាប័ន	GDICDM	ក្រសួង ស្ថាប័ន
១៩		DMFAS	ក្រសួង ស្ថាប័ន	GDICDM	ក្រសួង ស្ថាប័ន
២០		ប្រព័ន្ធគ្រប់គ្រងទិន្នន័យវិនិយោគសាធារណៈ	ក្រសួង ស្ថាប័ន	GDB	ក្រសួង ស្ថាប័ន
២១	ឧស្សាហកម្មហិរញ្ញវត្ថុ	ប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យ	វិស័យឯកជន	អ.ស.ហ., និយ័តករ	GS-FSA
២២		ប្រព័ន្ធបច្ចេកវិទ្យានិយ័តកម្ម	វិស័យឯកជន	អ.ស.ហ., និយ័តករ	GS-FSA
២៣		ប្រព័ន្ធគ្រប់គ្រងអាជ្ញាបណ្ណ ក្នុងវិស័យល្បែងពាណិជ្ជកម្ម	វិស័យឯកជន	CGMC	CGMC
២៤	រដ្ឋបាល, ធនធានមនុស្ស, សារពើភណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ និងសេវាសាធារណៈ	ប្រព័ន្ធគ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា (MEF Profile)	អង្គភាពក្រោមឱវាទ MEF	GS	GS
២៥		ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិផ្ទៃក្នុង MEF	អង្គភាពក្រោមឱវាទ MEF	GS	GS
២៦		SARMIS	ក្រសួង ស្ថាប័ន	GDSNR	GDNT
២៧		ប្រព័ន្ធបណ្តុះបណ្តាលពីចម្ងាយ	EFI	EFI	GS

២៨		ប្រព័ន្ធចុះបញ្ជីអាជីវកម្ម (ដំណាក់កាលទី ១)	វិស័យឯកជន	GDT, MOC, MLVT	GDT, MOC, MLVT
២៩		ប្រព័ន្ធចុះបញ្ជីអាជីវកម្ម (ដំណាក់កាលទី ២ និងទី ៣)	វិស័យឯកជន	ក្រសួង ស្ថាប័ន	ក្រសួង ស្ថាប័ន
៣០		ប្រព័ន្ធផ្តល់អាជ្ញាបណ្ណ	វិស័យឯកជន	GDT	GDT
៣១		ប្រព័ន្ធផ្តល់អាជ្ញាបណ្ណ	វិស័យឯកជន	GDCE	GDCE
៣២		CamDX	វិស័យឯកជន, ក្រសួង ស្ថាប័ន	វិស័យឯកជន, ក្រសួង ស្ថាប័ន	វិស័យឯកជន, ក្រសួង ស្ថាប័ន
៣៣		ប្រព័ន្ធសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ	វិស័យឯកជន	MISTI	ក្រសួង ស្ថាប័ន
៣៤		ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក (E-invoice)	វិស័យឯកជន	GDDE	វិស័យឯកជន, ក្រសួង ស្ថាប័ន
៣៥	ទិន្នន័យ, ម៉ាក្រូសេដ្ឋកិច្ច, សវនកម្ម និងអធិការកិច្ច	PIP DBMS	ក្រសួង ស្ថាប័ន	GDP	GDP
៣៦		ថ្នាលឌីជីថលធុរកិច្ចថ្មីកម្ពុជា	វិស័យឯកជន	TSC	វិស័យឯកជន, ក្រសួង ស្ថាប័ន
៣៧		ថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស	វិស័យឯកជន	TSC	វិស័យឯកជន, ក្រសួង ស្ថាប័ន
៣៨		SAAT	អង្គភាពក្រោមឱវាទ MEF	GDIA	GDIA
៣៩		M & E Portal	ក្រសួង ស្ថាប័ន	DEBC	ក្រសួង ស្ថាប័ន
៤០		Data EF	ក្រសួង ស្ថាប័ន	GDDE	ក្រសួង ស្ថាប័ន
៤១		ប្រព័ន្ធអេឡិចត្រូនិកកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ	កន្លែងផ្តល់សេវាសុខាភិបាល	NPCA	NSPC

ឧបសម្ព័ន្ធ ២. បញ្ជីទិន្នន័យរបស់អង្គភាពសម្រាប់ការផ្លាស់ប្តូរ

អថេរ	ប្រភេទទិន្នន័យ	មុខងារ	ភាពទៀងទាត់	វិធីសាស្ត្រ	ភាពសើប
១. ការគ្រប់គ្រងចំណូល					
១. អគ្គនាយកដ្ឋានពន្ធដារ					
I. ចំណូលតាមប្រភេទពន្ធ (COA)					
ចំណូលថវិកាថ្នាក់ជាតិ					
១. ពន្ធលើប្រាក់ចំណូល - ពន្ធលើប្រាក់ចំណូល (រូបវន្តបុគ្គល) - ពន្ធលើប្រាក់ចំណូល (នីតិបុគ្គល) - ពន្ធលើប្រាក់បៀវត្ស - អាករលើផលរបរ - អាករលើតម្លៃបន្ថែម	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
២. អាករពិសេស - អាករពិសេសលើទំនិញមួយចំនួន - អាករពិសេសលើសេវាមួយចំនួន - ប្រាក់ទោសទណ្ឌសារពើពន្ធ	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
ចំណូលថវិកាថ្នាក់ក្រោមជាតិ					
១. ពន្ធលើឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ - ពន្ធលើឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ (រូបវន្តបុគ្គល) - ពន្ធលើឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ (នីតិបុគ្គល) - អាករសម្រាប់បំភ្លឺសាធារណៈ	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង

- អាករលើការស្នាក់នៅ - ពន្ធសត្តឃាត - ពន្ធប៉ាតង់ - ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ					
២. ពន្ធប្រថាប់ត្រា - ពន្ធប្រថាប់ត្រាលើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ - ពន្ធប្រថាប់ត្រាលើតម្លៃមធ្យោបាយដឹកជញ្ជូន ឬយានយន្តចំពោះការផ្ទេរកម្មសិទ្ធិ - ពន្ធប្រថាប់ត្រាលើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន - ពន្ធប្រថាប់ត្រាលើតម្លៃកិច្ចសន្យាចំពោះការផ្តត់ផ្តង់ទំនិញ ឬសេវា - ពន្ធប្រថាប់ត្រាលើលិខិតមានលក្ខណៈគតិយុត្ត	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
៣. ពន្ធលើអចលនទ្រព្យ - ពន្ធលើអចលនទ្រព្យ (រូបវន្តបុគ្គល) - ពន្ធលើអចលនទ្រព្យ (នីតិបុគ្គល) - ពន្ធលើដីធ្លីមិនបានប្រើប្រាស់ - ពន្ធតែមប្រ៊ី	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
ចំណូលមិនមែនសារពើពន្ធ					
- លក់ឯកសារ កតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ - ផលពីការបង្កើតសហគ្រាស - សេវាលើពន្ធប្រថាប់ត្រា - ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង

- ផលហិរញ្ញវត្ថុផ្សេងទៀត					
II. ចំណូលតាមប្រភេទអ្នកជាប់ពន្ធ					
- អ្នកជាប់ពន្ធធំ - អ្នកជាប់ពន្ធមធ្យម - អ្នកជាប់ពន្ធតូច - ផ្សេងៗ (ពន្ធលើឈ្នួលផ្ទះ-ដី, ពន្ធលើមធ្យោបាយ, ពន្ធប្រថាប់ត្រាលើអចលនទ្រព្យ និងយានយន្ត, ពន្ធលើអចលនទ្រព្យ, ពន្ធលើដីធ្លីមិនប្រើប្រាស់ និងពិន័យពីប្រភេទពន្ធទាំងនេះ)	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
III. ចំណូលតាមសាខា (តួលេខពីប្រព័ន្ធ FMIS)	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
IV. ព័ត៌មានក្នុងសលាកបត្រចំណូល (តួលេខពីប្រព័ន្ធ FMIS)	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
V. ទិន្នន័យសហគ្រាសចុះបញ្ជី					
- ឈ្មោះសហគ្រាសជាភាសាខ្មែរ - ឈ្មោះសហគ្រាសជាអក្សរឡាតាំង - សកម្មភាពអាជីវកម្មចម្បង - អាសយដ្ឋានសហគ្រាស - លេខទូរស័ព្ទ - លេខអត្តសញ្ញាណកម្មសារពើពន្ធ - ទ្រង់ទ្រាយសហគ្រាស - ស្ថានភាពទូទៅរបស់សហគ្រាស - ការបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង

VI. ទិន្នន័យអំពីការប្រកាស និងបង់ពន្ធប៉ាតង់	ទិន្នន័យគោល	Data Custodian	ប្រចាំខែ		ផ្ទៃក្នុង
- ឈ្មោះសហគ្រាសជាភាសាខ្មែរ - ឈ្មោះសហគ្រាសជាអក្សរឡាតាំង - សកម្មភាពអាជីវកម្មចម្បង - អាសយដ្ឋានសហគ្រាស - លេខទូរស័ព្ទ - លេខអត្តសញ្ញាណកម្មសារពើពន្ធ - ទ្រង់ទ្រាយសហគ្រាស - ស្ថានភាពទូទៅរបស់សហគ្រាស - ការបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
២. អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា					
ព័ត៌មានសលាកបត្រចំណូល	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ		ផ្ទៃក្នុង
៣. អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ					
ទិន្នន័យចំណូល	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
ចំណូលតាមប្រភេទសេវា	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
ចំណូលតាមក្រសួង ស្ថាប័ន	ប្រតិបត្តិការ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
ទិន្នន័យអំពីក្រុមហ៊ុន និងនីតិបុគ្គល	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង

២. ការអនុវត្តចំណូល-ចំណាយ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យនៃថវិការដ្ឋ					
១. អគ្គនាយកដ្ឋានថវិកា					
ចំណាត់ថ្នាក់ថវិកា - ចំណាត់ថ្នាក់រដ្ឋបាល - ចំណាត់ថ្នាក់សេដ្ឋកិច្ច - ចំណាត់ថ្នាក់កម្មវិធី - ចំណាត់ថ្នាក់គម្រោង (វិនិយោគក្នុងស្រុក) - ចំណាត់ថ្នាក់មុខងារ	ទិន្នន័យមេ	ប្រធានទិន្នន័យ	ខែ, ត្រីមាស, ឆមាស, ៩ ខែ, ប្រចាំឆ្នាំ	PDF	សាធារណៈ
ច្បាប់ថវិកា (ចំណូល-ចំណាយ)	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ខែ, ត្រីមាស, ឆមាស, ៩ ខែ, ប្រចាំឆ្នាំ	PDF	សាធារណៈ
ការអនុវត្តថវិកា (ចំណូល-ចំណាយ)	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ខែ, ត្រីមាស, ឆមាស, ៩ ខែ, ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ផែនការវិនិយោគ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ខែ, ត្រីមាស, ឆមាស, ៩ ខែ, ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ការអនុវត្តគម្រោងវិនិយោគ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ខែ, ត្រីមាស, ឆមាស, ៩ ខែ, ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
របាយការណ៍ហិរញ្ញវត្ថុ (Financial Statement)	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ខែ, ត្រីមាស, ឆមាស, ៩ ខែ, ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង

២. អគ្គនាយកដ្ឋានរតនាគារជាតិ					
ចំណាត់ថ្នាក់ថវិកាទាំង ៧ - ចំណាត់ថ្នាក់រដ្ឋបាល - ចំណាត់ថ្នាក់សេដ្ឋកិច្ច - ចំណាត់ថ្នាក់កម្មវិធី - ចំណាត់ថ្នាក់គម្រោង - ចំណាត់ថ្នាក់មុខងារ - ចំណាត់ថ្នាក់មូលនិធិ - ចំណាត់ថ្នាក់ភូមិសាស្ត្រ	ទិន្នន័យគោល	បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	PDF	សាធារណៈ
មាតិកាគណនីនៃប្លង់គណនេយ្យ	ទិន្នន័យគោល	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ច្បាប់ថវិកា (ចំណូល-ចំណាយ)	ស្ថិតិ ឬរបាយការណ៍	បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	PDF	សាធារណៈ
ការអនុវត្តថវិកា និងរបាយការណ៍ចំណូល ចំណាយថវិកា	ស្ថិតិ ឬរបាយការណ៍	ប្រធានទិន្នន័យ	ប្រចាំថ្ងៃ ត្រីមាស ឆមាស	Excel & PDF	ផ្ទៃក្នុង
កិច្ចបញ្ជិកាគណនេយ្យ	ស្ថិតិ ឬរបាយការណ៍	ប្រធានទិន្នន័យ	ប្រចាំថ្ងៃ ត្រីមាស ឆមាស	Excel & PDF	ផ្ទៃក្នុង
គណនីទោលរតនាគារ និងគ្រប់គ្រងសាច់ប្រាក់	ស្ថិតិ ឬរបាយការណ៍	ប្រធានទិន្នន័យ	ប្រចាំថ្ងៃ ត្រីមាស ឆមាស	Excel & PDF	ផ្ទៃក្នុង
របាយការណ៍ហិរញ្ញវត្ថុ (Financial Statement)	ស្ថិតិ ឬរបាយការណ៍	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ	ស្ថិតិ ឬរបាយការណ៍	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	PDF	សាធារណៈ
របាយការណ៍ International Public Sector Accounting Standards (IPSAS)	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង

៣. អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ					
ចំណាត់ថ្នាក់ថវិកាទាំង ៧ - ចំណាត់ថ្នាក់រដ្ឋបាល - ចំណាត់ថ្នាក់សេដ្ឋកិច្ច - ចំណាត់ថ្នាក់កម្មវិធី - ចំណាត់ថ្នាក់គម្រោង - ចំណាត់ថ្នាក់មុខងារ - ចំណាត់ថ្នាក់មូលនិធិ - ចំណាត់ថ្នាក់ភូមិសាស្ត្រ	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ច្បាប់ថវិកា (ចំណូល-ចំណាយ)	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	PDF	សាធារណៈ
ការអនុវត្តថវិកា	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ត្រីមាស ឆមាស	Excel & PDF	ផ្ទៃក្នុង
ការធ្វើនិយ័តកម្មថវិកា	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ត្រីមាស ឆមាស	Excel & PDF	ផ្ទៃក្នុង
កិច្ចបញ្ជិកាគណនេយ្យ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ត្រីមាស ឆមាស	Excel & PDF	ផ្ទៃក្នុង
របាយការណ៍ហិរញ្ញវត្ថុ (Financial Statement)	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
៤. អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ					
ចំណាត់ថ្នាក់ថវិកាទាំង ៧	ទិន្នន័យគោល	បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង

ផែនការកិច្ចលទ្ធកម្ម	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
សេចក្តីជូនដំណឹងការដេញថ្លៃ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំ ឆមាស និងឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ការប្រគល់កិច្ចសន្យា	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំ ឆមាស និងឆ្នាំ	Excel & PDF	ផ្ទៃក្នុង
បញ្ជីឈ្មោះអ្នកដេញថ្លៃ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំ ឆមាស និងឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ទិន្នន័យចុះបញ្ជីអ្នកដេញថ្លៃ	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel	ផ្ទៃក្នុង
ទិន្នន័យក្រុមហ៊ុននៅក្នុងបញ្ជីខ្មៅ (Blacklist)	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel	ផ្ទៃក្នុង
របាយការណ៍អនុវត្តកិច្ចលទ្ធកម្ម	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
៥. អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ					
ចំណាត់ថ្នាក់ថវិកាទាំង ៧	ស្ថិតិ ឬរបាយការណ៍	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ច្បាប់ថវិកា (ចំណូល-ចំណាយ) ថ្នាក់ក្រោមជាតិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	PDF	សាធារណៈ
ការអនុវត្តថវិកា ថ្នាក់ក្រោមជាតិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ត្រីមាស, ឆមាស, ៩ខែ, ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
របាយការណ៍ហិរញ្ញវត្ថុ (Financial Statement)	ស្ថិតិ ឬរបាយការណ៍	បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង

៥. អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល					
ចំណាត់ថ្នាក់ថវិកា - ចំណាត់ថ្នាក់គម្រោង (ហិរញ្ញប្បទានក្រៅស្រុក) - ចំណាត់ថ្នាក់មូលនិធិ - ទំហំមូលនិធិ - ការអនុវត្តគម្រោង - ផែនការថវិកាវិនិយោគ (ក្រៅស្រុក&បដិភាគ) - ការអនុវត្តថវិកាវិនិយោគ (ក្រៅស្រុក&បដិភាគ) - បំណុលសាធារណៈ	ស្ថិតិ ឬរបាយការណ៍	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	ទាញចេញពី FMIS	ផ្ទៃក្នុង
៣. ការវិនិយោគសាធារណៈ:					
១. អគ្គនាយកដ្ឋានថវិកា					
ឈ្មោះគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ប្រភេទមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ប្រភពមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ទំហំមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ឆ្នាំអនុវត្តគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ប្រភេទគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង

វិស័យដែលអភិវឌ្ឍ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ស្ថានភាពនៃការអភិវឌ្ឍគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ព័ត៌មានវដ្តនៃគម្រោង - ធ្វើអត្តសញ្ញាណកម្មគម្រោង - ត្រួតពិនិត្យ និងវាយតម្លៃ - ត្រួតពិនិត្យអនុលោមភាព - ពិនិត្យ និងឋវិកានីយកម្ម - គ្រប់គ្រង និងអនុវត្តគម្រោង - កែសម្រួលគម្រោង - ការប្រើប្រាស់ និងចុះបញ្ជីទ្រព្យរដ្ឋ - បិទបញ្ចប់គម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
២. អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ					
ឈ្មោះគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ប្រភេទមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ប្រភពមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ទំហំមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង

ឆ្នាំអនុវត្តគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ប្រភេទគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
វិស័យដែលអភិវឌ្ឍ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ស្ថានភាពនៃការអភិវឌ្ឍគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ព័ត៌មានវដ្តនៃគម្រោង - ធ្វើអត្តសញ្ញាណកម្មគម្រោង - ការរៀបចំគម្រោងអាទិភាព - ការត្រួតពិនិត្យអនុលោម និងសមាហរណកម្មគម្រោងនៅថ្នាក់រាជធានី ខេត្ត - ការធ្វើថវិកានីយកម្ម - ការរៀបចំឯកសារគម្រោង និងអនុវត្តគម្រោង - ការកែសម្រួលគម្រោង - ការប្រើប្រាស់ និងចុះបញ្ជីទ្រព្យរដ្ឋ - ការវាយតម្លៃបញ្ចប់គម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
៣. អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល					
ឈ្មោះគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel, PDF, PPDMS	ផ្ទៃក្នុង
ប្រភេទមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel, PDF, PPDMS	ផ្ទៃក្នុង

ប្រភពមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel, PDF, PPDMS	ផ្ទៃក្នុង
ទំហំមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel, PDF, PPDMS	ផ្ទៃក្នុង
ឆ្នាំអនុវត្តគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel, PDF, PPDMS	ផ្ទៃក្នុង
ប្រភេទគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel, PDF, PPDMS	ផ្ទៃក្នុង
គម្រោងអនុវត្តតាមវិស័យ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel, PDF, PPDMS	ផ្ទៃក្នុង
វឌ្ឍនភាពនៃការអភិវឌ្ឍគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel, PDF, PPDMS	ផ្ទៃក្នុង
ព័ត៌មានវដ្តនៃគម្រោង - ធ្វើអត្តសញ្ញាណកម្មគម្រោង - ត្រួតពិនិត្យ និងវាយតម្លៃ - ត្រួតពិនិត្យអនុលោមភាព - ពិនិត្យ និងថវិកានីយកម្ម - គ្រប់គ្រង និងអនុវត្តគម្រោង - កែសម្រួលគម្រោង - ការប្រើប្រាស់ និងចុះបញ្ជីទ្រព្យរដ្ឋ - បិទបញ្ចប់គម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel, PDF, PPDMS	ផ្ទៃក្នុង

៤. អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន					
ប្រភេទមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ឈ្មោះគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel, PDF	ផ្ទៃក្នុង
ប្រភពមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ទំហំមូលនិធិ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ឆ្នាំអនុវត្តគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ប្រភេទគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
វិស័យដែលអភិវឌ្ឍ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ស្ថានភាពនៃការអភិវឌ្ឍគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ព័ត៌មានវដ្តនៃគម្រោង - ធ្វើអត្តសញ្ញាណកម្មគម្រោង - ត្រួតពិនិត្យ និងវាយតម្លៃ - ត្រួតពិនិត្យអនុលោមភាព - ពិនិត្យ និងបរិការនីយកម្ម - គ្រប់គ្រង និងអនុវត្តគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង

- កែសម្រួលគម្រោង - ប្រើប្រាស់ និងចុះបញ្ជីទ្រព្យរដ្ឋ - បិទបញ្ចប់គម្រោង					
៥. អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ					
ព័ត៌មានរូបធាតុនៃទ្រព្យ - លេខអត្តសញ្ញាណនៃទ្រព្យ - លេខកូដរដ្ឋបាលរបស់អង្គភាពប្រើប្រាស់ - លេខកូដភូមិសាស្ត្ររបស់អង្គភាពប្រើប្រាស់ - លេខសម្គាល់ចំណាត់ថ្នាក់ទ្រព្យ - លេខកូដសម្គាល់ទ្រព្យ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ព័ត៌មានហិរញ្ញវត្ថុ - ចំណាត់ថ្នាក់ថវិកាទាំង ៧ - ថ្លៃដើមនៃទ្រព្យ - អាយុកាលប្រើប្រាស់ - តម្លៃកាកសំណល់ - តម្លៃរំលស់	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ទ្រព្យបែងចែកតាមគម្រោង	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
៦. អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍					
ព័ត៌មានអំពីផលប៉ះពាល់ - តារាងថវិកាប៉ាន់ស្មានសម្រាប់គ្រោងចំណាយការងារដោះស្រាយផលប៉ះពាល់ប្រចាំឆ្នាំ - ផែនការដោះស្រាយផលប៉ះពាល់	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង

៤. ឧស្សាហកម្មហិរញ្ញវត្ថុ					
១. និយ័តករមូលបត្រកម្ពុជា					
I. ទីផ្សារមូលបត្រកម្មសិទ្ធិ					
១. ទីផ្សារគោល					
ចំនួនបុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ (លានរៀល)	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ (ដុល្លារអាមេរិក)	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
មូលធនូបនីយកម្មទីផ្សារ (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
មូលធនូបនីយកម្មទីផ្សារ (ដុល្លារអាមេរិក)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ទំហំជួញដូរសរុប (ភាគហ៊ុន)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
តម្លៃជួញដូរសរុប (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ

ទំហំដួញដូរជាមធ្យម (ភាគហ៊ុន)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
តម្លៃដួញដូរជាមធ្យម (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
២. ទីផ្សារកំណើន					
ចំនួនបុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ (លានរៀល)	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ (ដុល្លារអាមេរិក)	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
មូលធនូបនីយកម្មទីផ្សារ (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
មូលធនូបនីយកម្មទីផ្សារ (ដុល្លារអាមេរិក)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ទំហំដួញដូរសរុប (ភាគហ៊ុន)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
តម្លៃដួញដូរសរុប (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ

ទំហំជួញដូរជាមធ្យម (តាគហ៊ុន)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
តម្លៃជួញដូរជាមធ្យម (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
៣. ទីផ្សារទាំងពីរ					
ចំនួនបុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ (លានរៀល)	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ (ដុល្លារអាមេរិក)	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
មូលធនូបនីយកម្មទីផ្សារ (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
មូលធនូបនីយកម្មទីផ្សារ (ដុល្លារអាមេរិក)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ទំហំជួញដូរសរុប (តាគហ៊ុន)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ

តម្លៃជួញដូរសរុប (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ទំហំជួញដូរជាមធ្យម (ភាគហ៊ុន)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
តម្លៃជួញដូរជាមធ្យម (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនថ្ងៃជួញដូរ	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
សន្ទស្សន៍ ផមក (បិទ)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
II. ទីផ្សារមូលបត្របំណុល					
ចំនួនបុគ្គលចុះបញ្ជីលក់មូលបត្របំណុល	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ (លានរៀល)	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ (លានដុល្លារអាម៉េរិក)	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនសញ្ញាបណ្ណចុះបញ្ជីសរុប	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនសញ្ញាបណ្ណដល់ឥណប្រតិទាន	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ

ទំហំជួញដូរសរុប (ឯកតា)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
តម្លៃជួញដូរសរុប (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ចំនួនថ្ងៃជួញដូរ	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
តម្លៃជួញដូរមធ្យម (លានរៀល)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ទំហំជួញដូរជាមធ្យម (ឯកតា)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
III. ទីផ្សារឧបករណ៍និស្សន្ទ					
ចំនួនឧបករណ៍និស្សន្ទអនុញ្ញាតឱ្យជួញដូរ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ទំហំនៃការជួញដូរសរុប	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
តម្លៃជួញដូរសរុប (លានដុល្លារអាមេរិក)	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
IV. អ្នកចូលរួមក្នុងទីផ្សារ					
១. ក្រុមហ៊ុនធ្វើអាជីវកម្មមូលបត្រ					
ក្រុមហ៊ុនធានាទិញមូលបត្រ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនពាណិជ្ជករមូលបត្រ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ

ក្រុមហ៊ុនឈ្មួញដើងសាមូលបត្រ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនចែកចាយលក់មូលបត្រ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ភ្នាក់ងារបញ្ជិកា ភ្នាក់ចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនផ្តល់សេវាសវនកម្ម	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនផ្តល់សេវាបកប្រែក្នុងវិស័យមូលបត្រ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
២. ក្រុមហ៊ុនធ្វើអាជីវកម្មឧបករណ៍និស្សន្ន					
ក្រុមហ៊ុនសមភាគីកណ្តាល	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនឈ្មួញដើងសារឧបករណ៍និស្សន្ន	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
៣. ក្រុមហ៊ុនធ្វើអាជីកម្មគម្រោងវិនិយោគរួម					
ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនអភិបាលមូលនិធិ	ស្ថិតិ	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	សាធារណៈ

២. និយ័តករធានារ៉ាប់រងកម្ពុជា					
ទិន្នន័យទីផ្សារធានារ៉ាប់រង - បុព្វលាភដុលធានារ៉ាប់រង (Gross Premium) - ការទាមទារសំណងធានារ៉ាប់រង (Claims)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ក្រុមហ៊ុនធានារ៉ាប់រង	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ប្រភេទផលិតផល	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ទិន្នន័យអាជ្ញាបណ្ណ	ស្ថិតិ ឬរបាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
តារាងសេវាសាធារណៈ	បញ្ជីឈ្មោះសេវាសាធារណៈ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
របាយការណ៍ចំណាយ	របាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	ផ្ទៃក្នុង
៣. និយ័តកររបរធនបាលកិច្ច					
អាជ្ញាបណ្ណ	ស្ថិតិ ឬរបាយការណ៍	ប្រធានទិន្នន័យ	ប្រចាំខែ	PDF	ផ្ទៃក្នុង
លិខិតអនុញ្ញាត	ស្ថិតិ ឬរបាយការណ៍	ប្រធានទិន្នន័យ	ប្រចាំខែ	PDF	ផ្ទៃក្នុង
ប្រភេទនៃបរធនបាលកិច្ច	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ប្រតិបត្តិករ (ស្ថាប័ន)	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ប្រភេទប្រតិបត្តិការ	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ

ចំនួនករណីសរុប	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ទំហំបរធេនសរុប	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
៤. និយ័តករគណនេយ្យ និងសវនកម្ម					
អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត១	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត២	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ការព្យួរ ឬដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ចំនួនគណនេយ្យករ និងសវនករ	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
៥. និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ					
ក្រុមហ៊ុនផ្តល់សេវាកម្ម	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ប្រភេទនៃក្រុមហ៊ុន	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ប្រភេទអាជ្ញាបណ្ណ	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ

ចំនួនអាជ្ញាបណ្ណ	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ប្រភេទនៃកម្រៃសេវា (អាជ្ញាបណ្ណ, សេវារដ្ឋបាល, វិភាគទាន)	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ទំហំនៃកម្រៃសេវា	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ប្រភេទរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	ផ្ទៃក្នុង
៦. គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា					
ប្រភេទគ្រឹះស្ថានល្បែងពាណិជ្ជកម្ម	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
កម្រៃសេវា	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	PDF	សាធារណៈ
ប្រាក់តម្កល់	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	PDF	សាធារណៈ
ចំនួនដងនៃការស្នើសុំ	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	PDF	សាធារណៈ
ការផ្តល់, ពន្យារ, ការផ្អាក, ការបិទដំណើរការ, ការព្យួរ, ការដកហូត និងការប្រគល់វិញនូវអាជ្ញាបណ្ណដល់គ្រឹះស្ថាន	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
ប្រភេទល្បែង	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	PDF	សាធារណៈ
បណ្តឹងតវ៉ាផ្សេងៗ	របាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	ផ្ទៃក្នុង

ការរៀបចំស្តង់ដាគណនី និងសវនកម្ម	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	សាធារណៈ
៥. រដ្ឋបាល, បុគ្គលិក, សារពើភណ្ឌ, ទ្រព្យរដ្ឋ និងសេវាសាធារណៈ					
១. អគ្គលេខាធិការដ្ឋាន					
I. ព័ត៌មានអំពីទ្រព្យសម្បត្តិក្នុង MEF					
លេខអត្តសញ្ញាណនៃទ្រព្យ	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
លេខកូដរដ្ឋបាលរបស់អង្គភាពប្រើប្រាស់	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
លេខកូដកូមិសាស្ត្ររបស់អង្គភាពប្រើប្រាស់	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
លេខសម្គាល់ចំណាត់ថ្នាក់ទ្រព្យ	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
លេខកូដសម្គាល់ទ្រព្យ	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
II. ព័ត៌មានអំពីមន្ត្រី និងបុគ្គលិក					
ចំនួន	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
អាយុ	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
អង្គភាពបម្រើការ	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង

តួនាទី	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
កម្រិតវប្បធម៌	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ស្ថានភាពបម្រើការងារ (កំពុងបម្រើការងារ, ព្យួរការងារ, ចូលនិវត្តន៍,..)	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ក្របខ័ណ្ឌ, ហានុរស័ក្តិ និងថ្នាក់ (កាំប្រាក់)	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
២. អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ					
ព័ត៌មានរូបធាតុនៃទ្រព្យ - លេខអត្តសញ្ញាណនៃទ្រព្យ - លេខកូដរដ្ឋបាលរបស់អង្គភាពប្រើប្រាស់ - លេខកូដកូមិសាស្ត្ររបស់អង្គភាពប្រើប្រាស់ - លេខសម្គាល់ចំណាត់ថ្នាក់ទ្រព្យ - លេខកូដសម្គាល់ទ្រព្យ	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ព័ត៌មានហិរញ្ញវត្ថុ - ចំណាត់ថ្នាក់ថវិកាទាំង ៧ - ថ្លៃដើមនៃទ្រព្យ - អាយុកាលប្រើប្រាស់ - តម្លៃកាកសំណល់ - តម្លៃរំលស់	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ ត្រីមាស ឆ្នាំ	Excel & PDF	ផ្ទៃក្នុង
៣. វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ					
ព័ត៌មានអំពីការបណ្តុះបណ្តាល	ស្ថិតិ ឬរបាយការណ៍	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង

- កម្មវិធីបណ្តុះបណ្តាល - ឧទ្ទេសាចារ្យ/គ្រូបង្គោល - សិក្ខាកាម ឬនិស្សិត					
៤. មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"					
ទិន្នន័យអំពីសហគ្រាស	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ទិន្នន័យអំពីធុរកិច្ចថ្មី	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
វគ្គបណ្តុះបណ្តាល	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
កម្រិតនៃការចាប់យកឌីជីថល	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
អ្នកផ្តល់សេវា	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ប្រភេទនៃសេវាដែលផ្តល់	ស្ថិតិ	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
៥. គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល					
ផែនការសកម្មភាព (ផែនការសកម្មភាព ៣ ឆ្នាំរំកិល របស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និង ផែនការសកម្មភាព ៣ ឆ្នាំរំកិលនៃគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា)	របាយការណ៍	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
សមិទ្ធផល (លទ្ធផលសូចនាករ)	របាយការណ៍	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង

សមិទ្ធកម្ម (លទ្ធផល ឬ % សម្រេចបាននៃការអនុវត្តផែនការសកម្មភាព)	របាយការណ៍	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ទិន្នន័យអំពីសហគ្រាស ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ - ចំនួនសហគ្រាសសរុប - ចំនួនសហគ្រាសតាមវិស័យ, ទំហំ និងទីតាំង	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	Excel & PDF	ផ្ទៃក្នុង
៦. ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ					
ព័ត៌មានអ្នកជំងឺ (ឈ្មោះ, ថ្ងៃខែឆ្នាំកំណើត, ភេទ, មុខរបរ, កន្លែងធ្វើការ, លេខទូរស័ព្ទ, អាសយដ្ឋាន)	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	តាមករណី ប្រចាំថ្ងៃ ប្រចាំខែ	API	ផ្ទៃក្នុង
ព័ត៌មានមូលដ្ឋានសុខាភិបាល (សាធារណៈ, ឯកជន, ឈ្មោះ, កម្រិត, លេខកិច្ចសន្យា, លេខកូដមូលដ្ឋាន, លេខទូរស័ព្ទ, អាសយដ្ឋាន)	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	តាមករណី	API	ផ្ទៃក្នុង
ព័ត៌មានធានារ៉ាប់រងប្រភេទបណ្ណ (ប្រភេទអត្តគាហកៈ, ព័ត៌មានសំខាន់ៗនៃបណ្ណ)	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំថ្ងៃ	API	ផ្ទៃក្នុង
ព័ត៌មានទាក់ទងនឹងការផ្តល់សេវា (ម៉ោងពេលចូលចេញ, ប្រភេទសេវា, រោគវិនិច្ឆ័យ, មូលហេតុចូលចេញ)	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	ប្រចាំខែ	API	ផ្ទៃក្នុង
ព័ត៌មាននៃការស្នើសុំទូទាត់	ទិន្នន័យគោល	បុគ្គលគ្រប់គ្រងទិន្នន័យ	តាមករណី	API	ផ្ទៃក្នុង
៧. គណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា					
ទិន្នន័យសន្និធិស្បៀង និងគ្រាប់ពូជដំណាំប្រចាំឆ្នាំ	ទិន្នន័យគោល	ប្រធានទិន្នន័យ	ប្រចាំឆ្នាំ	Excel & PDF	ផ្ទៃក្នុង
ព័ត៌មានអំពីដំណើរការនៃការផ្តល់ស្បៀង និងគ្រាប់ពូជស្រូវ និងបន្លែ ជូនប្រជាជនក្រីក្រ និងងាយរងគ្រោះដែលជួបគ្រោះធម្មជាតិ និងគ្រោះមហន្តរាយនានា	របាយការណ៍	បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	ប្រចាំត្រីមាស/ឆមាស, ប្រចាំខែ	Excel & PDF	ផ្ទៃក្នុង

ព័ត៌មានអំពីការផ្តត់ផ្តង់គ្រាប់ពូជបន្លែ ជំរុញការដាំដុះជាលក្ខណៈគ្រួសារ	ទិន្នន័យគោល	ប្រធានទិន្នន័យ	ប្រចាំត្រីមាស/ឆមាស, ប្រចាំខែ	Excel & PDF	ផ្ទៃក្នុង

ឧបសម្ព័ន្ធ ៣. គោលការណ៍សម្រាប់ការអភិវឌ្ឍប្រព័ន្ធ

១. ការរៀបចំផែនការ និងគ្រប់គ្រងគម្រោង

ក. គោលការណ៍៖ រៀបចំឯកសារផែនការ និងការគ្រប់គ្រងគម្រោងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធីឱ្យបានច្បាស់លាស់ ដែលជួយធានាដល់ការអនុវត្តឱ្យមានប្រសិទ្ធភាព។

ខ. ស្តង់ដា៖

- **វិធីសាស្ត្រអភិវឌ្ឍប្រព័ន្ធ៖** ជ្រើសរើសវិធីសាស្ត្រអភិវឌ្ឍប្រព័ន្ធណាដែលស័ក្តិសមបំផុតសម្រាប់គម្រោងនីមួយៗ ។ វិធីសាស្ត្រនីមួយៗ មានចំណុចខ្លាំង និងចំណុចខ្សោយផ្សេងៗ គ្នា។ ដូចនេះ ការជ្រើសរើសឱ្យត្រូវតាមប្រភេទគម្រោង ចាំបាច់ត្រូវមើលលើតម្រូវការ និងស្ថានភាពជាក់ស្តែង។ វិធីសាស្ត្រទាំងនោះរួមមានដូចជា វិធីសាស្ត្រ Agile, វិធីសាស្ត្រ Scrum, វិធីសាស្ត្រ Waterfall និងវិធីសាស្ត្រ Spiral ជាដើម។
- **ឯកសារណែនាំ៖** រៀបចំនូវឯកសារណែនាំលម្អិតអំពីតម្រូវការចាំបាច់, ការរៀបចំ, ការអភិវឌ្ឍ, និងដំណាក់កាលធ្វើតេស្ត ដោយអាចប្រើប្រាស់កម្មវិធីដូចជា Confluence និង GitBook ជាដើម។
- **ការគ្រប់គ្រងកំណែ៖** ប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងកំណែប្រែដូចជា Git ជាដើម ដើម្បីតាមដានមើលនូវការកែប្រែកូដ និងអាចធ្វើការជាមួយគ្នាយ៉ាងមានប្រសិទ្ធភាព។ ថ្នាល ឬប្រព័ន្ធដែលពេញនិយមប្រើប្រាស់មានដូចជា GitHub, GitLab និង Bitbucket ជាដើម។

២. ការគ្រប់គ្រងគុណភាពនៃកូដ

ក. គោលការណ៍៖ ធានាឱ្យបាននូវគុណភាពនៃកូដរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមបញ្ចូលទាំងការសរសេរកូដឱ្យមានលក្ខណៈស្តង់ដារួម, ងាយស្រួលយល់, ងាយស្រួលថែទាំ ព្រមទាំងមានប្រសិទ្ធភាព និងអាចប្រើប្រាស់ឡើងវិញបាន។ បន្ថែមពីនេះ ការរក្សាសុវត្ថិភាព, ការពង្រីកវិសាលភាព, ការធ្វើតេស្ត និងការរៀបចំឯកសារណែនាំត្រឹមត្រូវ (Documentation) ក៏ត្រូវមានការគិតគូរផងដែរ។

ខ. ស្តង់ដា៖

- **ស្តង់ដាសរសេរកូដ៖** អនុវត្តតាមស្តង់ដាសរសេរកូដ ដែលបានបង្កើតឡើងសម្រាប់ភាសានីមួយៗ ដើម្បីធានាបាននូវសង្គតិភាព, ភាពសាមញ្ញ និងភាពងាយស្រួលយល់។ ស្តង់ដាសរសេរកូដទាំងនោះរួមមានដូចជា ការណែនាំដោយ Google ក្នុងការអនុវត្តកូដភាសា Java, PEP 8 សម្រាប់ភាសា Python, ការណែនាំដោយ Airbnb សម្រាប់ភាសា JavaScript និង TypeScript ជាដើម។
- **ការត្រួតពិនិត្យកូដ៖** ត្រួតពិនិត្យកូដដោយប្រើប្រាស់យន្តការ Pull Request នៅក្នុង GitHub ឬ GitLab ជាប្រចាំ ដើម្បីអាចធានាបាននូវគុណភាពកូដល្អប្រសើរ ដោយប្រកាន់ខ្ជាប់នូវការសរសេរកូដក្នុងលំនាំស្តង់ដាច្បាស់លាស់ និងការបែងចែកជាម៉ូឌុលដាច់ៗ ពីគ្នា ជាដើម។ ក្នុងនោះ ការសរសេរកូដដោយមានការសហការគ្នា អាចនាំមកនូវការកែលម្អ ឬចែករំលែកចំណេះដឹងបានភ្លាមៗ រួមជាមួយនឹងការត្រួតពិនិត្យកូដដោយស្វ័យប្រវត្តិ ដោយប្រើប្រាស់ SonarQube ជាដើម។ អ្នកត្រួតពិនិត្យកូដត្រូវធ្វើតាមឧត្តមានុវត្តន៍ និងស្តង់ដានៃការសរសេរកូដ ដោយមានគោលបំណង និងបញ្ជីត្រួតពិនិត្យជាក់លាក់។
- **ការវិភាគកូដ៖** ប្រើប្រាស់នូវកម្មវិធីដើម្បីរកមើលនូវកំហុសឆ្គងនៅក្នុងកូដ និងត្រួតពិនិត្យនូវគុណភាពកូដ ដើម្បីធានានូវស្តង់ដាកូដ។

៣. ការរក្សាសុវត្ថិភាព

ក. គោលការណ៍៖ ធានាឱ្យបាននូវសុវត្ថិភាពសម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធីពីការគំរាមកំហែងផ្សេងៗ ។

ខ. ស្តង់ដា៖

- **ការណែនាំ OWASP៖** ធ្វើតាមឧត្តមានុវត្តន៍នៃ OWASP ចំពោះសុវត្ថិភាពនៃកម្មវិធីវេប។

- **ការគ្រប់គ្រងសិទ្ធិប្រើប្រាស់៖** ត្រូវកំណត់សិទ្ធិលើប្រព័ន្ធឱ្យបានច្បាស់លាស់ ដើម្បីការពារពីការចូលមើល ឬប្រើប្រាស់ ទិន្នន័យឯកជន ឬផ្នែកណាមួយពីអ្នកប្រើប្រាស់ និងធានាថារាល់ការចូលប្រើប្រាស់ប្រព័ន្ធ ឬមើលទិន្នន័យផ្សេងៗ មានការគ្រប់គ្រងបានត្រឹមត្រូវ។
- **ការប្រើប្រាស់កូដវិទ្យា (Cryptographic)៖** ត្រូវធានាថា រាល់ការធ្វើប្រតិបត្តិការទិន្នន័យ, ផ្លាស់ប្តូរទិន្នន័យ ឬការរក្សាទុកទិន្នន័យដែលរសើប ត្រូវតែមានការធ្វើកូដនីយកម្មលើទិន្នន័យជាចាំបាច់ ដោយប្រើប្រាស់យន្តការកូដវិទ្យាដែលទំនើប និងរឹងមាំ។
- **ការការពារទិន្នន័យបញ្ចូលដោយអ្នកប្រើប្រាស់៖** ត្រូវធានាថារាល់ទិន្នន័យដែលបញ្ចូលដោយអ្នកប្រើប្រាស់ ត្រូវតែធ្វើការសម្អាត និងត្រួតពិនិត្យជាមុន ចៀសវាងការបញ្ចូលទិន្នន័យដែលអាចប៉ះពាល់ដល់ប្រព័ន្ធ និងអាចឱ្យប្រព័ន្ធងាយរងការវាយប្រហារបាន។
- **ការកំណត់មុខងារសុវត្ថិភាពមិនត្រឹមត្រូវ៖** ត្រូវធានាថាបានអនុវត្តត្រឹមត្រូវលើការកំណត់មុខងារផ្សេងៗ រាល់ការប្រើប្រាស់មុខងារសុវត្ថិភាពទាំងអស់។
- **សមាសធាតុដែលមានចន្លោះប្រហោង (Vulnerable Components) និងហួសសុពលភាព៖** ត្រូវធានាថា រាល់ការប្រើប្រាស់សមាសធាតុផ្សេងៗ (ដូចជា Dependencies ឬ Library) ឬឧបករណ៍/កម្មវិធីនានា ពីខាងក្រៅ ត្រូវធ្វើបច្ចុប្បន្នភាពឱ្យបានទៀងទាត់ ចៀសវាងប្រើប្រាស់សមាសធាតុណាមួយដែលមានចន្លោះប្រហោង ឬហួសសុពលភាព។
- **ការកំណត់អត្តសញ្ញាណ និងយថាភូតកម្ម៖** ត្រូវកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ឱ្យបានច្បាស់លាស់ តាមរយៈការធ្វើយថាភូតកម្ម នៅពេលមានការចូលទៅប្រើប្រាស់ទិន្នន័យ ឬចូលទៅធ្វើសកម្មភាពផ្សេងៗ នៅលើប្រព័ន្ធ។
- **សុច្ចរិតភាពនៃប្រព័ន្ធ និងទិន្នន័យ៖** ត្រូវធានាឱ្យបាននូវសុច្ចរិតភាព និងភាពត្រឹមត្រូវនៃសមាសធាតុទាំងនោះ ទាក់ទងនឹងសុវត្ថិភាព នៅពេលប្រើប្រាស់កម្មវិធី ឬឧបករណ៍ផ្សេងៗ ពីខាងក្រៅ ដូចជា Dependencies ឬ Library ជាដើម។
- **ការកត់ត្រា និងត្រួតពិនិត្យសកម្មភាពផ្សេងៗ៖** ត្រូវតែកត់ត្រាទុកនូវសកម្មភាពផ្សេងៗ ដែលទាក់ទងនឹងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ និងរបស់ប្រព័ន្ធ ព្រមទាំងត្រូវរក្សាទុកនូវកំណត់ត្រានេះឱ្យបានត្រឹមត្រូវ។ ទិន្នន័យរសើបគួរតែត្រូវបានបិទបាំង (Mask) នៅពេលចូលប្រើប្រាស់ប្រព័ន្ធ។

- OWASP MAS: ធ្វើតាមឧត្តមានុវត្តន៍នៃ OWASP ចំពោះបញ្ជីត្រួតពិនិត្យសុវត្ថិភាពនៃកម្មវិធីទូរស័ព្ទចល័ត។
  - **កន្លែងផ្ទុកទិន្នន័យ៖** ត្រូវជ្រើសយក ឬប្រើប្រាស់ប្រភេទនៃកន្លែងផ្ទុកទិន្នន័យឱ្យបានត្រឹមត្រូវនៅលើទូរស័ព្ទចល័ត ជាពិសេសចំពោះទិន្នន័យរសើប។
  - **កូដវិទ្យា៖** ត្រូវប្រើប្រាស់នូវយន្តការការពារទិន្នន័យនៅលើទូរស័ព្ទចល័ត ដោយធ្វើកូដ-នីយកម្មលើទិន្នន័យដែលសំខាន់ និងត្រូវការពារទិន្នន័យប្រភេទជាពាក្យសម្ងាត់ ឬកូដសម្ងាត់ឱ្យបានត្រឹមត្រូវ។
  - **យថាភូតកម្ម៖** ត្រូវធានាថា ការរក្សាទុកនូវព័ត៌មានយថាភូតកម្មរបស់អ្នកប្រើប្រាស់នៅលើទូរស័ព្ទចល័តមានសុវត្ថិភាព ដោយអាចប្រើប្រាស់កូដវិទ្យា ដោយប្រើប្រាស់រួមគ្នាជាមួយនឹងមុខងារយថាភូតកម្មជាមួយជីវមាត្រ (Biometric Authentication) ជាដើម។
  - **បណ្តាញតភ្ជាប់៖** ការផ្លាស់ប្តូរទិន្នន័យរវាងទូរស័ព្ទចល័ត ទៅកាន់អ៊ីនធឺណិតត្រូវតែធ្វើកូដនី-យកម្មជាមុនសិន ឬយ៉ាងហោចណាស់ក៏ត្រូវប្រើប្រាស់នូវ TLS/SSL ជាដើម។

- **ប្រភេទឧបករណ៍ទូរស័ព្ទចល័ត៖** ត្រូវពិនិត្យមើលលើលទ្ធភាពដែលទិន្នន័យអាចលេចធ្លាយនៅពេលអភិវឌ្ឍ តាមរយៈការប្រើប្រាស់មុខងារផ្សេងៗ នៅលើទូរស័ព្ទចល័ត ឬតាមរយៈការបើកសិទ្ធិច្រើនហួសពេកនៅលើទូរស័ព្ទចល័ត (ឧ. ទិន្នន័យទីតាំង, ការប្រើប្រាស់ឧបករណ៍ស្រូបសម្លេង ឬកាមេរ៉ា ជាដើម)។
- **កូដ៖** ត្រូវពិនិត្យមើលគុណភាពនៃកូដ និងធានាថាមិនមានកំហុសឆ្គងផ្នែកសុវត្ថិភាព ដូចជាការប្រើប្រាស់កន្លែងផ្ទុកទិន្នន័យ និងការប្រើប្រាស់ Dependencies ឬ Libraries ពីខាងក្រៅជាដើម។
- **ភាពធន់នៃកម្មវិធី៖** ត្រូវធានាថាកម្មវិធីទូរស័ព្ទចល័តដែលបានអភិវឌ្ឍមានភាពធន់នឹងការប្រើប្រាស់ ជាពិសេសធន់នឹងការវាយប្រហារផ្សេងៗ ដូចជាការធ្វើ Reverse Engineer, ការលួចយកទិន្នន័យនៅក្នុងកម្មវិធី, ការធ្វើ Jailbreak ឬ Root ជាដើម។
- **ឯកជនភាព៖** ត្រូវតែផ្តល់លទ្ធភាពជូនអ្នកប្រើប្រាស់ក្នុងការគ្រប់គ្រងទិន្នន័យរបស់គាត់ នៅពេលអភិវឌ្ឍកម្មវិធីទូរស័ព្ទចល័ត ដោយធ្វើការប្រើប្រាស់ទិន្នន័យអ្នកប្រើប្រាស់ឱ្យកាន់តែតិចតាមតែអាចធ្វើបាន ហើយត្រូវមានតម្លាភាពចំពោះការប្រើប្រាស់ទិន្នន័យទាំងនោះ។

៤. ការធ្វើតេស្ត

ក. គោលការណ៍៖ បង្កើនប្រសិទ្ធភាពនៃការធ្វើតេស្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធី ដើម្បីផ្តល់នូវបទពិសោធដល់អ្នកប្រើប្រាស់ដោយរហូត និងធានាឱ្យបាននូវស្ថិរភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ខ. ស្តង់ដា៖

- ការធ្វើតេស្តកូដជាផ្នែកតូចៗ៖ ត្រូវប្រាកដថាសមាសធាតុនីមួយៗ ត្រូវបានធ្វើតេស្តសាកល្បងយ៉ាងម៉ត់ចត់ ជាមួយនឹងសេណារីយ៉ូឱ្យជំណើរការជាក់ស្តែង លើចំណុចនីមួយៗ ទៅតាមប្រភេទមុខងារនៃផ្នែកនោះ ដើម្បីឱ្យប្រាកដថាពិតជាដំណើរការបានត្រឹមត្រូវ។ ធ្វើលំហែទាំក្នុងការតេស្តកូដ ដើម្បីស្វែងរកបញ្ហា (Bug) និងធ្វើការកែប្រែលើការធ្វើតេស្តបន្ទាប់ពីមានការកែកូដ (Codebase) ដើម្បីដឹងពីបញ្ហាភ្លាមៗ ដើម្បីធ្វើការបំពេញនូវចំណុចខ្វះខាតទាំងនោះ។
- **ការធ្វើតេស្តសមាហរណកម្ម៖** ត្រូវប្រាកដថាការធ្វើអន្តរកម្មរវាងការរួមបញ្ចូលម៉ូឌុល (Modules) និងមុខងារខាងក្រៅ (External Service) មានភាពត្រឹមត្រូវលើលំហូរទិន្នន័យ និងចំណុចប្រសព្វគ្នា (Interfaces) ទៅតាមដំណើរការដូចអ្វីដែលបានគ្រោងទុក។ ធ្វើតេស្តតាមលក្ខខណ្ឌជាក់ស្តែង និងបញ្ហាដែលមិនគ្រោងទុក ដើម្បីឱ្យដឹងពីបញ្ហាក្នុងការធ្វើសមាហរណកម្មចាប់ពីការចាប់ផ្តើម និងបញ្ចប់នៃមុខងារ។
- **ការធ្វើតេស្តផ្នែកសុវត្ថិភាព៖** ធ្វើការវាយតម្លៃផ្នែកសុវត្ថិភាពឱ្យស៊ីជម្រៅ រួមបញ្ចូលទាំងការវិភាគ Static និង Dynamic, ការធ្វើតេស្តជ្រៀតចូល (Penetration Testing) និងគំរូការគំរាមកំហែង (Threat Modeling)។ ទន្ទឹមនេះ ត្រូវអនុវត្តផ្នែកសុវត្ថិភាពតាមការអនុវត្តដែលល្អបំផុត, ធ្វើបច្ចុប្បន្នភាពនៃការធ្វើតេស្តជាប្រចាំទៅលើចំណុចណាមានភាពងាយរងគ្រោះ និងកំពុងកើតឡើង ក៏ដូចជាធានាការអនុលោមតាមស្តង់ដាសុវត្ថិភាព និងបទប្បញ្ញត្តិ។
- **ការធ្វើតេស្ត Load and Profiling ៖** អនុវត្តការធ្វើតេស្ត ដែលមានអ្នកប្រើប្រាស់ច្រើនដំណាលគ្នា ដើម្បីវាយតម្លៃដំណើរការនៃប្រព័ន្ធក្រោមលក្ខខណ្ឌរំពឹងទុក និងកម្រិតខ្ពស់។ ប្រើឧបករណ៍កំណត់ Profiling ដើម្បីកំណត់អត្តសញ្ញាណ និងដោះស្រាយការរាំងស្ទះនៃដំណើរការ, បង្កើនប្រសិទ្ធភាពការប្រើប្រាស់ធនធាន និងធានាឱ្យមានមាត្រដ្ឋាន និងភាពជឿជាក់ក្នុងបរិស្ថានប្រើប្រាស់។

- **តេស្ត UX/UI ៖** វាយតម្លៃបទពិសោធអ្នកប្រើប្រាស់ និងចំណុចប្រទាក់អ្នកប្រើប្រាស់ លើលទ្ធភាពក្នុងការប្រើប្រាស់, ភាពងាយស្រួល និងភាពស៊ីសង្វាក់គ្នាជាមួយនឹងការរចនាឱ្យចំគោលដៅ។ ប្រើប្រាស់មតិកែលម្អរបស់អ្នកប្រើប្រាស់ និងរង្វាស់លទ្ធភាពប្រើប្រាស់ ដើម្បីជំរុញការកែលម្អ និងធានាបាននូវភាពស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់ និងគោលបំណងអាជីវកម្ម។
- **ការធ្វើតេស្តពីអ្នកប្រើប្រាស់ផ្ទាល់៖** សម្របសម្រួល UAT ដោយកំណត់លក្ខណៈនិច្ឆ័យឱ្យបានច្បាស់លាស់ និងការចូលរួមពីភាគីពាក់ព័ន្ធ នៅក្នុងសេណារីយ៉ូការនៃធ្វើតេស្តជាក់ស្តែង។ ដោះស្រាយទៅតាមមតិកែលម្អភ្លាមៗ, ធានាបានថាតម្រូវការមុខងារទាំងអស់ត្រូវបានបំពេញ និងផ្ទៀងផ្ទាត់ថាមុខងារប្រព័ន្ធស្របតាមគោលដៅអាជីវកម្ម និងការរំពឹងទុករបស់អ្នកប្រើប្រាស់មុនពេលដាក់ឱ្យប្រើប្រាស់។

៥. ការពង្រីកវិសាលភាព

ក. គោលការណ៍៖ រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធី ដើម្បីអាចពង្រីកវិសាលភាព ស្របតាមតម្រូវការនាពេលអនាគត។

ខ. ស្តង់ដា៖

- **វិធីសាស្ត្រ Stateless ៖** បង្កើតនូវប្រព័ន្ធក្នុងរបៀបជា Stateless ដែលមានន័យថា រាល់ការស្នើគឺត្រូវដំណើរការដោយឯករាជ្យ និងមានព័ត៌មានចាំបាច់ទាំងអស់។ រាល់ការចូលប្រើប្រាស់, ប្រព័ន្ធត្រូវដំណើរការដោយឯករាជ្យ ហើយមិនត្រូវគ្រប់គ្រងទិន្នន័យទេ (ទិន្នន័យត្រូវបានរក្សា និងគ្រប់គ្រងនៅកន្លែងផ្សេង)។ ការធ្វើបែបនេះ នឹងធ្វើឱ្យការពង្រីកវិសាលភាពមានភាពងាយស្រួល។
- **និម្មាបនកម្មប្រព័ន្ធ៖** ជ្រើសយកនិម្មាបនកម្មណាមួយដែលសមស្របជាមួយនឹងតម្រូវការរបស់ប្រព័ន្ធ។ ការប្រើប្រាស់ប្រព័ន្ធរួមធំតែមួយ គឺសាកសមជាមួយនឹងប្រព័ន្ធណាដែលសាមញ្ញ ខណៈដែល ប្រព័ន្ធបែងចែកជាផ្នែកតូចៗ (Microservices) ផ្តល់នូវជម្រើសប្រសើរជាងសម្រាប់ការពង្រីកវិសាលភាពនៅពេលក្រោយ ចំពោះប្រព័ន្ធ ឬកម្មវិធីណាដែលស្មុគស្មាញ។
- **ការរចខ្ចប់ប្រព័ន្ធទៅជាទម្រង់ Container ៖** ដាក់កម្មវិធី ឬប្រព័ន្ធទាំងមូល រួមជាមួយនឹងសមាសធាតុពាក់ព័ន្ធទាំងអស់ទៅជាទម្រង់ Container ដើម្បីឱ្យការដាក់ឱ្យប្រើប្រាស់មានភាពស្របគ្នា ទោះបីជានៅក្នុងបរិស្ថានផ្សេងគ្នាក៏ដោយ។ ការធ្វើបែបនេះ គឺងាយស្រួលក្នុងការពង្រីកវិសាលភាពនៅពេលរួចរាល់ ហើយងាយក្នុងការគ្រប់គ្រងលើធនធាន ដើម្បីដាក់ឱ្យប្រើប្រាស់ផងដែរ។

គ. ឧបករណ៍ពេញនិយមប្រើប្រាស់៖

- **Nginx៖** ជាឧបករណ៍ដែលត្រូវបានប្រើប្រាស់ជាទូទៅ ដែលជួយគ្រប់គ្រងប្រព័ន្ធ តាមរយៈការបែងចែកការស្នើយ៉ាងមានប្រសិទ្ធភាពលើម៉ាស៊ីនមេជាច្រើន, បង្កើនតុល្យភាពបន្ទុក (Load Balancing) និងលទ្ធភាពបរាជ័យ (Failover Capabilities) ។
- **Docker៖** ជាឧបករណ៍ដែលត្រូវបានប្រើប្រាស់សម្រាប់ការបង្កើត និងគ្រប់គ្រង Containers ដោយផ្តល់នូវបរិស្ថានស្តង់ដាសម្រាប់ប្រព័ន្ធ។
- **Kubernetes៖** ប្រើសម្រាប់ស្វ័យប្រវត្តិកម្មនៃការដាក់ឱ្យប្រើប្រាស់, ការធ្វើពង្រីកវិសាលភាព និងការគ្រប់គ្រងប្រព័ន្ធដែលមាន Containers ។ វាជួយគ្រប់គ្រងប្រព័ន្ធនៅពេលពង្រីកវិសាលភាព, ធានានូវការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងដោះស្រាយការកើនឡើងនូវតម្រូវការ។

៦. ការកំណត់ស្តង់ដា UI/UX

ក. គោលការណ៍៖ ធានាឱ្យបាននូវភាពងាយស្រួលប្រើប្រាស់ (User-Friendly), អាចចូលទៅប្រើប្រាស់បាន និងមានភាពទាក់ទាញ សម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធី។

ខ. **ស្តង់ដា៖**

- **លទ្ធភាពក្នុងការប្រើប្រាស់ (Accessibility)៖** អនុវត្តតាមស្តង់ដានៃលទ្ធភាពដែលអាចចូលទៅប្រើប្រាស់បាន (ឧ. WCAG) ដើម្បីធានាថាអ្នកប្រើប្រាស់ទាំងអស់អាចប្រើប្រាស់ប្រព័ន្ធបាន។
- **ភាពស៊ីចង្វាក់នៃការរចនា (Design Consistency)៖** រក្សាភាពស៊ីចង្វាក់ចំពោះសមាសធាតុសម្រាប់ការរចនាប្រព័ន្ធទាំងមូល ដោយប្រើប្រាស់ប្រព័ន្ធរចនាដូចជា Material Design ឬ Bootstrap។
- **ពណ៌៖** អនុវត្តតាមគំរូពណ៌ស្តង់ដាដែលធានាភាពងាយស្រួលក្នុងការចូលប្រើប្រាស់ និងភាពស៊ីចង្វាក់នៅក្នុងប្រព័ន្ធ។ ប្រើឧបករណ៍ដូចជា Material Design Color Tool ដើម្បីបង្កើតក្តារលាយពណ៌ចម្រុះ (Cohesive Color Palette)។
- **ពុម្ពអក្សរ (Font)៖** ប្រើទំហំពុម្ពអក្សរ និងរចនាបថស្តង់ដា ដើម្បីធានាភាពងាយស្រួលក្នុងការអាន។ រក្សាហានុក្រមនៃទម្រង់អក្សរ និងប្រើពុម្ពអក្សរដែលសមស្របសម្រាប់គេហទំព័រ ឬមានម៉ាកយីហោជាក់លាក់។
- **ទំហំអេក្រង់៖** រចនាដោយឆ្លើយតបនឹងតម្រូវការរបស់អ្នកប្រើប្រាស់ ដើម្បីធានាបាននូវបទពិសោធដែលមានភាពរហូន សម្រាប់អ្នកប្រើប្រាស់នៅលើថ្នាលគ្រប់ប្រភេទ។ ប្រើប្រាស់ Fluid Grids និង Media Queries ដើម្បីកែតម្រូវប្លង់ (Layout) ស្របតាមទំហំនៃឧបករណ៍អេឡិចត្រូនិក។
- **រូបតំណាង (Icon)៖** ប្រើប្រាស់សំណុំរូបតំណាងដែលមានភាពពាក់ព័ន្ធ (Cohesive), ប្រភពបើកចំហ ឬមានការរក្សាសិទ្ធិ។ ត្រូវធានាថារូបតំណាងមានរចនាបថដែលស៊ីចង្វាក់គ្នា និងមានអក្សរសម្រាប់បរិយាយ ដើម្បីបង្កើនភាពងាយស្រួលក្នុងការប្រើប្រាស់។
- **រូបភាព៖** ប្រើប្រាស់រូបភាពមានគុណភាពខ្ពស់ ដែលមានការរក្សាសិទ្ធិដោយឥតគិតថ្លៃ ឬបង់ប្រាក់ត្រឹមត្រូវ ព្រមទាំងធានាថារូបភាពត្រូវបានកែសម្របឱ្យត្រូវទៅនឹងគេហទំព័រ ដើម្បីរក្សាដំណើរការ។
- **ការចុចតិច (Less Click)៖** សម្រួលដល់អន្តរសកម្ម (Interaction) របស់អ្នកប្រើប្រាស់ ដោយកាត់បន្ថយចំនួនដងនៃការចុច ដែលត្រូវការដើម្បីសម្រេចបានកិច្ចការផ្សេងៗ ។ សម្រួលដល់ការស្វែងរក និងរចនារំហូរការងារដែលងាយស្រួលយល់ ដើម្បីបង្កើនប្រសិទ្ធភាព និងភាពពេញចិត្តរបស់អ្នកប្រើប្រាស់ ដោយធ្វើឱ្យអ្នកប្រើប្រាស់មានភាពងាយស្រួល ក្នុងការសម្រេចបាននូវគោលដៅរបស់ពួកគេ ដោយចំណាយកម្លាំងតិចតួចបំផុត។

គ. **ឧបករណ៍ពេញនិយមប្រើប្រាស់៖**

- UserTesting៖ សម្រាប់ការស្រាវជ្រាវអំពីបទពិសោធអ្នកប្រើប្រាស់។
- Hotjar៖ សម្រាប់កំណត់ទីតាំង និងរយៈពេលនៃការចូលទៅប្រើប្រាស់របស់អ្នកប្រើប្រាស់។
- Material Design៖ សម្រាប់គោលការណ៍ណែនាំការរចនាឱ្យមានសង្គតិភាព ។
- Bootstrap៖ សម្រាប់ការរចនាតម្រូវតាមទំហំងអេក្រង់អ្នកប្រើប្រាស់។
- Material Design Color Tool៖ សម្រាប់ការបង្កើតក្តារលាយពណ៌ចម្រុះ។
- Google Fonts៖ សម្រាប់ការជ្រើសរើសពុម្ពអក្សរ Web-Safe ។
- FlatIcon៖ សម្រាប់ការចូលទៅប្រើប្រាស់រូបតំណាងដោយឥតគិតថ្លៃ។
- Freepik/Adobe Stock៖ សម្រាប់ចូលទៅប្រើប្រាស់រូបភាពដែលមានគុណភាពខ្ពស់។

៧. ការកំណត់ស្តង់ដា API

ក. គោលការណ៍៖ រៀបចំ, អភិវឌ្ឍ និងរក្សានូវ API ស្របតាមឧត្តមានុវត្តន៍ ដើម្បីធានាបាននូវភាពជឿជាក់, ភាពអាចពង្រីកបាន និងភាពងាយស្រួលក្នុងការប្រើប្រាស់។

ខ. **ស្តង់ដា៖**

- **បង្កើតជាទម្រង់ RESTful ៖** អនុវត្តតាមគោលការណ៍ REST ក្នុងការបង្កើត API ដែលឈ្មោះធនធានមានអត្ថន័យច្បាស់លាស់ ជាមួយនឹងការប្រើប្រាស់ HTTP Methods ឱ្យបានត្រឹមត្រូវ។
- **ការធ្វើកំណែ៖** នៅពេលមានការផ្លាស់ប្តូរ ឬកែប្រែទៅលើ API ត្រូវប្រើប្រាស់នូវលេខកំណែប្រែថ្មីសម្រាប់ការផ្លាស់ប្តូរនោះ ចៀសវាងប៉ះពាល់ដល់ API ដែលមានស្រាប់ ហើយកំពុងតែត្រូវបានប្រើប្រាស់។ ការដាក់លេខកំណែប្រែនេះ អាចដាក់នៅលើ URI នៃ API ឬក៏ដាក់នៅក្នុង Header ។
- **ឯកសារណែនាំ៖** ផ្តល់នូវឯកសារណែនាំពីរបៀបប្រើប្រាស់ API ដោយប្រើប្រាស់កម្មវិធី ដូចជា Swagger ឬ Postman ជាដើម ដើម្បីឱ្យអ្នកអភិវឌ្ឍកម្មវិធីអាចយល់ពី APIs បានងាយស្រួល។
- **ក្បួនដាក់ឈ្មោះ៖** ប្រើប្រាស់ឈ្មោះណាដែលមានអត្ថន័យគ្រប់គ្រាន់ និងត្រឹមត្រូវដែលអាចតំណាងរបស់ ឬសកម្មភាពផ្សេងៗ, ប្រើនាមពហុវចន:ដើម្បីតំណាងឱ្យបណ្តុំផ្សេងៗ និងប្រកាន់ខ្ជាប់នូវគម្រូមួយ (ឧ. Kebab-case ឬ CamelCase) សម្រាប់គ្រប់ API ទាំងអស់ ដើម្បីបង្កើនភាពច្បាស់លាស់ និងងាយស្រួលថែទាំ។
- **យថាភូតកម្ម៖** ការពារ API ដោយប្រើប្រាស់យន្តការយថាភូតកម្មដែលរឹងមាំ ដូចជា OAuth2 ឬ JWT (JSON Web Tokens) ជាដើម។ វិធីសាស្ត្រទាំងនេះ ជួយធានានូវសុវត្ថិភាព ដោយមានតែអ្នកប្រើប្រាស់ដែលមានសិទ្ធិប្រើប្រាស់ប៉ុណ្ណោះដែលអាចចូលទៅប្រើប្រាស់ធនធាន API បាន។
- **ការដាក់កម្រិតនូវចំនួនប្រើប្រាស់៖** ការដាក់កម្រិតចំនួនប្រើប្រាស់ API នេះ នឹងជួយការពារ API ពីការប្រើប្រាស់មិនត្រឹមត្រូវច្រើនលើសកំណត់។
- **ការគ្រប់គ្រងនៅពេលមានបញ្ហា៖** គួរបង្កើតនូវស្តង់ដាកូដសម្រាប់បញ្ហានីមួយៗ ក៏ដូចជាសារប្រាប់ទៅអ្នកប្រើប្រាស់ ដើម្បីដឹងពីបញ្ហាឱ្យបានច្បាស់លាស់ ហើយងាយស្រួលក្នុងការដួសជុលកំហុស ឬបញ្ហានោះ។ ការរាយការណ៍ពីបញ្ហា ឬកំហុសទាំងនោះបានច្បាស់លាស់ អាចជួយដល់អ្នកអភិវឌ្ឍកម្មវិធីក្នុងការដោះស្រាយ និងធ្វើឱ្យប្រព័ន្ធ ឬកម្មវិធីប្រសើរជាងមុន។

៨. ការដាក់ឱ្យប្រើប្រាស់ និងថែទាំ

ក. គោលការណ៍៖ ធានាឱ្យបាននូវការដាក់ឱ្យប្រើប្រាស់ប្រកបដោយភាពហូន និងការថែទាំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធីប្រកបដោយប្រសិទ្ធភាព តាមរយៈការបែងចែកបរិស្ថានអភិវឌ្ឍ (Development Environments) ជា ៣ ផ្នែកធំៗ រួមមាន បរិស្ថានអភិវឌ្ឍកម្មវិធី, បរិស្ថានតេស្តកម្មវិធី និងបរិស្ថានប្រើប្រាស់។

ខ. **ស្តង់ដា៖**

- **ផែនការ និងការសោកល្បងដាក់ឱ្យប្រើប្រាស់៖** រៀបចំនូវផែនការដាក់ឱ្យប្រើប្រាស់ ដោយលម្អិតពីដំណាក់កាលនីមួយៗ, ចំណុចដែលទាក់ទងគ្នា, និងនីតិវិធីក្នុងការត្រឡប់ក្រោយវិញ ក្នុងករណីមានប្រក្រតីណាមួយ។ ត្រូវធ្វើតេស្តការដាក់ឱ្យប្រើប្រាស់នេះនៅក្នុងបរិស្ថាន Stagging ឱ្យបានហ្មត់ចត់ឱ្យបានរួចរាល់ ដើម្បីធានាថាការកំណត់ និងមុខងារផ្សេងៗ ដំណើរការបានល្អដូចការរំពឹងទុក។
- **ស្វ័យប្រវត្តិកម្ម និងការតាមដានការដាក់ដំណើរការ៖** ប្រើប្រាស់នូវកម្មវិធីស្វ័យប្រវត្តិមួយចំនួនដូចជា Jenkins, GitHub Actions និង GitLab CI/CD ជាដើម ដើម្បីសម្រួលការងារដាក់ដំណើរការប្រព័ន្ធនេះឱ្យកាន់តែងាយស្រួល ហើយកាត់បន្ថយនូវកំហុសឆ្គងដែលអាចកើតមាន បើសិនជាធ្វើដោយដៃ។ ក្រៅពីនេះត្រូវដំឡើងនូវកម្មវិធីដូចជា Grafana, ELK Stack, New Relic, Datadog និង Prometheus ជាដើម ដើម្បីតាមដាននូវការដំណើរការរបស់ប្រព័ន្ធ, ដឹងពីបញ្ហាបានលឿន ហើយអាចទទួលបានការជូនដំណឹងបានភ្លាមៗ ។

- **ការបង្កើត Container ៖** ធ្វើស្វ័យប្រវត្តិកម្មលើការដាក់ដំណើរការប្រព័ន្ធ, ការពង្រីកវិសាលភាព និងការគ្រប់គ្រងកម្មវិធីដែលដំណើរការក្នុងទម្រង់ជា Container ដើម្បីធានាថាការប្រើប្រាស់ធនធានក្នុងការដាក់ឱ្យប្រើប្រាស់មានប្រសិទ្ធភាព ហើយដំណើរការបានល្អ។ កម្មវិធីសម្រាប់គ្រប់គ្រង ប្រព័ន្ធបែប Container មានដូចជា Kubernetes, Docker Swam និង OpenShift ជាដើម។
- **ការគ្រប់គ្រងកំណែ និងការបម្រុងទុក៖** ប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងកំណែ (ដូចជា Git) ដើម្បីគ្រប់គ្រងនៅពេលកូដត្រូវបានកែប្រែ ឬមានការកែប្រែលើការកំណត់ផ្សេងៗ ដើម្បីងាយស្រួលក្នុងការត្រឡប់ក្រោយវិញក្នុងករណីមិនប្រក្រតីណាមួយ និងងាយស្រួលតាមដាន។ ក្នុងនោះត្រូវមានយុទ្ធសាស្ត្រក្នុងការបម្រុងទុកទិន្នន័យ និងការកំណត់ផ្សេងៗ មុនពេលធ្វើការដាក់ឱ្យប្រើប្រាស់ ហើយត្រូវធ្វើតេស្តដំណើរការនៃការស្តារឡើងវិញនៅពេលមានបញ្ហាណាមួយកើតឡើង។
- **ធ្វើការថែទាំ និងតេស្តជាប្រចាំ៖** ត្រូវមានកាលវិភាគធ្វើការថែទាំប្រព័ន្ធជាប្រចាំ រួមបញ្ចូលទាំងការធ្វើបច្ចុប្បន្នភាព, ការជួលជុលកំហុសផ្នែកសុវត្ថិភាព, និងការធ្វើឱ្យប្រព័ន្ធប្រសើរជាងមុន ដើម្បីឱ្យប្រព័ន្ធមានស្ថិរភាព និងសុវត្ថិភាព។

ឧបសម្ព័ន្ធ ៤. បច្ចេកវិទ្យាជាក់ដំណើរការរួម

១. បច្ចេកវិទ្យារួមសម្រាប់ការអភិវឌ្ឍ (Development Tech Stack)

- **ផ្នែកខាងម៉ាស៊ីនមេ (Server Side)៖** សំដៅលើបច្ចេកវិទ្យា ឬឧបករណ៍ដែលប្រើប្រាស់សម្រាប់អភិវឌ្ឍប្រព័ន្ធផ្នែកខាងក្រោយ (Backend) ។
- **ផ្នែកខាងអ្នកប្រើប្រាស់ (Client Side)៖** សំដៅលើបច្ចេកវិទ្យា ឬឧបករណ៍ដែលប្រើប្រាស់សម្រាប់អភិវឌ្ឍប្រព័ន្ធផ្នែកខាងមុខ (Frontend), កម្មវិធីទូរស័ព្ទ, ឬកម្មវិធីលើ Desktop ។

	ផ្នែកខាងម៉ាស៊ីនមេ	ផ្នែកខាងអ្នកប្រើប្រាស់		
ថ្នាល/ប្រព័ន្ធប្រតិបត្តិការ (Platform / OS)	Linux, Windows	Web	Mobile (Android/iOS)	Desktop (Windows, Linux, macOS)
ការសរសេរស្គ្រីប (Scripting)	Shell, Python, Ruby, Perl	JavaScript, TypeScript, VBScript	JavaScript, Dart, Kotlin	PowerShell, Shell, AppleScript, Python, Batch
ភាសាសរសេរកម្មវិធី (Programming Language)	Java, JavaScript, C#, Python, PHP, Ruby, Go	JavaScript, TypeScript	Java, Kotlin, Swift, Dart	C#, Java, Python
ឃ្លាំងផ្ទុកទិន្នន័យ (Database)	PostgreSQL, MySQL, MongoDB, Oracle, MS-SQL Server, IBM DB2, Redis	WebStorage	Core Data, SQLite	SQLite, MySQL, PostgreSQL, MS-SQL Server
ម៉ាស៊ីនមេសម្រាប់កម្មវិធី (Application Server)	Node.js, Tomcat, Jetty, WildFly, GlassFish, Wapper service, NSSM			
ម៉ាស៊ីនមេសម្រាប់វេប (Web Server)	Node.js, Nginx, Apache, Tomcat, Jetty, WildFly, GlassFish, Microsoft IIS,	-		

	Oracle Web Logic, IBM PAW, Tomcat			
Framework	Spring, .NET, ExpressJS, NestJS, Django, Flask, Laravel, Koa.js, Ruby on Rails, Node, Odoo	AngularJS, ReactJS, VueJS, NuxtJS, NextJS	Flutter, React-native	.NET, Electron, JavaFX, Qt, Avalonia
ការគ្រប់គ្រង Package	pip, mvn, Composer, Nexus, Bundler, Conan, Jfrog Artifactory	npm, Yarn, Bower	pub, pod, CocoaPods, Gradle, Swift Package Manager	Homebrew, Chocolatey, npm, Yarn, NuGet
ឧបករណ៍សម្រាប់អភិវឌ្ឍ (Build Tools)	Maven, Gradle, MSBuild, Rake	Webpack, Gulp, Grunt, Parcel	Gradle, XCode, Carthage	MSBuild, CMake, Xcode, Gradle, Bazel
Webservice / API Tools	Rest-API, JSON, gRPC, Postman, Swagger, CURL, SOAP UI	-		
Libraries	PyJWT, Gson, Lodash, Requests	jQuery, Bootstrap, Axios, Lodash	Retrofit, Alamofire, Firebase, Glide, Realm, Provider, Dio	WinForms, GTK, Newtonsoft.Json
SMS Provider	OneSignal, Nomsa.gov.kh, Plasgate, MekongSMS	-		
ឧបករណ៍សម្រាប់ការអភិវឌ្ឍ (Development Tools)	IntelliJ, VS Code, Eclipse, Spring Tool Suite, Maven, Gradle, etc.	IntelliJ, Netbeans, VS Code	Xcode, Andriod Studio, VS Code	

២. បច្ចេកវិទ្យារួមសម្រាប់ប្រតិបត្តិ និងតាមដាន (Operation/Monitoring Tech Stack)

Category	Tools & Technologies
ការគ្រប់គ្រងកូដ (Source Control)	GitHub, GitLab, Bitbucket, Subversion (SVN)
ហេដ្ឋារចនាសម្ព័ន្ធជាកូដ (Infrastructure as Code)	Terraform, Pulumi, Ansible, Vagrant
Automation & Configuration	Ansible, Chef, OpenStack, Puppet, Terraform, SaltStack, Consul
CI/CD	Jenkins, GitHub Actions, GitLab CI/CD, Travis CI, CircleCI, Argo CD, Spinnaker, Helm, Maven, Git, JFrog
Container Orchestration & Management	Docker, Kubernetes, OpenShift, Rancher, Nomad, Portainer
ម៉ាស៊ីននិម្មិត (Virtual Machines)	Proxmox, VMware vSphere, VirtualBox, Oracle OVM, Nutanix AHV
ការតាមដាន, ការកត់ត្រាការចូលប្រើប្រាស់, ការរាយការណ៍ និងការវិភាគការចូលប្រើប្រាស់ (Monitoring, Logging, Reporting & Log Analytics)	ELK Stack (Elasticsearch, Logstash, Kibana), ZooKeeper, Fluentd, Prometheus, Grafana, New Relic, Loggly, Sentry, Dynatrace, AppDynamics, Splunk, FortiSIEM, Panorama
សុវត្ថិភាព, ការកំណត់អត្តសញ្ញាណ និងអនុលោមភាព (Security, Identity & Compliance)	MEF's Security Operations Center (SoC), Web Application Firewall (WAF), Docker Image Scanner (Snyk, ...), Cloudflare, OpenVPN, HashiCorp Vault
ការគ្រប់គ្រងឧប្បត្តិហេតុ (Incident Management)	TheHive Project, OpsGenie, Jira, Clickup,
ការធ្វើតេស្ត (Testing)	JUnit, JMeter, pytest, Mocha, Selenium, Cypress, TestNG, Cucumber, Postman, K6
ការតាមដានកំហុស (Error Tracking)	Sentry, Firebase Crashlytics
អ្នកផ្តល់ SSL (SSL Provider)	Let's Encrypt, Certbot, DigiCert, Comodo SSL, GlobalSign, SSL2buy, Entrust
Message Queue	Kafka, RabbitMQ, ActiveMQ, IBM MQ, TIBCO EMS
ការគ្រប់គ្រងគម្រោង និងឧបករណ៍ (Project Management & Tools)	Agile, Scrum and Kanban Confluence, JIRA, ClickUp, Asana Notion, Trello

ឧបករណ៍សម្រាប់ទិន្នន័យធំ (Big Data Tools)	Apache Spark, Hadoop, Python, R, Apache Kafka, Apache Flink, Dask
ឧបករណ៍គ្រប់គ្រងកំណែ (Computer Version Tools)	OpenCV, TensorFlow, CUDA, MATLAB, DeepFace, YOLO, Keras, ML Kit
ឧបករណ៍សម្រាប់វិទ្យាសាស្ត្រទិន្នន័យ/បញ្ញាសិប្បនិម្មិត (Data Science / AI Tools)	TensorFlow, R, Pandas, NumPy, Keras, Scikit-learn, PyTorch, MATLAB
ឌីជីថលូបនីយកម្មភាសាខ្មែរ (Khmer NLP)	• **Frameworks**: Django, FastAPI, Flask, • **Servers (ASGI/WSGI)**: Uvicorn, Gunicorn, Hypercorn, • **Machine Learning Frameworks**: TensorFlow, PyTorch, • **NLP Libraries**: NLTK, Transformers, TextBlob, Sentencepiece, Levenshtein, Phonetisaurus, SymspellyPy, Fasttext, Hunspell
ក្រាហ្វិក (Graphic)	Figma, Sketch, Adobe XD, Draw.io

៣. ស្តង់ដាសុវត្ថិភាពរួម (Security)

ប្រភេទ	ប្រភេទរង	ឧបករណ៍ និងបច្ចេកវិទ្យា
សុវត្ថិភាពបណ្តាញ (Network Security)	Firewall	FortiGate, Cisco, Palo Alto, pfSense, iptables, Checkpoint
	Intrusion Detection/Prevention Systems (IDS/IPS)	Snort, Suricata, OSSEC, Bro (Zeek)
	VPNs	OpenVPN, WireGuard, Fortinet, Cisco AnyConnect, SoftEther VPN
	Content Delivery Network (CDN)	Cloudflare, Akamai
សុវត្ថិភាពលើឧបករណ៍ (Endpoint Security)	Antivirus/Anti-malware	Kaspersky, McAfee, Bitdefender, Symantec Endpoint Protection, ClamAV, ESET, Trend Micro
	Endpoint Detection and Response (EDR)	CrowdStrike, Carbon Black, SentinelOne, OSQuery, Trend Micro XDR, Cortex XDR, FortiEDR, Kaspersky EDR Optimun
សុវត្ថិភាពប្រព័ន្ធ (Application Security)	Static Application Security Testing (SAST)	SonarQube, Checkmarx, Fortify,
	Dynamic Application Security Testing (DAST)	OWASP ZAP, Burp Suite, App Spider, Arachni
	Software Composition Analysis	WhiteSource, Snyk, Black Duck, OWASP Dependency-Check
	Web Application Firewalls (WAF)	AWS WAF, Cloudflare WAF, F5, Imperva WAF
ការគ្រប់គ្រងអត្តសញ្ញាណ និងការចូលប្រើប្រាស់ (Identity and Access Management - IAM)	Single Sign-On	CamDigiKey, Auth0, KeyCloak, Okta, Azure AD, OneLogin
	Multi-Factor Authentication	Google Authenticator, RSA SecurID, FreeOTP, Cisco Duo

	Phone Authentication	Firebase, Twilio Authy
	Privileged Acces Management (PAM)	CyberArk, BeyondTrust, Delinea
ការគ្រប់គ្រងភាពងាយរងគ្រោះ (Vulnerability Management)	Vulnerability Scanner	Nessus, OpenVAS, Nmap, Lynis, Burp suite, Acunetix
	Patch Management	Microsoft SCCM, Ivanti Patch Management, ManageEngine Patch Manager Plus
ការគ្រប់គ្រងព័ត៌មានសុវត្ថិភាព និង ព្រឹត្តិការណ៍ (Security Information and Event Management - SIEM)		OSSEC, Wazuh, ELK Stack (Elasticsearch, Logstash, Kibana), Graylog, Splunk, IBM QRadar, ArcSight (Micro Focus), Azure Sentinal, LogRhythm, FortiSIEM
សុវត្ថិភាព, Orchestration, ស្វ័យប្រវត្តិកម្ម និងការឆ្លើយតប (Security Orchestration, Automation and Response - SOAR)		TheHive, Cortex, Shuffle, Wazuh, Splunk Phantom, IBM Resilient, FortiSOAR, LogRhythm SOAR
Threat Intelligence		MISP, Open Threat Exchange (OTX), Yeti, Anomali ThreatStream, FireEye Threat Intelligence, Palo Alto Networks Auto Focus
ការឆ្លើយតបឧប្បត្តិហេតុ & កោសល្យវិច្ច័យ (Incident Response & Forensics)		Autopsy, Volatility, GRR, The Sleuth Kit, CrodStrike Falcon Insight
ការយល់ដឹងអំពីសុវត្ថិភាព (Security Awareness)	Phishing Simulation	GoPhish, PhishSim, King Phisher

ឧបសម្ព័ន្ធ ៥. ផែនការអនុវត្តលើការប្រតិបត្តិ, គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ល.រ.	អង្គភាព	ផែនការសកម្មភាព
១	អគ្គលេខាធិការដ្ឋាន	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងមន្ត្រី និងបុគ្គលិក - ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិសារពើភណ្ឌ ក្នុងក្រសួង រួមទាំងប្រព័ន្ធគ្រប់គ្រងយានយន្ត - ប្រតិបត្តិ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបណ្តាញតភ្ជាប់, មជ្ឈ-មណ្ឌលទិន្នន័យ និងមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ
២	អគ្គនាយកដ្ឋាន គោលនយោបាយ	- ប្រមូលទិន្នន័យពាក់ព័ន្ធដែលបម្រើដល់ការវិភាគម៉ាក្រូសេដ្ឋកិច្ច និងរៀបចំគោលនយោបាយ - ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធ PIP DBMS
៣	អគ្គនាយកដ្ឋានថវិកា	- បន្តប្រើប្រាស់ FMIS សម្រាប់ការងារត្រួតពិនិត្យថវិកា
៤	អគ្គនាយកដ្ឋានពន្ធដារ	- ប្រតិបត្តិ និងគ្រប់គ្រងចង្កោមនៃប្រព័ន្ធប្រមូលពន្ធដារ - ប្រតិបត្តិ និងគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ
៥	អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា	- ប្រតិបត្តិ និងគ្រប់គ្រងចង្កោមនៃប្រព័ន្ធប្រមូលពន្ធគយ - ប្រតិបត្តិ និងគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ
៦	អគ្គនាយកដ្ឋានរតនាគារ-ជាតិ	- បន្តប្រើប្រាស់ FMIS តាមមុខងាររបស់ខ្លួន FMIS Portal, Edoc, CMS និង NRMIS
៧	អគ្គនាយកដ្ឋានលទ្ធកម្ម សាធារណៈ	- ធ្វើជាម្ចាស់, ជាអ្នកប្រតិបត្តិ និងជាអ្នកជំរុញការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក (e-GP) ជាមុខងារស្នូលមួយក្នុង FMIS ដែលក្នុងនោះមានអនុមុខងារ Procurement Plan, Catalogue Management, Notification, Bidder Registration, Tendering និង Contract Management, Supplier Center និង Shopping Cart ជាដើម។ - ចូលរួមផ្តល់ធាតុចូល, ធ្វើតេស្ត និងអភិវឌ្ឍឱ្យបានគ្រប់ជ្រុងជ្រោយនូវប្រព័ន្ធ e-GP ព្រមទាំងជំរុញការគ្រប់គ្រង និងប្រតិបត្តិប្រព័ន្ធនេះ ជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេស អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងអគ្គនាយក-ដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
៨	អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធ SARMIS និងប្រព័ន្ធ NRMIS - រៀបចំអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានសហគ្រាសសាធារណៈ (PEMIS)

៩	អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ	- រៀបចំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ ដែលប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
១០	អគ្គាធិការដ្ឋាន	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងការងារអធិការកិច្ចហិរញ្ញវត្ថុ (Financial Information Database System)
១១	អគ្គនាយកដ្ឋានសហ-ប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល	- ប្រតិបត្តិប្រព័ន្ធ DMFAS និងប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោង (Project Portfolio Database Management System – PPDMS)
១២	អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍	- រៀបចំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
១៣	អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន	- រៀបចំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ
១៤	អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធ SAAT
១៥	អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល	- គ្រប់គ្រងប្រព័ន្ធប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក (E-invoice) និងទិន្នន័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Data EF)
១៦	អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	- ប្រតិបត្តិ និងគ្រប់គ្រង FMIS ស្នូល និងចង្កោម ដែលផ្តោតលើមុខងារការអនុវត្តចំណូល ចំណាយថវិការដ្ឋ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យនៃថវិការដ្ឋ ស្របតាមមាត្រាទី ១៣ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ - ប្រតិបត្តិ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធរូបវន្តទ្រទ្រង់ទាំងអស់របស់ FMIS និងអ៊ីនត្រាណិត
១៧	វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធបណ្តុះបណ្តាលឌីជីថល
១៨	មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"	- ប្រតិបត្តិ និងគ្រប់គ្រងថ្នាលឌីជីថលធុរកិច្ចថ្មីកម្ពុជា, ថ្នាលចុះបញ្ជីអាជីវកម្ម, ថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស - ប្រតិបត្តិ និងគ្រប់គ្រងថ្នាល CamDX, CamDigiKey, CamDL ជាដើម
១៩	ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ	- គ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងការរៀបចំតាក់តែងគោលនយោបាយ
២០	ក្រុមប្រឹក្សានីតិកម្ម	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធ និងថ្នាលបច្ចេកវិទ្យាបម្រើដល់មុខងាររបស់ខ្លួន

២១	ក្រុមប្រឹក្សាជាតិគាំពារសង្គម	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងថ្នាលគាំពារសង្គមឌីជីថល និងមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម
២២	គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និង គណនេយ្យភាព (PMAS)
២៣	គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតក្នុងវិស័យខ្លួន - គ្រប់គ្រងរបាយការណ៍អនុលោមភាព
២៤	គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល	- ប្រតិបត្តិ និងគ្រប់គ្រងថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងប្រព័ន្ធតាមដាន និងវាយតម្លៃ (M&E Portal)
២៥	គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	- ប្រមូលទិន្នន័យពាក់ព័ន្ធបម្រើដល់ការវិភាគម៉ាក្រូសេដ្ឋកិច្ច និងរៀបចំគោលនយោបាយ
២៦	គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា	- គ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងផលិតភាពសេដ្ឋកិច្ចកម្ពុជា
២៧	គណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា	- អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានដូចជា ប្រព័ន្ធគ្រប់គ្រងទិន្នន័យ, ប្រព័ន្ធបញ្ជាក់ទិន្នន័យ, ប្រព័ន្ធគ្រប់គ្រងប្រវត្តិតំបន់ហានិភ័យ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យអំពីការទទួលផល
២៨	ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធអេឡិចត្រូនិកកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ (Patient Management and Registration System – PMRS) - រៀបចំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការបញ្ជាក់ចំណាយក្នុងប្រព័ន្ធគាំពារសុខភាពសង្គមនៅកម្ពុជា
២៩	អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ	- ដឹកនាំ, គ្រប់គ្រង, អភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យ ប្រព័ន្ធបច្ចេកវិទ្យានិយ័តកម្ម និងប្រព័ន្ធផ្សេងទៀតគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
២៩.១	អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ	- ដឹកនាំ, គ្រប់គ្រង, អភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យ, ប្រព័ន្ធបច្ចេកវិទ្យានិយ័តកម្ម និងប្រព័ន្ធផ្សេងទៀតគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
២៩.២	និយ័តករមូលបត្រកម្ពុជា	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតក្នុងវិស័យរបស់ខ្លួន - គ្រប់គ្រងរបាយការណ៍អនុលោមភាព

២៩.៣	និយ័តករធានារ៉ាប់រងកម្ពុជា	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតក្នុងវិស័យរបស់ខ្លួន - គ្រប់គ្រងរបាយការណ៍អនុលោមភាព
២៩.៤	និយ័តកររសន្តិសុខសង្គម	- គ្រប់គ្រងប្រព័ន្ធទទួលរបាយការណ៍ និងទិន្នន័យ
២៩.៥	និយ័តករបេឆនបាលកិច្ច	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតក្នុងវិស័យរបស់ខ្លួន - គ្រប់គ្រងរបាយការណ៍អនុលោមភាព
២៩.៦	និយ័តករគណនេយ្យ និងសវនកម្ម	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតក្នុងវិស័យរបស់ខ្លួន - គ្រប់គ្រងរបាយការណ៍អនុលោមភាព
២៩.៧	និយ័តករអាជីវកម្មអចល-នវត្ថុ និងបញ្ចាំ	- ប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតក្នុងវិស័យរបស់ខ្លួន - គ្រប់គ្រងរបាយការណ៍អនុលោមភាព

ឧបសម្ព័ន្ធ ៦. សន្ទានុក្រម

ល.រ.	ភាសាអង់គ្លេស	ភាសាខ្មែរ	និយមន័យ
១.	Artificial Intellegence	បញ្ញាសិប្បនិម្មិត	បច្ចេកវិទ្យាដែលអនុញ្ញាតឱ្យម៉ាស៊ីនកុំព្យូទ័រមានសមត្ថភាពរៀន, គិត, វិភាគ និងយល់ដឹងពីបញ្ហាជាក់លាក់ណាមួយ តាមរយៈកុំព្យូទ័រ, ទូរស័ព្ទឆ្លាត ឬឧបករណ៍បច្ចេកវិទ្យានានា។
២.	Application Programming Interface	សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ	ច្រកចេញ-ចូលនៃទំនាក់ទំនងក្នុងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពីរ ឬ ច្រើន។
៣.	Big Data	ទិន្នន័យធំ	បណ្តុំទិន្នន័យដែលមានទំហំធំ មានច្រើនសណ្ឋាន និងជាទូទៅគ្មានរចនាសម្ព័ន្ធច្បាស់លាស់ ហើយត្រូវបានប្រើប្រាស់ដើម្បីវិភាគរកលំនាំ និន្នាការ និងការជាប់ទាក់ទងគ្នារវាងដែនមួយទៅដែនមួយទៀត។
៤.	Data Consumer	បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ	សំដៅដល់រូបវន្តបុគ្គល, នីតិបុគ្គលឯកជន, អាជ្ញាធរឯករាជ្យ, គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬសហគ្រាសសាធារណៈដែលធ្វើប្រព្រឹត្តកម្មទិន្នន័យរបស់ប្រធានទិន្នន័យក្នុងនាមជាបុគ្គលគ្រប់គ្រងទិន្នន័យ ឬអាជ្ញាធរសាធារណៈ។
៥.	Data Custodian	បុគ្គលគ្រប់គ្រងទិន្នន័យ	សំដៅដល់រូបវន្តបុគ្គល, នីតិបុគ្គលឯកជន, អាជ្ញាធរឯករាជ្យ, គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬសហគ្រាសសាធារណៈដែលកំណត់គោលបំណង និងមធ្យោបាយនៃការប្រមូល ការប្រើប្រាស់ ឬការលាតត្រដាងទិន្នន័យ។
៦.	Data-literate Culture	វប្បធម៌អក្ខរភាពទិន្នន័យ	សំដៅលើបរិយាកាសក្នុងអង្គភាពមួយ ដែលបុគ្គលិកគ្រប់កម្រិត មានសមត្ថភាពអាចយល់, បកស្រាយ និងប្រើប្រាស់ទិន្នន័យប្រកបដោយប្រសិទ្ធភាព ក្នុងដំណើរការធ្វើការសម្រេចចិត្ត និងប្រតិបត្តិការប្រចាំថ្ងៃ។
៧.	Data Owner	ប្រធានទិន្នន័យ	សំដៅអ្នកទទួលខុសត្រូវលើខ្លឹមសារ, អត្ថន័យ, និងគុណភាពទិន្នន័យ ព្រមទាំងផ្តល់ការយល់ព្រមលើការចែករំលែកទិន្នន័យទៅដល់បុគ្គលផ្សេងទៀតក្នុងគោលបំណងណាមួយ។

៨.	Data Steward	បុគ្គលអភិបាលកិច្ចទិន្នន័យ ឬបុគ្គលអធិការកិច្ចទិន្នន័យ	សំដៅដល់រូបវន្តបុគ្គល, នីតិបុគ្គលឯកជន, អាជ្ញាធរឯករាជ្យ, គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬសហគ្រាសសាធារណៈដែលតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តក្របខ័ណ្ឌអភិបាល-កិច្ចទិន្នន័យដែលបានព្រមព្រៀង។
៩.	Enterprise Architecture	និម្មាបនកម្មសហគ្រាស	ជាក្របខ័ណ្ឌទស្សនាទាន ក៏ដូចជាផែនទីមគ្គទេសក៍សម្រាប់រៀបចំកែសម្រួលមុខងារ និងយន្តការប្រតិបត្តិការ របស់តួអង្គពាក់ព័ន្ធទាំងអស់របស់ស្ថាប័ន ក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលមានភាពធំសំពីងសំពោង និងមានអន្តរសកម្មច្រើន ដើម្បីអាចសម្រេចគោលបំណងរបស់ស្ថាប័នដោយប្រសិទ្ធភាព។
១០.	Functional Requirement	មុខងារតម្រូវការ	ជាបញ្ជីនៃមុខងារដែលអង្គភាពជាម្ចាស់ និងជាអ្នកគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវកំណត់ ដែលមុខងារនោះគឺបម្រើដល់គោលបំណងស្នូលនៃការអភិវឌ្ឍប្រព័ន្ធ។
១១.	Non-Functional Requirement	មុខងារមិនតម្រូវការ	ជាបញ្ជីនៃមុខងារដែលអង្គភាពជាម្ចាស់ និងជាអ្នកគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវគោរពទៅតាមឯកសារណែនាំ នៅក្នុងស្រទាប់កម្មវិធី នៃក្របខ័ណ្ឌនិម្មាបនកម្មបច្ចេកវិទ្យាព័ត៌មាន។
១២.	Security Operation Center	មជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខ	គឺជាក្រុមអ្នកជំនាញផ្នែកសន្តិសុខព័ត៌មានវិទ្យា ដែលការពារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ពីការគំរាមកំហែងតាមអ៊ីនធឺណិត ដោយការត្រួតពិនិត្យ វិភាគ និងស៊ើបអង្កេត។
១៣.	User Expereince	បទពិសោធអ្នកប្រើ-ប្រាស់	ផ្តោតលើការរៀបចំរចនាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងមូលដោយផ្តែកលើបទពិសោធរបស់អ្នកប្រើ-ប្រាស់ សំដៅបង្កភាពងាយស្រួល, ភាពទាក់ទាញ និងភាពពេញចិត្តរបស់អ្នកប្រើប្រាស់ លើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយរួមបញ្ចូលនូវធាតុសំខាន់ៗ ដូចជា តម្រូវការអ្នកប្រើប្រាស់ និងទម្លាប់របស់អ្នកប្រើប្រាស់ ជាដើម។

១៤.	User Interface	ចំណុចប្រទាក់អ្នកប្រើប្រាស់	ផ្តោតលើការរៀបចំរចនាផ្នែកដែលអ្នកប្រើប្រាស់អាចមើលឃើញ និងធ្វើអន្តរកម្មបាន ដោយរួមបញ្ចូលដូចជា ប៊ូតុង, រូបតំណាង, ប្រភេទពុម្ពអក្សរ, ទំហំពុម្ពអក្សរ, ពណ៌ និងការចនាក្រាហ្វិក ជាដើម។


បរិសិទ្ធ ១. ការពិនិត្យលើស្ថានភាពបច្ចុប្បន្នផ្អែកតាមនិម្មាបនកម្មសហគ្រាស

ដើម្បីអាចស្វែងយល់ពីស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមនៃនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ទិដ្ឋភាពចំនួន ៤ ដែលរួមមាន (១)-ទិដ្ឋភាពមុខងារ, (២)-ទិដ្ឋភាពទិន្នន័យ, (៣)-ទិដ្ឋភាពប្រព័ន្ធ ឬកម្មវិធី និង (៤)-ទិដ្ឋភាពបច្ចេកវិទ្យា នឹងត្រូវយកមកពិនិត្យ និងពិភាក្សាដូចខាងក្រោម៖

១.១. ការពិនិត្យលើទិដ្ឋភាពមុខងារ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានអគ្គនាយកដ្ឋានក្រោមចំណុះសរុបចំនួន ១៦ អគ្គនាយកដ្ឋាន, គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ២ ព្រមទាំងមន្ទីរាជធានីខេត្ត សរុបចំនួន ២៥ (រូបភាពទី ១៣)។ បន្ថែមពីនេះ, អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលក្នុងនោះមាននិយ័តករចំនួន ៦ ព្រមទាំងគណៈកម្មាធិការ និងក្រុមប្រឹក្សាមួយចំនួនទៀត ក៏ស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។ អគ្គនាយកដ្ឋាន និងអង្គភាពនីមួយៗមានតួនាទី និងភារកិច្ចរៀងៗ ខ្លួន ដូចដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីការបង្កើត និងប្រកាសស្តីពីការរៀបចំប្រព្រឹត្តទៅ។ អគ្គនាយកដ្ឋាន និងអង្គភាពទាំងនោះក៏បានបង្កើតនាយកដ្ឋាន ឬការិយាល័យនៅក្រោមឱវាទរបស់ខ្លួន ដោយមានមុខងារ និងភារកិច្ចផ្សេងៗ ពីគ្នា សំដៅចូលរួមចំណែកបំពេញនូវបេសកកម្មរបស់ស្ថាប័នខ្លួន។ ក្នុងនោះ អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន **១៤** មាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ដែលបានបង្កើតឡើងដើម្បីបំពេញមុខងារលើការទ្រទ្រង់, រៀបចំ និងបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ប្រើប្រាស់ក្នុងការបំពេញមុខងារស្នូល និងមុខងារប្រតិបត្តិការរបស់ខ្លួន។ អគ្គនាយកដ្ឋាន និងអង្គភាពមួយចំនួនមានត្រឹមកម្រិតការិយាល័យបច្ចេកវិទ្យាព័ត៌មាន ឬក្រុមការងារបច្ចេកទេសនៅក្នុងនាយកដ្ឋានណាមួយ ដែលមានបុគ្គលិកជំនាញមួយចំនួននៅបម្រើការងារ និងសម្របសម្រួលលើការងារពាក់ព័ន្ធ។

រូបភាពទី ១៣៖ រចនាសម្ព័ន្ធអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាព ឬស្ថាប័ន ក្រោមអាណាព្យាបាល និងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០២៤


បច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន និងកំពុងអនុវត្តនូវគោលបំណងគោលនយោបាយ ចំនួន ២ និងកម្មវិធីចំនួន ៥ ដែលក្នុងនោះមានអនុកម្មវិធីសរុបចំនួន ៣២ ។ គោលបំណងគោល-នយោបាយទី ១ គឺការគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានកម្មវិធីចំនួន ២ គឺ (១)-ការគ្រប់គ្រងវិស័យសេដ្ឋកិច្ច និង (២)-ការគ្រប់គ្រងវិស័យហិរញ្ញវត្ថុ។ គោលបំណងគោលនយោបាយទី ២ គឺការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលមានកម្មវិធីចំនួន ៣ គឺ (១)-ការគ្រប់គ្រងចំណូលសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ, (២)-ការគ្រប់គ្រងចំណាយសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង (៣)-កិច្ចការរដ្ឋបាល និងអភិវឌ្ឍស្ថាប័ន។

(ក) ការកំណត់មុខងារអង្គភាពតាមក្របខ័ណ្ឌ COBIT ២០១៩

ការកំណត់មុខងារនេះ នឹងជួយដល់ការពិនិត្យមើលលើការស្នើសុំរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋាន ឬអង្គភាពនីមួយៗ ស្របតាមមុខងាររបស់ខ្លួន ក៏ដូចជាជួយដល់ការសម្រេចចិត្តលើការវិនិយោគសម្រាប់ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះ។ ទិន្នន័យទទួលបានពីក្របខ័ណ្ឌ COBIT ២០១៩ អាចបែងចែកអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទតាមមុខងារជា ៤ ក្រុមធំៗ ដែលក្នុងនោះរួមមាន៖ **(១)-មុខងារគាំទ្រ (Support)** សំដៅដល់អគ្គនាយកដ្ឋាន និងអង្គភាពដែល

ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សម្រាប់បម្រើមុខងារគាំទ្រដល់ដំណើរការរបស់ស្ថាប័ន តែបើទោះជាមិនមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក៏ដំណើរការការងាររបស់អគ្គនាយកដ្ឋាន និងអង្គភាពទាំងនោះ នៅតែអាចដំណើរការបាន, **(២)-មុខងារកសាង** (Factory) សំដៅដល់អគ្គនាយកដ្ឋាន និងអង្គភាពដែលប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សម្រាប់បម្រើដល់មុខងារស្នូលរបស់ស្ថាប័ន ហើយដំណើរការការងារមួយចំនួនត្រូវពឹងផ្អែកទៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ក្នុងករណីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះមានបញ្ហា ដំណើរការការងារនោះនឹងមានភាពយឺតយ៉ាវ ឬមិនអាចដំណើរការបានតែម្តង, **(៣)-មុខងារផ្លាស់ប្តូរ** (Turnaround) សំដៅដល់អគ្គនាយកដ្ឋាន និងអង្គភាពដែលប្រើប្រាស់បច្ចេក-វិទ្យាព័ត៌មាន សម្រាប់បម្រើការងារមួយចំនួន និងសម្រាប់ការបង្កើតនវានុវត្តន៍ថ្មីៗ សម្រាប់ស្ថាប័ន និង **(៤)-មុខងារយុទ្ធសាស្ត្រ** (Strategic) សំដៅដល់អគ្គនាយកដ្ឋាន និងអង្គភាពដែលប្រើប្រាស់បច្ចេក-វិទ្យាព័ត៌មាន សម្រាប់ជាធ្នឹងខ្នងរបស់ដំណើរការស្ថាប័នទាំងមូល។ ក្នុងករណីដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះមានបញ្ហា ដំណើរការការងាររបស់ស្ថាប័នទាំងមូលក៏នឹងប៉ះពាល់ខ្លាំង រហូតស្ទើរតែមិនអាចដំណើរការបាន។ យោងតាមទិន្នន័យដែលទទួលបាន, អគ្គនាយកដ្ឋាន និងអង្គភាពចំនួន ១១ ស្ថិតនៅក្នុងក្រុមទី ១ (Support), ចំនួន ៧ ស្ថិតនៅក្នុងក្រុមទី ២ (Factory), ចំនួន ១៣ ស្ថិតនៅក្នុងក្រុមទី ៣ (Turnaround) និងចំនួន ៤ ស្ថិតនៅក្នុងក្រុមទី ៤ (Strategic) ដូចបង្ហាញនៅក្នុងរូបភាពទី ១៤ ខាងក្រោមនេះ។ ការកំណត់មុខងារនេះ មិនមែនសំដៅលើថាអង្គភាពណា បានបំពេញមុខងារប្រសើរជាងអង្គភាពណានោះទេ ប៉ុន្តែជាការបែងចែកអង្គភាពទៅតាមក្រុមស្របតាមមុខងារ។

រូបភាពទី ១៤៖ បំណែងចែកអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទតាមមុខងារ



១. មុខងារគាំទ្រ (Support)

១. អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង
២. អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល
៣. ក្រុមប្រឹក្សានីតិកម្ម
៤. អគ្គនាយកដ្ឋានភាពជាដៃគូវ៉ាងរដ្ឋ និងឯកជន
៥. អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
៦. វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៧. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
៨. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
៩. គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
១០. គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា
១១. គណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា

២. មុខងារកសាង (Factory)

១. អគ្គនាយកដ្ឋានតេនាគារជាតិ
២. អគ្គនាយដ្ឋានថវិកា
៣. អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
៤. អគ្គនាយកដ្ឋានគោលនយោបាយ
៥. អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
៦. អគ្គាធិការដ្ឋាន
៧. ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ

៣. មុខងារផ្លាស់ប្តូរ (Turnaround)

១. អគ្គលេខាធិការដ្ឋាន
២. អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ
៣. អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
៤. គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល
៥. គណៈកម្មាធិការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
៦. ក្រុមប្រឹក្សាជាតិគាំពារសង្គម
៧. អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
៨. និយ័តករមូលបត្រកម្ពុជា
៩. និយ័តករធានាប់រងកម្ពុជា
១០. និយ័តករសន្តិសុខសង្គម
១១. និយ័តករបេឌបាលកិច្ច
១២. និយ័តករគណនេយ្យ និងសវនកម្ម
១៣. និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ

៤. មុខងារយុទ្ធសាស្ត្រ (Strategic)

១. អគ្គនាយកដ្ឋានពន្ធដារ
២. អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
៣. អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
៤. មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"

(ខ) ស្ថានភាពធនធានមនុស្ស

នៅក្នុងចក្ខុវិស័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះទី ១ គឺ "ប្រព័ន្ធអភិវឌ្ឍមូលធនមនុស្ស" ដោយកំណត់នូវអភិក្រមចំនួន ៤ គឺ "រើសត្រូវ បណ្តុះបណ្តាលត្រូវ ប្រើប្រាស់ត្រូវ និងទុកដាក់ត្រូវ"។ ដោយគិតតែអង្គភាពថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានមន្ត្រី និងបុគ្គលិកសរុបមានប្រមាណ ៧៤៩៥ នាក់។ ក្នុងនោះ បើគិតតែបុគ្គលិកមានជំនាញបច្ចេកវិទ្យាព័ត៌មាន និងកំពុងបម្រើការងារនៅតាមនាយកដ្ឋាន ឬការិយាល័យបច្ចេកវិទ្យាព័ត៌មាន មានសរុបចំនួន ៥១៥ នាក់ ដែលស្មើនឹងប្រមាណ ៦.៩% នៃបុគ្គលិកសរុប។ ក្នុងចំណោមមន្ត្រី និងបុគ្គលិកជំនាញបច្ចេកវិទ្យាព័ត៌មានទាំងអស់ ប្រមាណជា ៤១% គឺជាបុគ្គលិកផ្នែកអភិវឌ្ឍកម្មវិធី, ៣១% ជាបុគ្គលិកផ្នែកគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ, ៨% ជាបុគ្គលិកផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាន និង ១៨% ជាបុគ្គលិកដែលមានជំនាញផ្សេងៗ ដូចជា ជំនាញផ្នែកក្រាហ្វិក និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ ជាដើម។ ចំនួនមន្ត្រី និងបុគ្គលិកនៅតែមិនទាន់គ្រប់គ្រាន់ទៅតាមតម្រូវការសម្រាប់អគ្គនាយកដ្ឋាន និងអង្គភាពភាគច្រើន បើគិតជាមួយនឹងទំហំការងារដែលកំពុងមាន។ ការណ៍នេះ បានក្លាយជាបញ្ហាស្មុគស្មាញដែលថ្នាក់ដឹកនាំពិបាកដោះស្រាយកន្លងមក ដោយសារតែមិនមានក្របខ័ណ្ឌរួមមួយ ដែលបានចង្អុលបង្ហាញច្បាស់លាស់ និងកំណត់ពីរបៀបដែលអគ្គនាយកដ្ឋាន និងអង្គភាពត្រូវអនុវត្ត និងអនុលោមតាម។

ផ្អែកតាមទិន្នន័យខាងលើនេះ និងយោងតាមនិម្មាបនកម្មសហគ្រាស, អគ្គនាយកដ្ឋាន និងអង្គភាពទាំងអស់អាចបែងចែកជា ៣ ក្រុម ដែលក្នុងនោះ រួមមាន **ក្រុមទី ១ ដំណើរការពេញលេញ** (Full Stack) សំដៅដល់ក្រុមអគ្គនាយកដ្ឋានដែលប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពេញលេញតែម្តង ពោលគឺគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ និងមជ្ឈមណ្ឌលទិន្នន័យដោយខ្លួនឯង, អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយខ្លួនឯង និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយខ្លួនឯង ដែលមានអគ្គនាយកដ្ឋានចំនួន **៤** ស្ថិតនៅក្នុងក្រុមនេះ។ **ក្រុមទី ២ អភិវឌ្ឍន៍** (Development) សំដៅដល់អគ្គនាយកដ្ឋានដែលមានក្រុមការងារបច្ចេកទេស និងមានលទ្ធភាពក្នុងការអភិវឌ្ឍ និងប្រតិបត្តិប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយខ្លួនឯង ដែលមានអគ្គនាយកដ្ឋាន និងអង្គភាពចំនួន **១៦** ស្ថិតនៅក្នុងក្រុមនេះ។ **ក្រុមទី ៣ ប្រតិបត្តិការ** (Operation Only) សំដៅដល់អគ្គនាយកដ្ឋាន និងអង្គភាពមួយចំនួនដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីបំពេញការងារមួយចំនួន ប៉ុន្តែប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះត្រូវបានអភិវឌ្ឍដោយអង្គភាពផ្សេង ឬត្រូវបានទិញយកមកប្រើប្រាស់សម្រាប់ជាការប្រតិបត្តិការ ដែលមានអគ្គនាយកដ្ឋាន និងអង្គភាពចំនួន **១៥** ដែលស្ថិតនៅក្នុងក្រុមនេះ។

១.២. ការពិនិត្យលើទិដ្ឋភាពទិន្នន័យ

ទិន្នន័យ ជាធាតុចាំបាច់នៅក្នុងធុរកិច្ច និងការបំពេញមុខងាររបស់ស្ថាប័ន។ ខណៈដែលស្ថាប័នប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការងារប្រចាំថ្ងៃកាន់តែច្រើន និងការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (Artificial Intellegence) កាន់តែកើនឡើង, ទិន្នន័យ និងសុក្រឹតភាពនៃទិន្នន័យកាន់តែមានសារៈសំខាន់ដែលមិនអាចខ្វះបាន ហើយជាផ្នែកនៃធុរកិច្ចរបស់ស្ថាប័ន។ នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានទិន្នន័យជាច្រើន ដូចជាទិន្នន័យចំណូល (ពន្ធដារ, ពន្ធគយ និងចំណូលមិនមែនសារពើពន្ធ), ទិន្នន័យចំណាយ, ទិន្នន័យទ្រព្យរដ្ឋ, ទិន្នន័យបំណុល, ទិន្នន័យមូលបត្ររដ្ឋ,

ទិន្នន័យគម្រោង និងការវិនិយោគ, ទិន្នន័យអាជ្ញាបណ្ណ និងទិន្នន័យពាក់ពន្ធជាច្រើនទៀត។ នៅពេលដែលទិន្នន័យទាំងនោះ ត្រូវបានចែករំលែក និងមានអន្តរសកម្មជាមួយគ្នាទៅវិញទៅមក នឹងបង្កើតឱ្យក្លាយទៅជាបណ្តុំទិន្នន័យធំ (Big Data) ដែលអាចយកមកប្រើប្រាស់បម្រើដល់ការវិភាគផ្សេងៗ ព្រមទាំងប្រើប្រាស់សម្រាប់បញ្ញាសិប្បនិម្មិត។

ការអនុវត្តបច្ចុប្បន្ននៅក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ទិន្នន័យភាគច្រើននៅមានភាពរាយប៉ាយ, មិនមានសង្គតិភាព ហើយការចែករំលែកទិន្នន័យនៅមានកម្រិត។ អង្គភាពទាំងអស់ទោះជាមានប្រព័ន្ធ ឬមិនមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្តី, មានទិន្នន័យដែលបម្រើដល់មុខងាររបស់អង្គភាពខ្លួន និងមុខងាររបស់ក្រសួងទាំងមូល។ ភាគច្រើននៃទិន្នន័យទាំងនោះ គឺគ្រប់គ្រងដោយអង្គភាពដែលបំពេញលើការងារនោះ ឬគ្រប់គ្រងដោយអង្គភាពដែលជាអ្នកគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ត្បិតថាមានទិន្នន័យច្រើន ហើយមានប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យទាំងនោះ ប៉ុន្តែការចែករំលែកទិន្នន័យនៅមិនទាន់មានយន្តការច្បាស់លាស់ និងមិនអនុញ្ញាតឱ្យប្រព័ន្ធ និងប្រព័ន្ធធ្វើអន្តរប្រតិបត្តិការគ្នាទៅវិញទៅមកបានឡើយ ដោយភាគច្រើននៅតែបន្តប្រើប្រាស់ការស្នើសុំពីគ្នាទៅវិញទៅមកតាមរយៈការដាក់លិខិត។ ជាងនេះទៀត ប្រភេទទិន្នន័យ ឬទិន្នន័យអ្វីខ្លះដែលអាចចែករំលែកទៅវិញទៅមកបានក៏មិនទាន់បានកំណត់បានច្បាស់លាស់នៅឡើយ ដែលនៅតែបង្កជាបញ្ហាសម្រាប់ការយកទិន្នន័យទាំងនោះមកប្រើប្រាស់តាមតម្រូវការ និងភាពចាំបាច់។ ក្នុងនោះ អសង្គតិភាពនៃទិន្នន័យក៏ជាបញ្ហាសម្រាប់ការចែករំលែកទិន្នន័យ និងយកទិន្នន័យមកប្រើប្រាស់ផងដែរ។ ជាក់ស្តែង ក្នុងចំណោមទិន្នន័យទាំងនោះ មានតែទិន្នន័យនៃប្រព័ន្ធមួយចំនួនប៉ុណ្ណោះដែលបាន និងកំពុងធ្វើសន្ទានកម្ម។ ទិន្នន័យ និងប្រព័ន្ធទាំងនោះមានដូចជា ទិន្នន័យចំណូលពន្ធដារ, ទិន្នន័យចំណូលពន្ធគយ និងទិន្នន័យចំណូលមិនមែនសារពើពន្ធ ដែលបាន និងកំពុងធ្វើសន្ទានកម្មជាមួយនឹង FMIS ។ បញ្ហាចាក់ស្រេះទាំងនេះ បានធ្វើឱ្យអង្គភាពទាំងអស់ ក៏ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងមូល នៅមិនទាន់អាចប្រើប្រាស់ទិន្នន័យឱ្យមានប្រសិទ្ធភាពខ្ពស់នៅឡើយ។ សម្រាប់ឃ្លាំងទិន្នន័យ (Data Lake) ត្បិតថាទទួលបានគោលការណ៍ក្នុងការរៀបចំ ប៉ុន្តែស្ថិតនៅក្នុងដំណាក់កាលសិក្សា និងចាប់ផ្តើមនៅឡើយ ដែលនឹងត្រូវការពេលវេលាច្រើនទៀត ដើម្បីអាចសម្រេចបាន។ ដូចនេះ បញ្ហានេះនៅតែបន្តរាំងស្ទះដល់ការចែករំលែកទិន្នន័យឱ្យបានទូលំទូលាយ និងស្របតាមក្របខ័ណ្ឌច្បាស់លាស់។

អគ្គនាយកដ្ឋាន និងអង្គភាពជាច្រើននៅតែមានការព្រួយបារម្ភលើភាពជាម្ចាស់នៃទិន្នន័យនៅពេលដែលទិន្នន័យទាំងនោះត្រូវបានចែករំលែក។ ការណ៍នេះ បណ្តាលមកពីកង្វះនូវក្របខ័ណ្ឌច្បាស់លាស់មួយស្តីពីអភិបាលកិច្ចទិន្នន័យ ដែលចាំបាច់ត្រូវកំណត់នូវតួនាទី និងភាពជាម្ចាស់ទិន្នន័យក្នុងចំណោមអ្នកពាក់ព័ន្ធលើទិន្នន័យនោះឱ្យបានច្បាស់លាស់។ មួយវិញទៀត ជម្រើសនៃនិម្មាបនកម្មសម្រាប់អនុវត្តនៅក្នុងក្រសួង ក៏នៅមិនទាន់កំណត់ឱ្យបានច្បាស់លាស់ថាត្រូវប្រើប្រាស់ប្រភេទនៃនិម្មាបនកម្មមួយណានៅឡើយ។ ប៉ុន្តែជាឧត្តមានុវត្តន៍ ការអនុវត្តនិម្មាបនកម្មតាមបែបប្រព័ន្ធអេកូឡូស៊ីត្រូវបានប្រើប្រាស់ ដោយសារទិន្នន័យមិនត្រូវបានប្រមូលផ្តុំនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតែមួយនោះទេ ហើយទិន្នន័យត្រូវការផ្លាស់ប្តូរទៅវិញទៅមករវាងបណ្តាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានា ដើម្បីបម្រើដល់មុខងារធុរកិច្ចនៅក្នុងអង្គភាពនីមួយៗ ។ ការណ៍នេះ អាចផ្តល់លទ្ធភាពដល់ថ្នាក់ដឹកនាំ

បច្ចេកទេស និងថ្នាក់ដឹកនាំនយោបាយនៅក្នុងស្ថាប័ន ដែលមានតម្រូវការនៃការប្រើប្រាស់ទិន្នន័យឆ្លងអង្គភាព ចំណាយពេលវេលាតិចជាងមុន និងងាយស្រួលក្នុងការរៀបចំរបាយការណ៍ដែលផ្អែកលើទិន្នន័យទាំងនោះជាប្រចាំ។

១.៣. ការពិនិត្យលើទិដ្ឋភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ក្នុងបរិការណ៍ "បរិវត្តកម្មកម្មឌីជីថល" បច្ចេកវិទ្យាឌីជីថលបានរួមចំណែកយ៉ាងសំខាន់ក្នុងការបំពេញបេសកម្មរបស់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ ព្រមទាំងចូលរួមជាវិភាគទានក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ប្រើប្រាស់លើការងារប្រចាំថ្ងៃកាន់តែពេញនិយម និងបានកំពុងក្លាយជានិន្នាការថ្មីក្នុងចំណោមអគ្គនាយកដ្ឋានភាគច្រើន។ កន្លងមក អគ្គនាយកដ្ឋាន និងអង្គភាពដែលឱ្យតម្លៃលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបាន និងកំពុងអភិវឌ្ឍ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងយន្តការជាការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះដោយខ្លួនឯង, ជួលក្រុមហ៊ុនផ្តល់សេវាកម្មបច្ចេកវិទ្យាឱ្យអភិវឌ្ឍ ឬទិញស្រាប់យកមកប្រើប្រាស់តែម្តង និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអគ្គនាយកដ្ឋាន ឬអង្គភាពផ្សេងទៀតបានអភិវឌ្ឍ សម្រាប់ប្រើប្រាស់រួមនៅក្នុងក្របខ័ណ្ឌក្រសួង ឬរាជរដ្ឋាភិបាលទាំងមូល។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួន បានបង្កើតឡើង ដែលមានអ្នកប្រើប្រាស់ជាមន្ត្រី ឬបុគ្គលិក សម្រាប់ការបំពេញការងារប្រចាំថ្ងៃរបស់ខ្លួន ខណៈដែលប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានមួយចំនួនទៀតបានបង្កើតឡើង សម្រាប់បម្រើសេវាដល់អ្នកប្រើប្រាស់ផ្សេងទៀតដូចជាសហគ្រាស, ធុរកិច្ច ឬសាធារណៈជនទូទៅ ជាដើម។ ផ្អែកលើទិន្នន័យដែលបានប្រមូលក្នុងដើមឆ្នាំ ២០២៤, គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់មានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសរុបប្រមាណ ២០០ ប្រព័ន្ធ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះ អាចបែងចែកទៅជាបីប្រភេទធំៗ រួមមាន៖

(១) **ប្រព័ន្ធដែលបំពេញមុខងារស្នូល** សំដៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបង្កើតឡើងដើម្បីបម្រើដល់មុខងារស្នូលរបស់ស្ថាប័ន។ មុខងារស្នូលទាំងនោះមានដូចជាការប្រមូលចំណូល, ការគ្រប់គ្រងចំណាយ, ការគ្រប់គ្រងទ្រព្យរដ្ឋ, ការគ្រប់គ្រងបំណុល, ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច ជាដើម។ ប្រព័ន្ធដែលបំពេញមុខងារស្នូលនៅតាមអគ្គនាយកដ្ឋាន និងអង្គភាពទាំងអស់សរុបមានប្រមាន ៨៣ ប្រព័ន្ធ។ ត្បិតថាប្រព័ន្ធទាំងនោះ បង្កើតឡើងដើម្បីបម្រើដល់មុខងារស្នូលរបស់ស្ថាប័នដូចគ្នា ប៉ុន្តែប្រព័ន្ធទាំងនោះមានលក្ខណៈ និងវិសាលភាពខុសៗ គ្នា។

(២) **ប្រព័ន្ធដែលបំពេញមុខងាររួម** សំដៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបង្កើតឡើងដើម្បីបម្រើដល់កិច្ចការប្រតិបត្តិការប្រចាំថ្ងៃ ដែលកិច្ចការងារនោះមានលក្ខណៈរួម ឬដូចគ្នាពីស្ថាប័នមួយទៅស្ថាប័នមួយទៀត។ មុខងាររួមទាំងនោះមានដូចជា ការគ្រប់គ្រងបុគ្គលិក, ការគ្រប់គ្រងសវនកម្ម, ការគ្រប់គ្រងធនធាន និងឯកសារ, ការគ្រប់គ្រងទិន្នន័យរួម, ការផ្លាស់ប្តូរទិន្នន័យ ជាដើម។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបំពេញមុខងាររួមនៅតាមអគ្គនាយកដ្ឋាន និងអង្គភាពទាំងអស់សរុបមានប្រមាន ៣៤ ប្រព័ន្ធ។

(៣) ប្រព័ន្ធដែលបំពេញមុខងារប្រតិបត្តិការ សំដៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបង្កើតឡើងដើម្បីបម្រើដល់កិច្ចការប្រតិបត្តិការប្រចាំថ្ងៃរបស់ស្ថាប័ន។ មុខងារប្រតិបត្តិការទាំងនោះមានដូចជា ការងាររដ្ឋបាល និងហិរញ្ញវត្ថុ, ការបែងចែកតួនាទីភារកិច្ច, ការធ្វើស្វ័យប្រវត្តិកម្មការងារ, ការផ្សព្វផ្សាយជាដើម។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបំពេញមុខងារប្រតិបត្តិការនៅតាមអគ្គនាយកដ្ឋាន និងអង្គភាពទាំងអស់សរុបមានប្រមាន ៨២ ប្រព័ន្ធ។

កន្លងមក, អគ្គនាយកដ្ឋាន និងអង្គភាពនីមួយៗ បានចំណាយពេល និងធនធានច្រើនទៅលើការអភិវឌ្ឍ, ការថែទាំ និងប្រតិបត្តិការ ព្រមទាំងយន្តការសន្តិសុខឌីជីថល។ ជាងនេះទៀត ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅតាមបណ្តាអគ្គនាយកដ្ឋាន និងអង្គភាពមួយចំនួន ហាក់មិនបានគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ ដោយភាគច្រើនប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះត្រូវបានរៀបចំឱ្យគ្រាន់តែមានដែលខ្វះខាតលើមុខងារមួយចំនួនដូចជា សន្តិសុខឌីជីថល និងការធ្វើអន្តរប្រតិបត្តិការ ជាដើម។ នៅពេលដែលប្រព័ន្ធមិនអាចធ្វើអន្តរប្រតិបត្តិការជាមួយគ្នាបាន ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះអាចដំណើរការដោយឯករាជ្យបាន ប៉ុន្តែមិនអាចបំពេញមុខងារឱ្យគ្នាទៅវិញទៅមកបាន និងចែករំលែកទិន្នន័យជាមួយគ្នាបានឡើយ។ ការណ៍នេះ បណ្តាលឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះអាចនឹងធ្វើការងារដូចគ្នាម្តងហើយម្តងទៀត ជាហេតុនាំឱ្យខ្ជះខ្ជាយពេលវេលា និងធនធានច្រើន ទាំងធនធានមនុស្ស និងថវិកាក្នុងការអភិវឌ្ឍ និងការប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ហើយនាំឱ្យការបម្រើសេវាដល់អ្នកប្រើប្រាស់មិនសូវមានប្រសិទ្ធភាពខ្ពស់នោះទេ។

ការរៀបចំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានកន្លងមក ភាគច្រើនបានគិតគូរតែទៅលើមុខងារតម្រូវការ (Functional Requirement) របស់ប្រព័ន្ធ ដោយអង្គភាពនីមួយៗ បានកំណត់យ៉ាងច្បាស់ពីមុខងារដែលប្រព័ន្ធនោះត្រូវមាន ដើម្បីបំពេញការងារស្នូលរបស់ស្ថាប័នខ្លួន។ ផ្ទុយមកវិញ មុខងារមិនតម្រូវការ (Non-Functional Requirement) ហាក់ដូចជាត្រូវបានមើលរំលង និងកំណត់ឱ្យបានច្បាស់លាស់។ អង្គភាពមួយចំនួន ក៏បានគិតគូររៀបប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យមានមុខងារមិនតម្រូវការនេះដែរ ដែលបាននាំមកនូវបច្ច័យវិជ្ជមានដល់ការធ្វើអន្តរប្រតិបត្តិការរវាងប្រព័ន្ធ និងប្រព័ន្ធ ក៏ដូចជាការពិនិត្យលើសុវត្ថិភាពរបស់ប្រព័ន្ធ ជាដើម។ ការណ៍នេះ បានរំលេចឱ្យឃើញនូវភាពចាំបាច់ក្នុងការគិតគូរលើមុខងារទាំងពីរ និងភាពចាំបាច់នៃក្របខ័ណ្ឌ ឬគោលការណ៍ស្តង់ដាសម្រាប់ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលអង្គភាពទាំងអស់ត្រូវអនុលោមតាមនៅឡើយ។

កង្វះខាតនូវគោលការណ៍ស្តង់ដារួមសម្រាប់ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន បានធ្វើឱ្យប្រព័ន្ធទាំងនោះអាចនឹងជួបនូវបញ្ហាប្រឈមមួយចំនួននៅពេលដែលចង់ធ្វើសន្ទានកម្មរវាងប្រព័ន្ធ និងប្រព័ន្ធ ក៏ដូចជាការពង្រីកវិសាលភាពនៃប្រព័ន្ធទៅថ្ងៃអនាគត។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនត្រូវបានអភិវឌ្ឍដោយអគ្គនាយកដ្ឋាន ឬអង្គភាពផ្សេងគ្នា ខណៈដែលប្រព័ន្ធទាំងនោះបម្រើលើមុខងារដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដែលបណ្តាលឱ្យខ្ជះខ្ជាយធនធានក្នុងការវិនិយោគ។ ជាងនេះទៀត ប្រសិទ្ធភាពនៃការធានានូវសន្តិសុខសាយប័រក៏ជាបញ្ហាប្រឈមផងដែរ នៅពេលដែលការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗ មិនទាន់បានអនុលោមទៅតាមគោលការណ៍សុវត្ថិភាពបានត្រឹមត្រូវ ជាពិសេស

ចំពោះប្រព័ន្ធដែលគ្រប់គ្រង និងប្រតិបត្តិដោយអង្គភាពដែលមានធនធានតិច។ កង្វះនូវគោលការណ៍ស្តង់ដារួមក៏នាំឱ្យការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំណាយនូវធនធានច្រើនផងដែរ។

១.៤. ការពិនិត្យលើទិដ្ឋភាពបច្ចេកវិទ្យា

ស្រទាប់បច្ចេកវិទ្យា កំណត់ពីហេដ្ឋារចនាសម្ព័ន្ធ, ហាដវែរ, បច្ចេកវិទ្យាដែលប្រើប្រាស់ក្នុងការដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងថ្នាលឌីជីថលគ្រឹះដែលត្រូវប្រើប្រាស់ ដើម្បីឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបានរៀបចំ មានស្តង់ដា និងប្រើប្រាស់ធនធានរួម។ ស្រទាប់នេះរួមបញ្ចូលការប្រើប្រាស់កុំព្យូទ័ររួម, បណ្តាញរួម, ការប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យ និងមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យរួម, បច្ចេកវិទ្យាដាក់ដំណើរការរួម និងថ្នាលឌីជីថលគ្រឹះរួម ជាដើម។

ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន បានក្លាយជាឧបករណ៍ដែលស្ទើរតែមិនអាចខ្វះបានសម្រាប់បុគ្គលិក និងមន្ត្រី ពោលគឺច្រើនជាង ៨០% នៃបុគ្គលិក និងមន្ត្រីមានកុំព្យូទ័រប្រើប្រាស់។ ក្នុងនោះទូរស័ព្ទទំនើបក៏បានក្លាយជាឧបករណ៍ដ៏សំខាន់ ពិសេសប្រើប្រាស់សម្រាប់ការទំនាក់ទំនង និងការប្រើប្រាស់កម្មវិធីបច្ចេកវិទ្យាព័ត៌មានមួយចំនួនទៀត។ ឧទាហរណ៍ បុគ្គលិក និងមន្ត្រីត្រូវប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មាន (MEF Profile) តាមទូរស័ព្ទដៃសម្រាប់ការចុះវត្តមាន ជាដើម។ ខណៈដែលការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាព័ត៌មានកើនឡើងកាន់តែច្រើន ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថលក៏កាន់តែមានច្រើនដូចគ្នា។ ជាក់ស្តែង កុំព្យូទ័រភាគច្រើនត្រូវបានប្រើប្រាស់ដោយសេរី, យកទៅប្រើប្រាស់សម្រាប់ការងារផ្ទាល់ខ្លួនក្រៅពីការងាររបស់ស្ថាប័ន និងមិនមានអាជ្ញាបណ្ណប្រព័ន្ធ ឬកម្មវិធីដែលកំពុងប្រើប្រាស់ ជាដើម។ ការណ៍នេះ បានបណ្តាលឱ្យកើតឡើងនូវបញ្ហាមួយចំនួន រួមមានការឆ្លងមេរោគក្នុងកុំព្យូទ័រ, ការខូចកម្មវិធីក្នុងកុំព្យូទ័រ ព្រមទាំងការបាត់បង់ និងខូចខាតឯកសារ ជាដើមដែលរាំងស្ទះដល់ដំណើរការអនុវត្តការងារប្រចាំថ្ងៃ។

បណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានរៀបចំរួចរាល់ទាំងបណ្តាញតភ្ជាប់ផ្ទៃក្នុងអង្គភាព និងបណ្តាញតភ្ជាប់អន្តរអង្គភាពនៅក្រោមឱវាទក្រសួង។ នៅក្នុងទីស្តីការក្រសួងផ្ទាល់ បណ្តាញតភ្ជាប់ស្នូលត្រូវបានរៀបចំរួចរាល់ដែលអាចបម្រើដល់ការផ្តល់សេវាអ៊ីនធឺណិតរួមនៅទូទាំងទីស្តីការ, សេវាចែករំលែកទិន្នន័យឌីជីថល, ការទំនាក់ទំនងផ្ទៃក្នុងតាម-រយៈទូរស័ព្ទ (IP Phone) និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុង របស់អង្គភាពដែលស្ថិតនៅក្នុងទីស្តីការ។ ការតភ្ជាប់បណ្តាញនៅក្នុងទីស្តីការក្រសួង មានពីរប្រភេទ គឺការតភ្ជាប់ដោយប្រើប្រាស់ខ្សែ (Wire) និងការភ្ជាប់ដោយឥតខ្សែ (Wi-Fi)។ សម្រាប់អង្គភាព ក្រោមឱវាទក្រសួង ប៉ុន្តែទីតាំងស្ថិតនៅក្រៅទីស្តីការ ក៏មានបណ្តាញតភ្ជាប់ផ្ទៃក្នុងអគាររបស់ខ្លួនផងដែរ សម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរៀងៗ ខ្លួន និងតភ្ជាប់ជាមួយបណ្តាញអ៊ីនត្រាណិតរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដោយឡែកអង្គភាពក្រោមឱវាទក្រសួង នៅថ្នាក់មូលដ្ឋានដូចជា មន្ទីរ និងរតនាគារជជានី-ខេត្ត ស្ទើរតែទាំងអស់មិនទាន់មានប្រើប្រាស់សេវាបច្ចេកវិទ្យាព័ត៌មាននៅលើបណ្តាញតភ្ជាប់ស្នូល (អ៊ីនត្រាណិតរួមរបស់ក្រសួង) សម្រាប់គាំទ្រដល់ការងារប្រចាំថ្ងៃរបស់ខ្លួននៅឡើយទេ ដោយមានតែបណ្តាញតភ្ជាប់សម្រាប់ក្របខ័ណ្ឌនៃការប្រើប្រាស់ FMIS តែប៉ុណ្ណោះ។ ចំណែកឯសាខាពន្ធដារ និងសាខា/ការិយាល័យគយ និងរដ្ឋាករ ភាគច្រើនបានតភ្ជាប់បណ្តាញផ្ទៃក្នុងរួចរាល់ សម្រាប់ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

របស់អគ្គនាយកដ្ឋានរៀងៗ ខ្លួន ជាពិសេសលើការគ្រប់គ្រងការប្រមូលចំណូលពន្ធដារ និងចំណូលគយ និងរដ្ឋាករ។

ជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានរៀបចំដំឡើងបណ្តាញតភ្ជាប់ឆ្អឹងខ្នងដោយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកបានរួចរាល់មួយចំនួនធំ នៅក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដោយគិតចាប់ពីឆ្នាំ ២០២០ ដែលហៅថាបណ្តាញអ៊ិនត្រាណិតរួមក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ដោយធ្វើការតភ្ជាប់ចេញពីទីស្តីការក្រសួង ទៅកាន់ទីតាំងមជ្ឈមណ្ឌលទិន្នន័យទាំងអស់, ទីតាំងនៃអគ្គនាយក-ដ្ឋានដែលស្ថិតនៅក្រៅទីស្តីការក្រសួង, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, រតនាគារ, សាខាពន្ធដារ និងសាខាគយ និងរដ្ឋាករកម្ពុជារាជធានី-ខេត្ត មួយចំនួនដែលស្ថិតនៅតំបន់ក្រុងស្ទើរតែទាំងអស់។ ទោះបីជាមានបណ្តាញអ៊ីនត្រាណិតរួមនេះក្តី ក៏ការប្រើប្រាស់សេវាបច្ចេកវិទ្យាព័ត៌មាននៅលើបណ្តាញនេះនៅមានកម្រិតនៅឡើយ ពោលគឺនៅប្រើប្រាស់សម្រាប់តែសេវាផ្ទៃក្នុងរបស់អង្គភាពរៀងខ្លួនតែប៉ុណ្ណោះ លើកលែងតែប្រព័ន្ធសន្និសីទវីដេអូ ដែលបានដំណើរការនៅលើបណ្តាញនេះជារួម។ សម្រាប់បណ្តាញអ៊ីនធឺ-ណិត គឺមានតែនៅទីស្តីការក្រសួងប៉ុណ្ណោះដែលបាន និងកំពុងប្រើប្រាស់សេវាអ៊ីនធឺណិតរួមតាមរយៈបណ្តាញតភ្ជាប់ផ្ទៃក្នុងទាំងបណ្តាញមានខ្សែ និងបណ្តាញឥតខ្សែ ខណៈអគ្គនាយកដ្ឋាននៅក្រៅទីស្តីការក្រសួង និងអង្គភាពនានានៅថ្នាក់មូលដ្ឋាន នៅបន្តប្រើប្រាស់ផ្សេងគ្នានៅឡើយ។

ចំពោះមជ្ឈមណ្ឌលទិន្នន័យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកសាងមជ្ឈមណ្ឌលទិន្នន័យចំនួន ៤ ដែលមានអគ្គនាយកដ្ឋានចំនួន ៤ កំពុងគ្រប់គ្រង និងប្រតិបត្តិ។ ក្នុងនោះ អគ្គនាយកដ្ឋានចំនួន ៣ កំពុងគ្រប់គ្រង និងប្រតិបត្តិផ្ទាល់ខ្លួនរួមមានអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ អគ្គនាយកដ្ឋាននិងអង្គភាពផ្សេងទៀត បាន និងកំពុងប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលគ្រប់គ្រងដោយនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានរបស់អគ្គលេខាធិការដ្ឋានជាអ្នកគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យរួម។ ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់មជ្ឈមណ្ឌលទិន្នន័យខាងលើ នៅមានលក្ខណៈដូចគ្នាខ្លះ និងខុសគ្នាខ្លះ ផ្អែកតាមតម្រូវការនៃការកសាងរៀងៗ ខ្លួន ហើយក្របខ័ណ្ឌរួមក្នុងការរៀបចំ និងគ្រប់គ្រងក៏នៅមិនទាន់បានរៀបចំនៅឡើយ។

ក្នុងចំណោមមជ្ឈមណ្ឌលទិន្នន័យទាំង ៤ ខាងលើ, មានមជ្ឈមណ្ឌលទិន្នន័យចំនួន ២ ដែលមានមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ គឺ (១)-មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យនៃគម្រោង FMIS និង (២)-មជ្ឈមណ្ឌលសង្គ្រោះ ទិន្នន័យនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យដែលមានស្រាប់បច្ចុប្បន្ននេះ ក៏មិនទាន់គោរពបាននូវលក្ខខណ្ឌបច្ចេកទេសគ្រប់គ្រាន់នៅឡើយដែរ ដែលទាមទារឱ្យមានការគិតគូរក្នុងការពង្រឹង និងកែលម្អបន្ថែម ស្របតាមបទដ្ឋានបច្ចេកទេស។ ដោយឡែក សម្រាប់អគ្គនាយកដ្ឋានពន្ធដារ បើទោះបីជាមិនទាន់មានមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ ក៏អគ្គនាយកដ្ឋានបានរៀបចំនូវប្រព័ន្ធសង្គ្រោះ និងបម្រុងទិន្នន័យប្រកបដោយការទុកចិត្ត និងអាចធានាបាននូវការមិនបាត់បង់ទិន្នន័យ និងនិរន្តរភាពនៃការងារក្នុងកម្រិតមួយផងដែរ។ ចំណែកឯមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យរួមនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺកំពុងតែរៀបចំតាមគោលការណ៍ដែលទទួលបាន។

នៅពេលដែលមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យបានកសាងរួចរាល់ គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពទាំងអស់នឹងត្រូវប្រើប្រាស់រួមគ្នាតាមគោលការណ៍។

ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញតភ្ជាប់ និងមជ្ឈមណ្ឌលទិន្នន័យនៅមានទាន់មានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់នៅឡើយ។ បច្ចុប្បន្ន អគ្គនាយកដ្ឋានចំនួន ៤ ដែលមានលទ្ធភាពប្រតិបត្តិ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដោយខ្លួនឯង។ ក្នុងនោះអគ្គលេខាធិការដ្ឋានមានតួនាទីគ្រប់គ្រង និងសម្របសម្រួលដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់អគ្គនាយកដ្ឋាន និងអង្គភាពផ្សេងទៀតស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះជាយ៉ាងនេះក្តី អគ្គនាយកដ្ឋានមួយចំនួនក៏នៅបន្តប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនដែលមាន ដោយមិនទាន់បានផ្លាស់ប្តូរមកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួមនៅឡើយ ដោយសារតែកង្វះខាតធនធានក្នុងការផ្លាស់ប្តូរ។ មួយវិញទៀត ក្នុងពេលបច្ចុប្បន្ននេះ ការផ្តល់សេវាពីអគ្គលេខាធិការដ្ឋានក៏នៅមានកម្រិត ដោយសារតែចំនួនធនធាននៅខ្វះខាត និងមានចំនួនបុគ្គលិកតិច។

បរិសិទ្ធ ២. លទ្ធផលពីក្របខ័ណ្ឌ COBIT ២០១៩

COBIT ដែលពាក្យពេញគឺ Control Objectives for Information and Related Technology គឺជាឧបករណ៍ដែលត្រូវបានបង្កើតឡើងដោយសមាគមសវនកម្ម និងត្រួតពិនិត្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Information Systems Audit and Control Association – ISACA) ក្នុងគោលបំណងប្រើប្រាស់សម្រាប់ការវាយតម្លៃ និងអភិបាលកិច្ចប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានាឱ្យបាននូវការប្រើប្រាស់ប្រកបដោយគុណភាព, ប្រសិទ្ធភាព និងភាពជឿជាក់នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ក្របខ័ណ្ឌ COBIT 2019 បានបែងចែកគោលដៅសម្រាប់អភិបាលកិច្ច និងការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ចំនួន ៤០ ។ ការវិភាគទិន្នន័យដែលប្រមូលបានពីអង្គភាពចំនួន ១៥ បានបង្ហាញថា ក្នុងចំណោមគោលដៅចំនួន ៤០, គោលដៅធំៗ ចំនួន ១១ ត្រូវបានចាត់ទុកថាជាគោលដៅសំខាន់ដែលអគ្គនាយកដ្ឋាន និងអង្គភាព ត្រូវសម្រេចឱ្យបាន ដើម្បីធានាឱ្យបាននូវការសម្រេចនូវគោល-បំណងចម្បងរបស់ស្ថាប័ន។ គោលដៅទាំងនោះរួមមាន (១)-ការធានាឱ្យបាននូវការកំណត់ និងការថែទាំក្របខ័ណ្ឌអភិបាលកិច្ច តាមរយៈការប្រើប្រាស់វិធីសាស្ត្រដែលឆ្លើយតបនឹងគោលបំណងរបស់ស្ថាប័ន ហើយក៏ធានាឱ្យបាននូវភាពប្រទាក់ក្រឡាគ្នារវាងភាគីពាក់ព័ន្ធ, (២)-ការធានាឱ្យបាននូវការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន, (៣)-ការធានាឱ្យបាននូវការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ, (៤)-ការគ្រប់គ្រងនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការបង្កើតឱ្យមាននូវអន្តរសេកម្មរវាងភាគីពាក់ព័ន្ធ, (៥)-ការគ្រប់គ្រងទំនាក់ទំនងរវាងភាគីពាក់ព័ន្ធ, (៦)-ការគ្រប់គ្រងគុណភាព (ដំណោះ-ស្រាយ និងសេវាបច្ចេកវិទ្យាព័ត៌មាន), (៧)-ការគ្រប់គ្រងទិន្នន័យ តាមរយៈការប្រើប្រាស់ និងការបែងចែកទិន្នន័យប្រកបដោយប្រសិទ្ធភាព និងតម្លាភាព, (៨)-ការគ្រប់គ្រងការកំណត់អត្តសញ្ញាណ និងបង្កើតដំណោះស្រាយ, (៩)-ការគ្រប់គ្រងការស្នើសុំសេវា និងការដោះស្រាយបញ្ហានៃប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មាន, (១០)-ការគ្រប់គ្រងការអនុវត្ត និងការត្រួតពិនិត្យអនុលោមភាពរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប្រកបដោយតម្លាភាព, និង (១១)-ការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុងប្រកបដោយតម្លាភាពរបស់ភាគីពាក់ព័ន្ធ។

តាមរយៈគោលដៅចម្បងទាំង ១១ នេះ, យើងអាចទាញជាសេចក្តីសន្និដ្ឋានជាបឋមចំនួន ៣ រួមមាន (១)-ការរៀបចំនូវនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលតម្រូវឱ្យមានអន្តរសេកម្មរវាងអគ្គនាយកដ្ឋាន និងអង្គភាពទៅតាមភាពចាំបាច់ និងត្រូវធានាឱ្យបានថា អគ្គនាយកដ្ឋាន និងអង្គភាពមានសិទ្ធិសម្រេច និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុង ក៏ដូចជាទិន្នន័យរបស់ខ្លួន។ និយាយជារួម អគ្គនាយកដ្ឋាន និងអង្គភាព នៅតែរក្សានូវអធិបតេយ្យភាពសិទ្ធិ, អំណាច និងតួនាទីរបស់ខ្លួនទន្ទឹមនឹងចូលរួមយ៉ាងសកម្មបន្ថែមទៀត នៅក្នុងប្រព័ន្ធអេកូឡូស៊ីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (២)-ការចែករំលែកទិន្នន័យប្រកបដោយតម្លាភាពរវាងអគ្គនាយកដ្ឋាន និងអង្គភាព ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទិន្នន័យដែលមានស្រាប់ និង (៣)-ការប្រើប្រាស់ធនធាន នឹងដោះស្រាយបញ្ហានៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានប្រកបដោយប្រសិទ្ធភាព តាមរយៈការប្រើប្រាស់នូវធនធានដែលមានស្រាប់រួមគ្នា និងកំណត់នូវតួនាទី និងទំនួលខុសត្រូវច្បាស់លាស់។


ក្នុងចំណោមសំណួរទាំងនោះ, ទម្រង់នៃហានិភ័យ (Risk Profile) ដែលទាក់ទងនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានសាកសួរពីអគ្គនាយកដ្ឋាន និងអង្គភាពនីមួយៗ ដើម្បីកំណត់នូវប្រភេទ ក៏ដូចជា កម្រិត ឬទំហំនៃហានិភ័យទាំងនោះមកលើដំណើរការនៃអគ្គនាយកដ្ឋាន និងអង្គភាពទាំងមូល។ ប្រភេទនៃហានិភ័យអាចបែងចែកជា ៣ ប្រភេទធំៗ រួមមាន (១)-ការគ្រប់គ្រងផ្ទៃក្នុង (ដូចជា កង្វះការប្តេជ្ញាចិត្តក្នុងការវិនិយោគលើបច្ចេកវិទ្យាពីសំណាក់ថ្នាក់ដឹកនាំ និងកង្វះការគ្រប់គ្រងវដ្តនៃកម្មវិធី និងគម្រោង), (២)-បុគ្គលិក (ឧទាហរណ៍ដូចជា ចំណេះដឹង និងជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈរបស់បុគ្គលិក), និង (៣)-កត្តាខាងក្រៅ (ឧទាហរណ៍ដូចជា ការលួចវាយប្រហារ និងបញ្ហាទាក់ទងនឹងអ្នកផ្គត់ផ្គង់)។ កម្រិតនៃហានិភ័យបានបែងចែកជា ៥ ប្រភេទ តាមរយៈការធ្វើផលគុណនៃភាពញឹកញាប់ដែលហានិភ័យទាំងនោះនឹងអាចកើតឡើង និងកម្រិតនៃភាពពាក់ព័ន្ធនៃប្រភេទហានិភ័យទាំងនោះនៅក្នុងអគ្គនាយកដ្ឋាន និងអង្គភាពនីមួយៗ ។ កម្រិតនៃហានិភ័យកាន់តែខ្ពស់ បញ្ជាក់ពីការដែលត្រូវយកចិត្តទុកដាក់កាន់តែខ្លាំង ដើម្បីគ្រប់គ្រង, កាត់បន្ថយ ឬបញ្ចៀសផលប៉ះពាល់ពីប្រភេទនៃហានិភ័យទាំងនោះ។

បរិសិទ្ធ ៣. ក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ

ជាទូទៅ អភិបាលកិច្ចទិន្នន័យនឹងអនុលោមតាមអភិក្រមចំនួន ៣ ដែលរួមមាន (**១)-មនុស្ស, (២)-ដំណើរការ និង (៣)-បច្ចេកវិទ្យា**។ អភិក្រម **"មនុស្ស"** ត្រូវបានចាត់ទុកជាមូលដ្ឋានគ្រឹះនៅក្នុងអភិបាលកិច្ចទិន្នន័យ ដោយសារពួកគេជាអ្នកបង្កើត, ប្រមូល, ប្រើប្រាស់ និងគ្រប់គ្រងទិន្នន័យ។ ដូចនេះ ការកំណត់តួនាទី និងទំនួលខុសត្រូវ ដែលរួមមាន ប្រធានទិន្នន័យ (Data Owner), បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ (Data Consumer), បុគ្គលគ្រប់គ្រងទិន្នន័យ (Data Custodian) និងបុគ្គលអភិបាលកិច្ចទិន្នន័យ ឬបុគ្គលអធិការកិច្ចទិន្នន័យ (Data Steward) ជាភាពចាំបាច់ដែលមិនអាចខ្វះបាននៅក្នុងអភិបាលកិច្ចទិន្នន័យ។ នៅក្នុងឯកសារក្របខ័ណ្ឌនិម្មាបនកម្មនេះ, **"មនុស្ស"** សំដៅលើអង្គភាពដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតួអង្គពាក់ព័ន្ធដទៃទៀតនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បន្ថែមលើការកំណត់តួនាទី និងទំនួលខុសត្រូវ, អភិក្រម **"មនុស្ស"** ក៏សំដៅលើភាពសំខាន់ក្នុងការអប់រំ និងបណ្តុះបណ្តាលបុគ្គលិកពីគោលការណ៍ និង ការអនុវត្តលើអភិបាលកិច្ចទិន្នន័យ។ ការណ៍នេះ នឹងជួយបង្កើតនូវវប្បធម៌អក្ខរភាពទិន្នន័យ (Data-Literate Culture) នៅក្នុងស្ថាប័ន។

ចំណែកអភិក្រម **"ដំណើរការ"** ត្រូវបានចាត់ទុកថាជាក្របខ័ណ្ឌសម្រាប់គ្រប់គ្រងទិន្នន័យ (Data Management Framework) ក្នុងអភិបាលកិច្ចទិន្នន័យ។ **"ដំណើរការ"** សំដៅលើការរៀបចំរចនាសម្ព័ន្ធសម្រាប់អភិបាលកិច្ចទិន្នន័យ។ បន្ថែមពីនេះ **"ដំណើរការ"** ក៏កំណត់រំហូរការងារ និងនីតិវិធីសម្រាប់ការគ្រប់គ្រងទិន្នន័យ ដែលនឹងរួមបញ្ចូលទាំងការត្រួតពិនិត្យគុណភាពទិន្នន័យ (Data Quality Check), ការគ្រប់គ្រងការចូលប្រើប្រាស់ទិន្នន័យ (Access Control), ការតាមដានរំហូរនៃទិន្នន័យ (Data Lineage Tracking) និងគោលការណ៍រក្សាទិន្នន័យ (Data Retention) ជាដើម។ ជាផ្នែកមួយនៃការរៀបចំរចនាសម្ព័ន្ធសម្រាប់អភិបាលកិច្ចទិន្នន័យ, ការកំណត់ពីទិន្នន័យ (Data Discovery), ការបែងចែកប្រភេទទិន្នន័យ (Data Classification), ការកំណត់អំពីអភិក្រម ឬគោលនយោបាយនៃការគ្រប់គ្រងទិន្នន័យ (Data Policy or Principle) និងការកំណត់វិធានជាក់លាក់សម្រាប់គ្រប់គ្រងទិន្នន័យ (Data Rule) ជាជំហានមួយដែលមិនអាចខ្វះបាន។ ការកំណត់ពីទិន្នន័យនឹងផ្តល់ជាមូលដ្ឋានពេញលេញ ដើម្បីឱ្យយើងអាចដឹង និងកំណត់បានពីទិន្នន័យដែលមានក្នុងស្ថាប័ននីមួយៗ និងទិន្នន័យដែលមានក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗ ជាដើម។ បន្ទាប់មកទិន្នន័យទាំងនោះត្រូវយកមកធ្វើការបែងចែក តាមរយៈប្រភេទ ឬភាពរសើបនៃទិន្នន័យ ដែលកំណត់ដោយបទប្បញ្ញត្តិរបស់ស្ថាប័នផ្ទាល់ ឬរបស់ប្រទេសជារួមតែម្តង។ ផ្អែកលើការកំណត់ពីទិន្នន័យ និងការបែងចែកទិន្នន័យ, អភិក្រមសម្រាប់ការគ្រប់គ្រង និងចែករំលែកទិន្នន័យទាំងនោះនឹងត្រូវបានកំណត់។ ជំហានចុងក្រោយ វិធានជាក់លាក់សម្រាប់ការចែករំលែក ឬគ្រប់គ្រងទិន្នន័យទាំងនោះ នឹងត្រូវបានកំណត់នៅក្នុងអភិក្រមនៃការគ្រប់គ្រងទិន្នន័យ ។ រូបភាពទី ១៥ ខាងក្រោមនេះបង្ហាញពីជំហានទាំង ៤ នៃការរៀបចំអភិបាលកិច្ចទិន្នន័យ។

រូបភាពទី ១៥៖ ជំហាននៃការរៀបចំអភិបាលកិច្ចទិន្នន័យ



អង្គភាពទាំងអស់ ទោះជាមានប្រព័ន្ធ ឬមិនមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន មានទិន្នន័យដែលបម្រើដល់មុខងាររបស់អង្គភាពខ្លួន និងមុខងាររបស់ក្រសួងទាំងមូល។ ភាគច្រើននៃទិន្នន័យទាំងនោះគឺគ្រប់គ្រងដោយអង្គភាពដែលបំពេញលើការងារនោះ ឬក៏គ្រប់គ្រងដោយអង្គភាពដែលជាអ្នកគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ទិន្នន័យទាំងនោះមានច្រើនប្រភេទ អាស្រ័យតាមមុខងាររបស់អង្គភាពនីមួយៗ ប៉ុន្តែអាចបែងចែកទៅជា ៦ ប្រភេទធំៗ ដែលរួមមានទិន្នន័យអំពី (១)-ការគ្រប់គ្រងចំណូល, (២)-ការអនុវត្តចំណូល-ចំណាយ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យនៃថវិការដ្ឋ, (៣)-ការវិនិយោគសាធារណៈ, (៤)-ឧស្សាហកម្មហិរញ្ញវត្ថុ,(៥)-រដ្ឋបាល, ធនធានមនុស្ស, សារពើភណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ និងសេវាសាធារណៈ និង (៦)-ម៉ាក្រូសេដ្ឋកិច្ច, សវនកម្ម និងអធិការកិច្ច។ ត្បិតថាមានទិន្នន័យច្រើន, ការអនុវត្តបច្ចុប្បន្ននៅក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទិន្នន័យភាគច្រើននៅមានភាពរាយប៉ាយ, មិនមានសង្គតិភាព ហើយការចែករំលែកទិន្នន័យនៅមានកម្រិត។ ការចែករំលែកទិន្នន័យនៅមិនទាន់មានយន្តការច្បាស់លាស់ និងអនុញ្ញាតឱ្យប្រព័ន្ធ និងប្រព័ន្ធធ្វើអន្តរប្រតិបត្តិការគ្នាទៅវិញទៅមកបានឡើយ ដោយភាគច្រើននៅតែបន្តប្រើប្រាស់ការស្នើសុំពីគ្នាទៅវិញទៅមកតាមរយៈការដាក់លិខិត ដែលត្រូវចំណាយពេលវេលាច្រើន និងមានភាពស្មុគស្មាញ។ ជារួម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុខ្វះខាតនូវក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យ និងក្របខ័ណ្ឌអន្តរប្រតិបត្តិការច្បាស់លាស់មួយសម្រាប់ប្រើប្រាស់ក្នុងការចែករំលែកទិន្នន័យសម្រាប់កម្រិតផ្ទៃក្នុងស្ថាប័នខ្លួន។

ការអនុវត្តជាប្រព័ន្ធអេកូឡូស៊ីបែបរមិជ្ឈការ, ទិន្នន័យមិនត្រូវប្រមូលផ្តុំនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតែមួយនោះទេ ហើយទិន្នន័យត្រូវការផ្លាស់ប្តូរទៅវិញទៅមករវាងបណ្តាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានា ដើម្បីបម្រើដល់មុខងារធុរកិច្ចនៅក្នុងស្ថាប័ននីមួយៗ ។ ជាងនេះទៀត ស្ថាប័ននីមួយៗមានសិទ្ធ និងតួនាទីពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យរបស់ខ្លួន បើទោះជាស្ថាប័ននោះប្រើប្រាស់ប្រព័ន្ធរបស់អគ្គនាយកដ្ឋានផ្សេងក៏ដោយ។ បច្ចុប្បន្ន ក្នុងទិដ្ឋភាពក្របខ័ណ្ឌប្រព័ន្ធអេកូ-ឡូស៊ីឌីជីថលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនដូចជា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ, ប្រព័ន្ធអាស៊ីគូដារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ បានធ្វើសន្ធានកម្មទិន្នន័យជាមួយ FMIS ដែលជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្នូល សម្រាប់ទិន្នន័យសំខាន់ៗ មួយចំនួន។ ប៉ុន្តែ ការធ្វើសន្ធានកម្មលើទិន្នន័យទាំងនេះ នៅមានចំនួនតិចតួចនៅឡើយ បើធៀបទៅនឹងទិន្នន័យដែលមាននៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនេះ។ លើសពីនេះ ប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានជាច្រើនទៀត នៅមិនទាន់បាន ឬមិនទាន់មានលទ្ធភាពធ្វើសន្ធានកម្មទិន្នន័យជាមួយគ្នានៅឡើយទេ។ ការណ៍នេះ បានបណ្តាលឱ្យការប្រើប្រាស់ទិន្នន័យពីគ្នាទៅវិញទៅមក នៅតែជួបបញ្ហា ហើយរាំងស្ទះដល់ការទាញយកប្រយោជន៍ជាអតិបរិមានពីទិន្នន័យដែលមាន។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាំបាច់ត្រូវរៀបចំអភិបាលកិច្ចទិន្នន័យ និងក្របខ័ណ្ឌអន្តរប្រតិបត្តិការឱ្យបានច្បាស់លាស់ និងគត់មត់ សម្រាប់ជាក្របខ័ណ្ឌរួមមួយរបស់ក្រសួង ដើម្បីពង្រឹងដល់វប្បធម៌នៃការធ្វើការដោយផ្អែកលើទិន្នន័យ។

ផ្អែកតាមដំហាននៃការបែងចែកទិន្នន័យ ទាំង ៤ ដំហាននេះ, អថេរសំខាន់ៗ របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់តាមសូចនាករសំខាន់ៗ ដូចជា ប្រភេទទិន្នន័យ, មុខងារនៃអង្គភាពលើទិន្នន័យ, ភាពទៀងទាត់នៃការចែករំលែក, វិធីសាស្ត្រក្នុងការចែករំលែកទិន្នន័យ និងភាពរសើបនៃការចែករំលែកទិន្នន័យ ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោម។

តារាងទី ១៖ សូចនាករ និងនិយមន័យសម្រាប់ការរៀបចំរចនាសម្ព័ន្ធអភិបាលកិច្ចទិន្នន័យ


បំណែកចែក	ប្រភេទ	និយមន័យ
ប្រភេទទិន្នន័យ	ទិន្នន័យគោល (Base registries)	ព័ត៌មានលម្អិតអំពីបុគ្គល ឬគ្រឹះស្ថាន ដែលប្រើប្រាស់សម្រាប់ការកំណត់អត្តសញ្ញាណ (ឧ. ព័ត៌មានលម្អិតរបស់ក្រុមហ៊ុនដែលស្នើសុំអាជ្ញាបណ្ណ)។
	ប្រតិបត្តិការ (Transactional)	ទិន្នន័យដែលទទួលបានពីប្រតិបត្តិការ ដែលក្នុងនោះអាចមានដូចជា ពេលវេលា, ទីតាំង តម្លៃ, ... (ឧ. ចំនួន Claim ពីធានារ៉ាប់រងប្រចាំថ្ងៃ, Shipping status)។
	ស្ថិតិ (Statistical)	ជាទិន្នន័យដែលបានមកពីការវិភាគពីទិន្នន័យដើម (ឧ. ចំនួនអាជ្ញាបណ្ណសរុបដែលនិយ័តករបានផ្តល់ឱ្យក្នុងរយៈពេលមួយខែ ឬមួយឆ្នាំ)។

	របាយការណ៍ (Reporting)		ជារបាយការណ៍ដែលត្រូវបានរៀបចំតាមពេលវេលាកំណត់ សម្រាប់ដាក់ជូនទៅស្ថាប័នពាក់ព័ន្ធ (ឧ. របាយការណ៍សមិទ្ធផល, ផែនការសកម្មភាព)។
មុខងារ	ប្រធានទិន្នន័យ (Data Owner)		សំដៅអ្នកទទួលខុសត្រូវលើខ្លឹមសារ, អត្ថន័យ, និងគុណភាពទិន្នន័យ ព្រមទាំងផ្តល់ការយល់ព្រមលើការចែករំលែកទិន្នន័យទៅដល់បុគ្គលផ្សេងទៀតក្នុងគោលបំណងណាមួយ។
	បុគ្គលគ្រប់គ្រងទិន្នន័យ (Data Custodian)		សំដៅដល់រូបវន្តបុគ្គល, នីតិបុគ្គលឯកជន, អាជ្ញាធរឯករាជ្យ, គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ សហគ្រាសសាធារណៈដែលកំណត់គោលបំណងនិងមធ្យោបាយនៃការប្រមូល ការប្រើប្រាស់ ឬការលាតត្រដាងទិន្នន័យ។
	បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ (Data Consumer)		សំដៅដល់រូបវន្តបុគ្គល, នីតិបុគ្គលឯកជន, អាជ្ញាធរឯករាជ្យ, គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ សហគ្រាសសាធារណៈដែលធ្វើប្រព្រឹត្តកម្មទិន្នន័យរបស់ប្រធានទិន្នន័យក្នុងនាមជាបុគ្គលគ្រប់គ្រងទិន្នន័យ ឬអាជ្ញាធរសាធារណៈ។
	បុគ្គលអភិបាលកិច្ចទិន្នន័យ ឬ បុគ្គលអធិការកិច្ចទិន្នន័យ (Data Steward)		សំដៅដល់រូបវន្តបុគ្គល, នីតិបុគ្គលឯកជន, អាជ្ញាធរឯករាជ្យ, គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ សហគ្រាសសាធារណៈដែលតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យដែលបានព្រមព្រៀង។
ភាពទៀងទាត់	ភ្លាមៗ		ទិន្នន័យនឹងត្រូវចែករំលែកភ្លាមៗ បន្ទាប់ពីប្រតិបត្តិការ
	ប្រចាំម៉ោង		ទិន្នន័យនឹងត្រូវចែករំលែកប្រចាំម៉ោង
	ប្រចាំថ្ងៃ		ទិន្នន័យនឹងត្រូវចែករំលែកប្រចាំថ្ងៃ
	ប្រចាំខែ		ទិន្នន័យនឹងត្រូវចែករំលែកប្រចាំខែ
	ប្រចាំត្រីមាស		ទិន្នន័យនឹងត្រូវចែករំលែកប្រចាំត្រីមាស
	ប្រចាំឆមាស		ទិន្នន័យនឹងត្រូវចែករំលែកប្រចាំឆមាស
	ប្រចាំឆ្នាំ		ទិន្នន័យនឹងត្រូវចែករំលែកប្រចាំឆ្នាំ
វិធីសាស្ត្រ	ចែករំលែកដោយផ្ទាល់	ជាក្រដាស	ទិន្នន័យចែករំលែកជាទម្រង់ក្រដាស
		Reporting (PDF, Word, PTT)	ទិន្នន័យចែករំលែកជាទម្រង់ PDF, Word, PowerPoint
		Excel	ទិន្នន័យចែករំលែកជាទម្រង់ Excel
		CSV	ទិន្នន័យចែករំលែកជាទម្រង់ CSV
	ពីប្រព័ន្ធទៅប្រព័ន្ធ	JSON	ទិន្នន័យចែករំលែកជាទម្រង់ JSON
		XML	ទិន្នន័យចែករំលែកជាទម្រង់ XML

ភាពរសើប	សាធារណៈ (Public)	ទិន្នន័យដែលអាចចែករំលែកសម្រាប់សាធារណៈទូទៅ
	ផ្ទៃក្នុង (Internal)	ទិន្នន័យសម្រាប់តែចែករំលែក និងប្រើប្រាស់ផ្ទៃក្នុងក្រសួង
	ព័ត៌មានសម្ងាត់ (Confidential)	ទិន្នន័យសម្ងាត់សម្រាប់ស្ថាប័ន ដែលអាចចែករំលែក និងប្រើប្រាស់បាន ក្នុងករណីមានការយល់ព្រមពីប្រធានទិន្នន័យ។
	Restricted	ទិន្នន័យដែលមានភាពរសើបខ្លាំង ហើយអាចមានផលប៉ះពាល់ដល់ស្ថាប័ន ក្នុងករណីមានការលេចធ្លាយ។


នៅក្នុងដំណាក់កាលនៃការកំណត់ពីទិន្នន័យនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, យើងឃើញថាប្រភេទនៃទិន្នន័យអាចមានរហូតដល់ ១៨ ប្រភេទ ដោយផ្អែកតាមមុខងារនៃស្ថាប័ន ដែលក្នុងនោះរួមមានទិន្នន័យដូចជា ពន្ធដារ, ពន្ធគយ, ចំណូលមិនមែនសារពើពន្ធ, ចំណាយ, ទ្រព្យរដ្ឋ និងបំណុល ជាដើម ដូចបង្ហាញក្នុងរូបភាពទី ១៦ ខាងក្រោម។

រូបភាពទី ១៦៖ ការកំណត់ពីទិន្នន័យ (Data Discovery) នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



នៅក្នុងដំណាក់កាលនៃការបែងចែកប្រភេទទិន្នន័យនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, យើងអាចបែងចែកទិន្នន័យជាចំនួន ៦ ប្រភេទធំៗ (រូបភាពទី ១៧) ដែលរួមមាន (១)-ការគ្រប់គ្រងចំណូល, (២)-ការអនុវត្តចំណូល-ចំណាយ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យនៃថវិការដ្ឋ, (៣)-ការវិនិយោគសាធារណៈ, (៤)-ឧស្សាហកម្មហិរញ្ញវត្ថុ,(៥)-រដ្ឋបាល, ធនធានមនុស្ស, សារពើភណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ និងសេវាសាធារណៈ និង (៦)-ម៉ាក្រូសេដ្ឋកិច្ច, សវនកម្ម និងអធិការកិច្ច។ ការបែងចែកនេះគឺធ្វើឡើយ ដោយផ្អែកតាមមុខងារកម្មវិធីទាំង ៥ នៃការអនុវត្តថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលរួមមាន (១)-ការគ្រប់គ្រងវិស័យសេដ្ឋកិច្ច, (២)-ការគ្រប់គ្រងវិស័យហិរញ្ញវត្ថុ, (៣)-ការគ្រប់គ្រងចំណូលសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ, (៤)-ការគ្រប់គ្រងចំណាយសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង (៥)-កិច្ចការរដ្ឋបាល និងអភិវឌ្ឍស្ថាប័ន។

រូបភាពទី ១៧៖ ការបែងចែកប្រភេទទិន្នន័យ (Data Classification)



នៅក្នុងដំណាក់កាលទី ៣ ដែលជាដំណាក់កាលនៃការកំណត់ពីអភិក្រម ឬគោលនយោបាយនៃការគ្រប់គ្រងទិន្នន័យ (Data Policy or Principle), ការកំណត់ពីការណែនាំ និងដែនសមត្ថកិច្ចរបស់ប្រធានទិន្នន័យ, បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ, បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលអភិបាលកិច្ចទិន្នន័យ ឬបុគ្គលអធិការកិច្ចទិន្នន័យ លើអភិបាលកិច្ចទិន្នន័យ នឹងត្រូវបានបង្កើតឡើង។ ការកំណត់ពី

អភិក្រម ឬគោលនយោបាយនៃការគ្រប់គ្រងទិន្នន័យនេះ នឹងជួយឱ្យបុគ្គលនីមួយៗ ដឹងពីតួនាទី និងទំនួលខុសត្រូវរបស់ខ្លួន កាន់តែច្បាស់ ដែលនេះនឹងនាំឱ្យការអនុវត្តអភិបាលកិច្ចទិន្នន័យកាន់តែមានប្រសិទ្ធភាព និងរហូន។

នៅក្នុងដំណាក់កាលទី ៤ ដែលជាដំណាក់កាលនៃការកំណត់វិធានជាក់លាក់សម្រាប់គ្រប់គ្រងទិន្នន័យ, ការកំណត់វិធានការជាក់លាក់នឹងត្រូវធ្វើឡើងដោយផ្អែកតាមកត្តាមួយចំនួន ដែលរួមមានដូចជា ប្រភេទនៃសកម្មភាព (ការវិភាគទិន្នន័យ, ការធ្វើរបាយការណ៍ ឬការធ្វើសមាហរណកម្មនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (System Integration) និងក្របខ័ណ្ឌពេលវេលាក្នុងការសម្រេចបានសកម្មភាពទាំងនោះ (សប្តាហ៍, ខែ, ឬក្លាមៗ)។

ចំណែកអភិក្រម **"បច្ចេកវិទ្យា"** ត្រូវបានចាត់ទុកថាជាគន្លឹះដំរុញក្នុងអភិបាលកិច្ចទិន្នន័យ។ ជាទូទៅ, **"បច្ចេកវិទ្យា"** សំដៅលើឧបករណ៍ និងកម្មវិធីគ្រប់គ្រងទិន្នន័យ (Tools and Software), ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ត្រួតពិនិត្យ និងជូនដំណឹងពីគុណភាពទិន្នន័យ (Data Quality Monitoring and Alerting System), យន្តការគ្រប់គ្រងការចូលប្រើប្រាស់ទិន្នន័យ និង ការគ្រប់គ្រងលើការតាមដានលំហូរនៃទិន្នន័យ និងមេតាទិន្នន័យ (Data Lineage Tracking and Metadata Management)។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....សហវ.....

ប្រកាស
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការបង្កើតវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៧១ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១.-

ត្រូវបានបង្កើត "**ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**" ដែលសរសេរជាអក្សរកាត់ថា "**ក.ប.ព.**" ដើម្បីដឹកនាំសម្របសម្រួលនិងជំរុញការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងឌីជីថលព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយជរភាព សង្គតិភាព និងសុខដុមភាព ក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថល សំដៅកសាងនិងលើកកម្ពស់ភាពជឿទុកចិត្តលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជារួមចំណែកដល់ការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជាដ៏រស់រវើក អនុលោមតាមគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

ជំពូកទី២

តួនាទីនិងភារកិច្ចរបស់ ក.ប.ព.

ប្រការ២.-

ក.ប.ព. បំពេញមុខងារជាអង្គភាពបរិវត្តកម្មឌីជីថលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- កំណត់ចក្ខុវិស័យនៃការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដឹកនាំរៀបចំនិងតម្រង់ទិសលើការរៀបចំផែនការមេ យុទ្ធសាស្ត្រ ក្របខណ្ឌ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ គម្រោង និងផែនការសកម្មភាព ពាក់ព័ន្ធនឹងការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ដឹកនាំនិងជំរុញការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្ម ឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដឹកនាំនិងជំរុញការប្រើប្រាស់ធនធានបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថល រួមជាអាទិ៍ហេដ្ឋារចនាសម្ព័ន្ធឌីជីថលរួម មជ្ឈមណ្ឌលទិន្នន័យរួម ថ្នាលឌីជីថលរួម និងសេវាឌីជីថលរួម របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដឹកនាំនិងជំរុញការអភិវឌ្ឍសមត្ថភាពនិងគុណវុឌ្ឍិ ព្រមទាំងការអភិវឌ្ឍភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចឌីជីថលក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដឹកនាំនិងជំរុញការរៀបចំ ការពិនិត្យ និងការសម្រេចដាក់ឱ្យអនុវត្តស្តង់ដាបច្ចេកទេស ស្តង់ដាសន្តិសុខ ឌីជីថល ស្តង់ដានីតិវិធីប្រតិបត្តិ និងសេចក្តីណែនាំបច្ចេកទេសបច្ចេកវិទ្យាព័ត៌មានផ្សេងៗ ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់គ្រងហានិភ័យបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដឹកនាំសម្របសម្រួលការងារនិងដោះស្រាយបញ្ហាប្រឈមដែលមានលក្ខណៈអន្តរក្រសួង-ស្ថាប័ននិងអង្គភាព ពាក់ព័ន្ធនឹងគម្រោងបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កៀរគរធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងធនធានមនុស្ស ក្នុងបុព្វហេតុអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើការស្នើសុំថវិកាគាំទ្រដល់ការអភិវឌ្ឍគម្រោងបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដំរុញលើកទឹកចិត្តនិងគាំទ្រការចូលរួមលើកស្ទួយការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តិកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សហការនិងសម្របសម្រួលជាមួយនឹងក្រសួង-ស្ថាប័ននិងអង្គភាពពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍ ដើម្បីជំរុញការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៣
សមាសភាព ក.ប.ព.

ប្រការ៣.-

ក.ប.ព. មានសមាសភាព ដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ប្រធាន
- រដ្ឋលេខាធិការពាក់ព័ន្ធមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធាន
- ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប	អនុប្រធានប្រចាំការ
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ	អនុប្រធាន
- អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា	អនុប្រធាន

- នាយកមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" អនុប្រធាន
- អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុប្រធាន
- អនុរដ្ឋលេខាធិការពាក់ព័ន្ធមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- នាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអង្គភាពឬស្ថាប័នក្រោមអាណាព្យាបាលនិងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

ក.ប.ព. អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័នឬអង្គភាពពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ ក.ប.ព. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៤
ការប្រព្រឹត្តទៅរបស់ ក.ប.ព.

ប្រការ៤.-

ក.ប.ព. ត្រូវប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមានឬមានករណីចាំបាច់ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានឬអនុប្រធានប្រចាំការឱ្យកោះអញ្ជើញនិងដឹកនាំកិច្ចប្រជុំ

សមាជិក ក.ប.ព. ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានឬអនុប្រធានឬអនុប្រធានប្រចាំការក្នុងករណីដែលប្រធានអវត្តមានឬមានករណីចាំបាច់។ ប្រធានឬអនុប្រធានប្រចាំការក្នុងករណីដែលប្រធានអវត្តមានឬមានករណីចាំបាច់ មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័ននិងអង្គភាពពាក់ព័ន្ធ ដើម្បីចូលរួមកិច្ចប្រជុំនិងពិគ្រោះយោបល់ តាមការចាំបាច់។

ប្រការ៥.-

ក.ប.ព. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

ប្រការ៦.-

ក.ប.ព. មានក្រុមការងារបច្ចេកទេសមួយជាសេនាធិការក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

ក្រុមការងារបច្ចេកទេសនៃ ក.ប.ព. មានសមាសភាព ដូចខាងក្រោម៖

- អនុប្រធានប្រចាំការ ក.ប.ព. ប្រធាន
- ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ប្រធានអង្គភាពឬអនុប្រធានប្រចាំការទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន នៃអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយចំនួន អនុប្រធាន

- ប្រធាននាយកដ្ឋានទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន
  នៃអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន
  នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រុមការងារទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន
  នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

ក្រុមការងារបច្ចេកទេសនៃ ក.ប.ព. អាចមានសមាសភាពបន្ថែមជាប្រធានឬតំណាងអង្គភាពពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃក្រុមការងារបច្ចេកទេសនៃ ក.ប.ព. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រការ៧.-

ក្រុមការងារបច្ចេកទេសនៃ ក.ប.ព. មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួលលើការងារអនុវត្តផែនការមេ យុទ្ធសាស្ត្រ ក្របខណ្ឌ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍គម្រោង និងផែនការសកម្មភាព ដើម្បីកសាងនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងជំរុញការធ្វើបរិវត្តកម្មឌីជីថល
- សហការការងារជាមួយនឹងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាពឬស្ថាប័នក្រោមអាណាព្យាបាលនិងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការកសាងនិងការ-អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កសាង អភិវឌ្ឍ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងថ្នាលឌីជីថលសម្រាប់ការប្រើប្រាស់រួម ក្នុងប្រពៃនធ្វើកដាបច្ចេកទេស ស្តង់ដាសន្តិសុខឌីជីថល ស្តង់ដានីតិវិធីប្រតិបត្តិ និងសេចក្តីណែនាំបច្ចេកទេសបច្ចេកវិទ្យាព័ត៌មានផ្សេងៗ
- ផ្តួចផ្តើមនិងកំណត់កម្មវត្ថុនៃការសិក្សាស្រាវជ្រាវនិងរៀបចំទស្សនកិច្ចសិក្សាទាំងក្នុងប្រទេសនិងក្រៅប្រទេស ដើម្បីទាញយកបទពិសោធនិងប្រមូលជាតុចូលសំខាន់ៗពាក់ព័ន្ធនឹងការកសាងនិងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថល
- រៀបចំឱ្យមានការបណ្តុះបណ្តាល ការពង្រឹងសមត្ថភាពនិងគុណវុឌ្ឍិ និងការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងការអភិវឌ្ឍ ការប្រតិបត្តិ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំផែនការវិនិយោគ ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថល
- ពិនិត្យ ពិភាក្សា វាយតម្លៃ និងធ្វើអាទិភាវូបនីយកម្មគម្រោងបច្ចេកវិទ្យាព័ត៌មានដែលបានស្នើក្នុងក្របខណ្ឌការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាការគោរពគោលការណ៍គ្រឹះនៃថវិកានិងវិន័យហិរញ្ញវត្ថុសាធារណៈ ព្រមទាំងធានាសង្គតិភាពជាមួយនឹងផែនការមេបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល ព្រមទាំងការធ្វើបរិវត្តកម្មឌីជីថល

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួម យុទ្ធសាស្ត្រ ក្របខណ្ឌ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ គម្រោង និងផែនការសកម្មភាព ដោយត្រូវរៀបចំរបាយការណ៍ជូន ក.ប.ព.
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាន ក.ប.ព.។

ប្រការ៨.-

ក្រុមការងារបច្ចេកទេសនៃ ក.ប.ព. មាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាលេខាធិការដ្ឋាន។ លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសនៃ ក.ប.ព. បំពេញមុខងារជាសេនាធិការជូនក្រុមការងារបច្ចេកទេសនៃ ក.ប.ព. លើការងាររដ្ឋបាលនិងបច្ចេកទេស។

ជំពូកទី៥
អវសានប្បញ្ញត្តិ

ប្រការ៩.-

ប្រកាសលេខ ៣៦៩ សហវ-ប្រក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១០.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងប្រធានគ្រប់អង្គភាពឬស្ថាប័នក្រោមអាណាព្យាបាលនិងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១២ កើត ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់អង្គភាពឬស្ថាប័នក្រោមអាណាព្យាបាល និងក្រោមឱវាទរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០នីតិ.....សហវ.....

សេចក្តីសម្រេច
ស្តីពី
ការតែងតាំងសមាសភាពក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន និងសមាសភាពក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការបង្កើតវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៧១ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"
- បានឃើញប្រកាសលេខ ៧៤៧ សហវ.ប្រក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១.-

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ ក.ប.ព. ដូចខាងក្រោម ៖

- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន
- ឯកឧត្តមបណ្ឌិតសភាចារ្យ **ង្វៃ ឥទិត្ត** រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **តង់ ឥសុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយដ្ឋានពន្ធដារ អនុប្រធាន
- ឯកឧត្តម **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយដ្ឋានគយនិងរដ្ឋាករកម្ពុជា អនុប្រធាន
- ឯកឧត្តម **ឱ តាយ៉ី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ង្វៃ គឹមឡេង** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ស្តើង សុខុម** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ឥង់ សណ្ហាប់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

- ឯកឧត្តម **សួង ម៉េងគា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- លោកជំទាវ **កែវ ចរិយា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ជាន់ ផល្លា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **គីម សុភៈ** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ឈន សុភាព** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ចាន់ សុធី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **អៀង ស៊ុនលី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ហែល ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ហ៊ីវ សុវណ្ណ** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ឆាន់ វឌ្ឍនៈ** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ម៉ី ខ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- លោកជំទាវ **ប៉ែន សុបនា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ប៉ែន សំអាត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **គង់ ម៉ារី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានប្រចាំការ
- ឯកឧត្តម **ហាស សុខសេនសាន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ប៉ែន ធីរុទ្ធ** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ជា ឆុចណា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **ឈួន សំរីទ្ធិ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **តាំង ឡូនលី** នាយកប្រតិបត្តិមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" អនុប្រធាន
- ឯកឧត្តម **មន្ត ប្រាថ្នា** អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុប្រធាន
- ឯកឧត្តម **ឧេព អិយ៉ារិទ្ធ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **ចន ណារិទ្ធ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **ឯក ចន្ថា** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **វង្ស ប៊ុនឥន្ទ្រាវុធ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ សមាជិក
- ឯកឧត្តម **ហាវ រតនៈ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានឋវិកា សមាជិក
- ឯកឧត្តម **កែវ បេងវឌ្ឍន៍** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក
- ឯកឧត្តម **ឈឹម សារ៉ែត** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក

- ឯកឧត្តម **ឧេត មុន្នី** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក
- ឯកឧត្តម **អ៊ឹម សិទ្ធីរ៉ា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយកនៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ សមាជិក
- ឯកឧត្តម **ឆាយ រតនៈ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គាធិការនៃអគ្គាធិការដ្ឋាន សមាជិក
- ឯកឧត្តម **ឱម ម៉ាក់ចារិទ្ធ** អគ្គនាយកនៃអគ្គយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន សមាជិក
- ឯកឧត្តម **អ៊ុច លុយណា** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ សមាជិក
- ឯកឧត្តម **ហ៊ុល បុណ្ណារ័ត្ន** អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
និងគ្រប់គ្រងបំណុល សមាជិក
- លោកជំទាវ **ង៉ែត ម៉ូនីឈ្មេន** អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិក
- ឯកឧត្តម **អិន អេម** នាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

ប្រការ២.-

ត្រូវបានតែងតាំងសមាសភាពក្រុមការងារបច្ចេកទេសនៃ ក.ប.ព. ដូចខាងក្រោម៖

- ឯកឧត្តម **គង់ ម៉ារី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន
- ឯកឧត្តម **តាំង ឡូឆលី** នាយកប្រតិបត្តិមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" អនុប្រធាន
- ឯកឧត្តម **មន្ត ប្រាថ្នា** អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុប្រធាន
- លោក **អៀច សេដ្ឋា** អគ្គនាយករងនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល អនុប្រធាន
- លោក **ប៊ី ណារិន** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
នៃអគ្គលេខាធិការដ្ឋាន អនុប្រធាន
- លោក **ឈន ភឿន** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អនុប្រធាន
- លោក **ចាន ឌី ឥទ្ធ** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
នៃអគ្គនាយកដ្ឋានពន្ធដារ អនុប្រធាន
- លោក **ប៊ូរ ឥទ្ធិសាល** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
នៃអគ្គនាយកដ្ឋានរតនាគារជាតិ សមាជិក
- លោក **ជាតិ សុខា** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក
- លោក **ជាត់ ខាសនា** ប្រធាននាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន
នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិក
- លោក **ហួត ខ្វ៉ែនហួ** ប្រធានផ្នែកបច្ចេកវិទ្យាព័ត៌មាននីតិកម្ម
នៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម សមាជិក

- លោក **សូ សុភា** ប្រធានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ
  នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាមិនមែនធនាគារ សមាជិក។

ប្រការ៣ .-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១និងប្រការ២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៤៤.....សហវ.សស.ទ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោង បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៦៩/១៨ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- បានឃើញអនុក្រឹត្យ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- បានឃើញប្រកាសលេខ ២៦៩ សហវ-ប្រក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- បានឃើញប្រកាសលេខ ៣៦៩ សហវ.ប្រក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១..

ត្រូវបានបង្កើតក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម៖

- ឯកឧត្តម **គង់ ហ៊ីរ** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន
- ឯកឧត្តម **យ៉ែត ឥវិណាល** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុប្រធាន
- ឯកឧត្តម **តាំង ឡូនលី** នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីតេជោ អនុប្រធាន
- ឯកឧត្តម **សេង ស្រេង** អគ្គនាយករងនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អនុប្រធាន
- លោកស្រី **ឈុន ជាលីន** អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា អនុប្រធាន
- លោក **ឃី សុខចារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល អនុប្រធាន
- ឯកឧត្តម **ឌី សុវណ្ណ** អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក
- លោក **ហង្ស ភុទ្ធិកា** អគ្គនាយករងនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន សមាជិក
- លោក **ឥន្ទ្រី ឥចិត្រ** អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា សមាជិក
- លោក **ឡាយ សុខយៀង** ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានថវិកា សមាជិក

- លោក **ហេង ស៊ីឡឿន** ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានថវិកា សមាជិក
- លោក **រៀច សេដ្ឋា** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
  នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- លោក **ហៃ សុភុច្ឆា** ប្រធាននាយកដ្ឋាន
  នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក
- លោក **ឡាយ សុភ័ក្ត្រ** ប្រធាននាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា សមាជិក
- លោក **តាន់ ឡូ** អនុប្រធាននាយកដ្ឋាន
  នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក
- លោក **សឿង ភុត្ថា** អនុប្រធាននាយកដ្ឋាន
  នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក
- លោក **ហាស សំអាន** អនុប្រធាននាយកដ្ឋាន
  នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល សមាជិក
- លោកស្រី **សេង មួយយូ** ប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល សមាជិកា
- លោក **អ៊ុន សាភាន** ប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន សមាជិក
- លោក **ឃួន សុភាផល្លា** ប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន សមាជិក
- កញ្ញា **ជា ម៉ីកា** ប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន សមាជិកា
- លោក **ង៉ែត គឹមហាយ** ប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក
- លោក **ជោត មុនីភក្តី** អនុប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក
- លោក **កែម បញ្ញា** មន្ត្រីនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក។

ប្រការ២.-

ក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យនិងផ្តល់យោបល់លើទិដ្ឋភាពបច្ចេកទេសនិងហិរញ្ញវត្ថុលើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន
  និងគមនាគមន៍ ឬគម្រោង/ការងារពាក់ព័ន្ធនឹងវិស័យឌីជីថល ដែលក្រសួង-ស្ថាប័នស្នើសុំថវិកាឬ

ហិរញ្ញប្បទានមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងគម្រោងដែលស្នើនិងអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពីគ្រប់ប្រភពនៃថវិកានិងហិរញ្ញប្បទាន

- ពិភាក្សា វាយតម្លៃ និងធ្វើអាទិភាវូបនីយកម្មសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ឬគម្រោង/ការងារពាក់ព័ន្ធនឹងវិស័យឌីជីថល ដើម្បីធានាប្រសិទ្ធភាពនៃចំណាយថវិកាសាធារណៈ និងអនុលោមភាពជាមួយនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ព្រមទាំងគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- បូកសរុប ផ្តល់អនុសាសន៍ និងផ្តល់របាយការណ៍ពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ឬគម្រោង/ការងារពាក់ព័ន្ធនឹងវិស័យឌីជីថល ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងសម្រេច មុននឹងអនុញ្ញាតឱ្យដាក់ចូលក្នុងបញ្ជីនៃការផ្តល់ថវិកា, ការអនុវត្តនីតិវិធីនៃការអនុវត្តថវិកាឬការផ្តល់ហិរញ្ញប្បទាន
- បំពេញតួនាទីនិងភារកិច្ចពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់និងតាមបញ្ជារបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រការ៣..

ក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។ ក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់ ប្រធានក្រុមការងារអាចផ្ទេរសិទ្ធិជូនអនុប្រធានណាមួយដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិកក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារឬអនុប្រធានក្រុមការងារណាមួយក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់។

ប្រការ៤..

ក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ អាចអញ្ជើញតំណាងអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័ននិង/ឬអង្គភាពពាក់ព័ន្ធផ្សេងទៀតចូលរួមក្នុងកិច្ចប្រជុំពិនិត្យនិងពិភាក្សាតាមការចាំបាច់។

ប្រការ៥..

ក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ មានលេខាធិការដ្ឋានមួយជាសេនាធិការនៅក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ត្រូវបំពេញមុខងារជាលេខាធិការដ្ឋានឱ្យក្រុមការងារនេះ។

ប្រការ៦.-

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៧.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣ ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ២០២៣

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ

បរិសិទ្ធ ៧. បញ្ជីឈ្មោះក្រុមការងាររៀបចំក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក. អ្នកដឹកនាំក្រុមការងារ

១.	ឯកឧត្តមបណ្ឌិត **គង់ ម៉ារី**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.)
២.	ឯកឧត្តមបណ្ឌិត **តាំង ឆ្នលី**	នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (ម.ធ.ត.)

ខ. ក្រុមការងារតាក់តែងឯកសារ

៣.	អ្នកស្រីបណ្ឌិត **ឥន្ទ្រ រីលីជា**	នាយករងនៃ ម.ធ.ត.
៤.	លោក **ស្ទ្រូ លីហ៊ុល**	មន្ត្រីស្រាវជ្រាវនៃ ម.ធ.ត.
៥.	លោក **តាន់ ឥណ្ណលិ**	មន្ត្រីស្រាវជ្រាវគោលនយោបាយនៃ គ.ស.ធ.ឌ.
៦.	កញ្ញា **សំណាង សុភ័ក្ត្រនាថ**	មន្ត្រីស្រាវជ្រាវគោលនយោបាយនៃ គ.ស.ធ.ឌ.
៧.	លោក **ទិទ្ធ រតន:**	មន្ត្រីស្រាវជ្រាវគោលនយោបាយនៃ គ.ស.ធ.ឌ.

គ. ក្រុមការងារបច្ចេកទេស

៨.	លោក **ឆិត្យ ជារ៉ាយ៉ុង**	នាយករងនៃ ម.ធ.ត.
៩.	លោក **អៀច សេដ្ឋា**	អគ្គនាយករងនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
១០.	លោក **សុង ម៉េងចុង**	វិស្វករផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាននៃ ម.ធ.ត.
១១.	លោក **យិន កក់ចឹង**	អ្នកគ្រប់គ្រងបច្ចេកទេសថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
១២.	លោក **ប៉ែង ឆ័យឡេង**	អ្នកអភិវឌ្ឍកម្មវិធីជាន់ខ្ពស់នៃ ម.ធ.ត.
១៣.	លោក **ប៊ី ណារិន**	ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
១៤.	លោក **ឆៅ ឥចិត្រ្តា**	អនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
១៥.	លោក **ចាន់ ណារិន**	មន្ត្រីនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

ឃ. ក្រុមការងារបកប្រែឯកសារ

១៦.	លោក **ផុង គឹមឆួយ**	មន្ត្រីស្រាវជ្រាវនៃ ម.ធ.ត.
១៧.	លោក **សាយ សៀកឡាយ**	មន្ត្រីស្រាវជ្រាវនៃ ម.ធ.ត.
១៨.	លោក **សោម ឥសិដ្ឋវឌ្ឍន:**	មន្ត្រីស្រាវជ្រាវនៃ ម.ធ.ត.
១៩.	លោក **លឹម សេងហុង**	មន្ត្រីនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
២០.	លោក **ឌួង សុភ័ក្ត្រ**	មន្ត្រីនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
២១.	លោក **ឈឹម សុខសំបូណ៌ឫទ្ធី**	មន្ត្រីនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល

ង. អ្នករចនាក្រាហ្វិក

២២.	លោក **សុិន ឥសាល**	អ្នកអភិវឌ្ឍកម្មវិធីជាន់ខ្ពស់នៃ ម.ធ.ត.



រក្សាសិទ្ធិដោយ
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ